សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការបញ្ជូនក្នុងនីតិវិធីជំនុំជម្រះលើកទី១

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **កែវ ពេជ្រនេត្រា**
កញ្ញា **ផាន ស្រីពេជ្រ**

សាស្ត្រាចារ្យណែនាំ
លោក **ហ៊ីង គីមឡេង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# មាតិកា


សេចក្ដីផ្ដើម ............................................................. ១

១. ចំណោទបញ្ហានៃការស្រាវជ្រាវ ............................................. ២

២. គោលបំណងនៃការស្រាវជ្រាវ ............................................. ២

៣. សារៈសំខាន់នៃការស្រាវជ្រាវ ............................................. ២

៤. វិធីសាស្ត្រនៃការស្រាវជ្រាវ ............................................. ៣

៤.១. វិធីសាស្ត្រប្រមូលទិន្នន័យ ............................................. ៣

ក. ទិន្នន័យចម្បង ............................................. ៣

ខ. ទិន្នន័យបន្ទាប់បន្សំ ............................................. ៣

៤.២. វិធីសាស្ត្រវិភាគទិន្នន័យ ............................................. ៤

៥. គ្រោងខណ្ឌ នៃការស្រាវជ្រាវ ............................................. ៥


## ជំពូកទី១

## ការសិក្សាលើលិខិតតូបករណ៍គតិយុត្ត និងទ្រឹស្តីច្បាប់ដែលពាក់ព័ន្ធ


១. សញ្ញាណទូទៅនៃការបញ្ជូន ............................................. ៦

១.១. និយមន័យ ............................................. ៦

១.២. មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន ............................................. ៧

១.២.១. មន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូន ............................................. ៧

១.២.២. មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន ............................................. ៧

១.៣. ឯកសារដែលត្រូវធ្វើការបញ្ជូន ............................................. ៧

២. វិធីនៃការបញ្ជូន និងរបាយការណ៍នៃការបញ្ជូន ............................................. ៩

២.១. វិធីនៃការបញ្ជូន និងការបញ្ជូនទៅអសមត្ថជនក្នុងបណ្ដឹង ............................................. ៩

២.១.១. វិធីនៃការបញ្ជូន ........................................................................................ ៩

២.១.២. ការបញ្ជូនទៅអសមត្ថជនក្នុងបណ្ដឹង ........................................................ ១៤

២.២. របាយការណ៍អំពីការបញ្ជូន ................................................................................. ១៤

## ជំពូកទី២

## ការរកឃើញលើការអនុវត្តជាក់ស្ដែង ឬ ការពិពណ៌នាអំពីការខារ

១. មន្ត្រីដែលធ្វើការបញ្ជូនក្នុងការអនុវត្តជាក់ស្ដែង ..........................................១៦

១.១. មន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូន ....................................................... ១៦

១.២. មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន ............................................................ ១៦

១.២.១. ក្រឡាបញ្ជី...........................................................................................១៧

១.២.២. បុគ្គលិកប្រៃសណីយ៍ ..........................................................................១៧

២. វិធីបញ្ជូនក្នុងការអនុវត្តជាក់ស្ដែង.................................................................. ១៧

២.១. ការបញ្ជូនដោយការប្រគល់................................................................................ ១៨

២.២. ការបញ្ជូនដោយការជួបប្រទះ ................................................................................ ១៨

២.៣. ការបញ្ជូនដោយបន្ទប់កិច្ច.................................................................................... ១៩

២.៤. ការបញ្ជូនដោយទុកចោល ...................................................................................... ១៩

២.៥. ការបញ្ជូនទៅបរទេស.............................................................................................. ១៩

២.៦. ការបញ្ជូនតាមការផ្សាយជាសាធារណៈ ........................................................២០

២.៦.១. លក្ខខណ្ឌនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ ..................................២១

២.៦.២. របៀបបញ្ជូនតាមការផ្សាយជាសាធារណៈ ..................................................២២

២.៦.៣. អានុភាពនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ..................................២២

២.៧. ការបញ្ជូនទៅអសមត្ថជនក្នុងបណ្ដឹង ...........................................................២៣

៣. របាយការណ៍អំពីការបញ្ជូន ....................................................................................... ២៣
៣.១. គំរូរបាយការណ៍អំពីការបញ្ជូន ........................................................................... ២៣
៣.២. ការបំពេញរបាយការណ៍អំពីការបញ្ជូន ................................................................. ២៤

## ជំពូកទី៣
## ការវិភាគប្រៀបធៀបរវាងការអនុវត្តជាក់ស្តែងដែលរកឃើញជាមួយទ្រឹស្តីច្បាប់គតិយុត្ត

១. ភាពត្រឹមត្រូវក្នុងការអនុវត្តច្បាប់ក្នុងនីតិវិធីបញ្ជូន ...................................... ២៦
១.១. មន្ត្រីដែលធ្វើការបញ្ជូន ................................................................................... ២៦
១.១.១. មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន ................................................................... ២៦
១.១.២. មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន ........................................................... ២៧
១.១.២.១. ក្រឡាបញ្ជី ............................................................................................ ២៧
១.១.២.២. បុគ្គលិកប្រៃសណីយ៍ ............................................................................. ២៧
១.២. វិធីបញ្ជូន និងការធ្វើរបាយការណ៍បញ្ជូន .................................................................. ២៨
១.២.១. វិធីបញ្ជូន .................................................................................................. ២៨
១.២.២. ការធ្វើរបាយការណ៍អំពីការបញ្ជូន ................................................................ ២៨
២. នីតិវិធីនៃការបញ្ជូនដែលមិនទាន់បានអនុវត្ត និង ចំណុចខ្វះខាតក្នុងការអនុវត្ត ............................................................................................................ ២៩
២.១. ស្ថាប័នដែលមិនបានបំពេញកិច្ចនីតិវិធីនៃការបញ្ជូន ................................................... ២៩
២.២. វិធីបញ្ជូន និង ការបំពេញរបាយការណ៍នៃការបញ្ជូន ................................................. ២៩
២.២.១. វិធីបញ្ជូន .................................................................................................. ២៩
២.២.២. ការបំពេញរបាយការណ៍អំពីការបញ្ជូន ......................................................... ៣០
សេចក្តីសន្និដ្ឋាន ................................................................................................... ៣២

**ការផ្តល់អនុសាសន៍** ............................................................................................ ៣៤
**ឯកសារយោង**
**បញ្ជីរាយនាមឧបសម្ព័ន្ធ**

# អារម្ភកថា

សារណាមួយក្បាលនេះជាគឺជាស្នាដៃទីមួយ  និងជាសមិទ្ធផលដែលបានមកពីការខិតខំប្រឹងប្រែងព្យាយាមក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចអស់រយៈពេល ០៤ ឆ្នាំ កន្លងមក ហើយព្រមទាំងបានឆ្លងកាត់ការសិក្សាជាសិស្សក្រឡាបញ្ជី នៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គួបផ្សំ និងការចុះកម្មសិក្សាអនុវត្តការងារជាក់ស្តែងនៅក្នុងសាលាដំបូង និង អយ្យការអមសាលាដំបូងខេត្តព្រះសីហនុកន្លងមកធ្វើឲ្យយើងខ្ញុំបានយល់ដឹងកាន់តែច្បាស់ថាវិស័យច្បាប់ គឺដើរតួរយ៉ាងសំខាន់ក្នុងវិស័យផ្សេងៗទៀត  ហើយវិស័យច្បាប់ក៏បានដើរតួរនាទីយ៉ាងសំខាន់ក្នុងការរៀបចំសណ្តាប់ធ្នាប់សង្គមឲ្យមានរបៀបរៀបរយផងដែរ។ ក្នុងវិស័យច្បាប់មាននីតិវិធីជាច្រើនហើយគ្រប់ដំណាក់កាលត្រូវធ្វើឡើងស្របទៅនឹងច្បាប់កំណត់  ពីមួយដំណាក់កាលទៅមួយដំណាក់ការអនុវត្ត  និងនីតិវិធីសុទ្ធតែមានលក្ខណៈខុសគ្នាដែលវាមានលក្ខណៈស្មុគស្មាញ។  ហេតុនេះជាមូលហេតុដែលយើងខ្ញុំបានជ្រើសរើសយកនូវការស្រាវជ្រាវសារណាមួយនេះឡើងក្រោមប្រធានបទស្តីពី  “**ការបញ្ជូនក្នុងនីតិវិធីជំនុំជម្រះលើកទី១**”  ការដែលយើងខ្ញុំជ្រើសរើសប្រធានបទនេះមកធ្វើជាសារណាបញ្ចប់ការសិក្សា  ឃើញថានីតិវិធីនៃការបញ្ជូនពិតជាមានសារៈសំខាន់ចំពោះភាគីដែលពាក់ព័ន្ធនឹងរឿងក្តីហើយនីតិវិធីនៃការបញ្ជូនមានច្រើនរបៀបដែលយើងគួរតែស្វែងយល់ពីការអនុវត្តច្បាប់ក្នុងដំណើរការនីតិវិធីនាពេលបច្ចុប្បន្នឲ្យកាន់តែច្បាស់បន្ថែមទៀត។

តាមរយៈស្នាដៃស្រាវជ្រាវមួយនេះ យើងខ្ញុំសង្ឃឹមថាសារណាក្រោមប្រធានបទខាងលើនេះ នឹងក្លាយជាវិភាគទានមួយចំណែកក្នុងវិស័យច្បាប់  និងចំពោះអ្នកសិក្សាជំនាន់ក្រោយ  អ្នកស្រាវ  និងអ្នកដែលបម្រើការងារក្នុងវិស័យច្បាប់ទាំងអស់ដើម្បីទុកជាផលប្រយោជន៍សម្រាប់ជំនួយស្មារតី  និងយកទៅប្រើប្រាស់ក្នុងវិស័យការងារដែលពាក់ព័ន្ធផងដែល។  យើងខ្ញុំទាំងពីរនាក់សប្បាយរីករាយ   នឹងទទួលយកនូវការរិះគន់ក្នុងន័យស្ថាបនារបស់លោក លោកស្រី សាស្ត្រាចារ្យ និង គ្រប់ស្រទាប់អ្នកសិក្សាទាំងអស់ដោយទុកមិតិរិះគន់នេះដើម្បីស្ថាបនាក្នុងការកែលម្អនូវចំណុចខ្វះខាតដែលកើតមាននៅក្នុងសារណានេះ  ហើយយើងខ្ញុំនឹងប្តេជ្ញាចិត្តយ៉ាងមុតមាំថានឹងយកនូវបទពិសោធន៍អំពីការចុះកម្មសិក្សាលើការអនុវត្តការងារជាក់ស្តែងនេះមកធ្វើការប្រៀបធៀបជាមួយនឹងទ្រឹស្តីដែលមាននៅក្នុងបទដ្ឋានគតិយុត្តនានាដើម្បីរៀបចំនូវឯកសារសារណាបញ្ចប់ការសិក្សានេះឲ្យកាន់តែមានភាពល្អប្រសើរព្រមទាំងដើម្បីចូលរួមចំណែកក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើកំណែទម្រង់វិស័យច្បាប់  និងប្រព័ន្ធយុត្តិធម៌ឲ្យទទួលបានការទុកចិត្តពីប្រជាពលរដ្ឋទៅលើការបម្រើសេវាយុត្តិធម៌ឲ្យបានល្អ ប្រសើរនិងត្រឹមត្រូវតាមច្បាប់កំណត់។

ជាចុងក្រោយយើងខ្ញុំសូមជូនពរ លោក លោកស្រី សាស្ត្រាចារ្យ និងសិស្សនិស្សិតដែលកំពុងសិក្សាក៏ដូចជាបញ្ចប់ការសិក្សា ទាំងអស់គ្នាឲ្យជួបតែសំណាងល្អសុខភាពល្អ និងទទួលបានជោគជ័យគ្រប់ភារកិច្ច។

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំទាំងពីររូបឈ្មោះ **កែវ ពេជ្រនេត្រា** និង **ផាង ស្រីពេជ្រ** ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**យើងខ្ញុំទាំងពីរអ្នកសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

លោកឪពុក **កែវ ឡា** និងអ្នកម្តាយ **ហេង ចាន់ធឿន** លោកឪពុក **ផាង ផាន** និងអ្នកម្តាយ **ហេង វ៉ាង** ដែលលោកបានផ្តល់កំណើតព្រមទាំងចិញ្ចឹមបីបាច់មើលថែរក្សាថ្នាក់ថ្នមរូបយើងខ្ញុំតាំងពីពេលចាប់កំណើតមកទល់សព្វថ្ងៃនេះពេញដោយក្តីស្រលាញ់ ការសណ្តោសប្រណី និងព្រហ្មវិហារធម៌ ជាពិសេសគឺជាគ្រូដែលបានផ្តល់នូវការអប់រំទូន្មានដំបូងបំផុត នៃជីវិតរបស់យើងខ្ញុំទាំងពីរអ្នកលើសពីនេះទៅទៀតពួកលោកតែងតែជួយជ្រោមជ្រែងគ្រប់សព្វបែបយ៉ាងទាំងផ្នែកស្មារតី និង សម្ភារៈសម្រាប់ផ្គត់ផ្គង់ដល់ការរៀនសូត្ររបស់យើងខ្ញុំតាំងពីថ្នាក់បឋមសិក្សា រហូតដល់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច នាវេលានេះដោយពុំដែលត្អូញត្អែរពីភាពនឿយហត់បន្តិចណាសោះឡើយដែលទាំងនេះគឺជាកម្លាំងជំរុញដ៏អស្ចារ្យបំផុតមួយនៅពីក្រោយភាពជោគជ័យរបស់យើងខ្ញុំទាំងពីរនាក់ក្នុងពេលបច្ចុប្បន្ននេះ។

យើងខ្ញុំសូមគោរពថ្លែងអំណរគុណផងដែរចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស និងលោក លោកស្រី សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច** ទាំងអស់ដែលបានយកចិត្តទុកដាក់ចំណាយពេលវេលា និង កម្លាំងញើសឈាមដ៏មានតម្លៃរបស់អស់លោកដើម្បីបណ្តុះបណ្តាល និង បំពេញបន្ថែមនូវពុទ្ធិដល់រូបយើងខ្ញុំក៏ដូចជាមិត្តនិស្សិតទាំងអស់ដែលសិក្សានៅក្នុងសាកលវិទ្យាល័យនេះ គ្រប់មុខវិជ្ជាតាំងពីថ្នាក់សិក្សាឆ្នាំមូលដ្ឋានរហូតដល់បញ្ចប់ការសិក្សា។

យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **លោកសាស្ត្រាចារ្យ ហ៊ីង គឹមឡេង** ដែលលោកសាស្ត្រាចារ្យ បានព្រមទទួលយកនូវការដឹកនាំក្នុងការសរសេរសាណាបញ្ចប់ការសិក្សារបស់យើងខ្ញុំដោយលោកបានចំណាយនូវពេលវេលាដ៏មានតម្លៃទាំងកម្លាំងកាយ និង កម្លាំងចិត្តដើម្បីបណ្តុះបណ្តាល និង ពន្យល់ណែនាំផ្តល់ជាចង្កៀងដើម្បីបំភ្លឺគំនិតដល់យើងខ្ញុំ ក្នុងរយៈពេលកន្លងមកមកនេះរហូតយើងខ្ញុំបានចងក្រងនូវសារណាបញ្ចប់ថ្នាក់បរិញ្ញាប័ត្រមួយនេះឡើងដោយភាពជោគជ័យ។

ជាទីបញ្ចប់យើងខ្ញុំសូមធ្វើការគោរពជូនពរដល់**លោកអ្នកមានគុណរបស់យើងខ្ញុំទាំងពីររូប ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោកសាស្ត្រាចារ្យ លោក លោកស្រី និងសិស្សនិស្សិតទាំងអស់** សូមឲ្យជួបប្រទះតែនូវពុទ្ធពរទាំងបួនប្រការគឺ៖ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។សូមអរគុណ៕

# សេចក្តីសង្ខេបខ្លឹមសាររបាយការណ៍

ក្នុងអំឡុងពេលចុះកម្មសិក្សានៅសាលាដំបូង និង អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ អស់រយៈពេល ៦ (ប្រាំមួយ) ខែមកនេះ យើងខ្ញុំបានធ្វើការរៀបចំនូវសារណាបញ្ចប់ការសិក្សាមួយឡើងដែលទាក់ទងទៅនឹងនីតិវិធី នៅក្នុងដំណើររឿងរដ្ឋប្បវេណី នឹងបានសម្រេចចិត្តធ្វើការជ្រើសរើសប្រធានបទសារណាដែលពាក់ព័ន្ធនឹងនីតិវិធីរដ្ឋប្បវេណី ដើម្បីចងក្រងជាសារណាបញ្ចប់ការសិក្សាស្តីពី "**ការបញ្ជូនក្នុងនីតិវិធីជំនុំជម្រះលើកទី១**"។ ចំពោះការសម្រេចចិត្តធ្វើការជ្រើសរើសប្រធានបទនេះឡើងដោយសារតែមានការពាក់ព័ន្ធយ៉ាងសំខាន់ទៅលើដំណើរការនីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណី និងជាតួនាទីមួយដ៏សំខាន់របស់ក្រឡាបញ្ជីផងដែរ។ ចំណុចសំខាន់ក្នុងនីតិវិធីនៃការបញ្ជូននេះ គឺធ្វើយ៉ាងណាឲ្យភាគីបានដឹងអំពីខ្លឹមសារនៃឯកសារតាមផ្លូវបណ្តឹងដើម្បីឲ្យភាគីនៅក្នុងបណ្តឹងប្រើប្រាស់សិទ្ធិតាមផ្លូវច្បាប់របស់ខ្លួន និង ធ្វើយ៉ាងណាឲ្យភាគីអាចចូលរួមក្នុងដំណើរការនីតិវិធីរបស់ខ្លួនបានគ្រប់ដំណាក់កាល។ ដូចជាឲ្យភាគីបានយល់ដឹងពីចំណាត់ការនានា ព្រមទាំងការសម្រេចរបស់តុលាការលើដំណើរការនីតិវិធីរឿងក្តី។

ដើម្បីធ្វើការសិក្សាលើដំណើរការនីតិវិធីនៃការបញ្ជូនក្នុងរឿងក្តីរដ្ឋប្បវេណីនេះឲ្យបានច្បាស់គឺយើងខ្ញុំមបានធ្វើការបែងចែកនៅក្នុងសារណាបញ្ចប់ការសិក្សានេះជា ៣ (បី) ជំពូកសំខាន់ៗ រួមមានៈ

**ជំពូកទី១៖ ការសិក្សាលើលិខិតឧបករណ៍គតិយុត្ត និងទ្រឹស្តីច្បាប់ដែលពាក់ព័ន្ធ** ដែលមានការសិក្សាបែងចែកជា ២ (ពីរ) **ផ្នែក** រួមមាន **ផ្នែកទី១** សិក្សាលើ **សញ្ញាណទូទៅនៃការបញ្ជូន** ដើម្បីធ្វើការសិក្សាអំពីអត្ថន័យនៃការបញ្ជូន,ស្ថាប័នដែលធ្វើការបញ្ជូន និងឯកសារដែលត្រូវធ្វើការបញ្ជូននិង **ផ្នែកទី២** សិក្សាទៅលើ**វិធីនៃការបញ្ជូន និង របាយការណ៍អំពីការបញ្ជូន** ដើម្បីឲ្យមន្ត្រីដែលទទួលបន្ទុកកិច្ចការបញ្ជូននិងមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនធ្វើការអនុវត្ត។ ការសិក្សាក្នុងជំពូកទី១នេះ គឺសិក្សាតែលើទ្រឹស្តីច្បាប់ និងបទដ្ឋានគតិយុត្តជាធរមានប៉ុណ្ណោះដែលជាមូលដ្ឋាននៃការយល់ដឹងដំបូងមុននឹងឈានដល់ការសិក្សាលើការអនុវត្តការងារជាក់ស្តែងលើដំណើរការបញ្ជូនក្នុងនីតិវិធីជំនុំជម្រះលើកទី១ នៅក្នុងសាលាដំបូងខេត្តព្រះសីហនុ។

**ជំពូកទី២៖ ការរកឃើញលើការអនុវត្តជាក់ស្តែង ឬ ការពិពណ៌នាអំពីការងារ** នៅក្នុងដំណើរការបញ្ជូនក្នុងនីតិវិធីជំនុំជម្រះលើកទី១ ដែលបានអនុវត្តនៅសាលាដំបូងខេត្តព្រះសីហនុ លើដំណើរការនីតិវិធីនៃការបញ្ជូនក្នុងរឿងក្តីរដ្ឋប្បវេណីជាក់ស្តែង។ ការសិក្សានៅក្នុងជំពូកនេះ គឺនឹងធ្វើការសិក្សាដែលមានការបែងចែកជា ២ (ពីរ) **ផ្នែក** រួមមាន **ផ្នែកទី១** ដែលធ្វើការសិក្សាពី **រចនាសម្ព័ន្ធតុលាការ និងរដ្ឋបាលនៃតុលាការខេត្តព្រះសីហនុ** ដើម្បីធ្វើការស្វែងយល់ឲ្យបានច្បាស់ពីការគ្រប់គ្រងដឹកនាំ និងរៀបចំការងារនៃការអនុវត្តការងារនៅក្នុងសាលាដំបូងខេត្តព្រះសីហនុ។ ចំពោះ **ផ្នែកទី២** គឺសិក្សាពី **នីតិវិធីនៃការបញ្ជូនដែលបានអនុវត្តជាក់ស្តែង**

ដោយមានការសិក្សាពីស្ថាប័នដែលធ្វើការបញ្ជូន វិធីនៃការបញ្ជូននិងរបាយការណ៍អំពីការបញ្ជូនដែលបានអនុវត្តជាក់ស្តែងហើយបានចូលរួមសិក្សាដោយផ្ទាល់លើការអនុវត្តច្បាប់នេះដែលបានជួបប្រទះក្នុងពេលធ្វើកម្មសិក្សា។

**ជំពូកទី៣៖ ការវិភាគប្រៀបធៀបរវាងការអនុវត្តជាក់ស្តែងដែលរកឃើញជាមួយទ្រឹស្តីច្បាប់គតិយុត្ត** គឺជាការសិក្សាលើនីតិវិធីនៃការបញ្ជូនក្នុងរឿងក្តីរដ្ឋប្បវេណីដែលបានអនុវត្តមានភាពសមស្របឬមិនទាន់មានភាពសមស្របទៅតាមច្បាប់កំណត់ដោយធ្វើការប្រៀបធៀបរវាងទ្រឹស្តីច្បាប់ និង ការអនុវត្តជាក់ស្តែងលើដំណើរការនីតិវិធីនៃការបញ្ជូននេះ។ ការសិក្សាក្នុងជំពូកទី៣នេះមានការសិក្សាបែងចែកជា ២ (ពីរ) ផ្នែករួមមានផ្នែកទី១ គឺសិក្សាពីភាពត្រឹមត្រូវនៃការអនុវត្តច្បាប់នៃនីតិវិធីបញ្ជូន និងផ្នែកទី២ សិក្សាពីនីតិវិធីនៃការបញ្ជូនដែលមិនទាន់បានអនុវត្ត និងចំណុចខ្វះខាតក្នុងការអនុវត្ត។

ទោះជាយ៉ាងណាក៏ដោយសម្រាប់សារណានេះគឺផ្តោតសំខាន់ទៅលើខ្លឹមសារច្បាប់ និង ការអនុវត្តការងារជាក់ស្តែងលើដំណើរការនីតិវិធីនៃការបញ្ជូនដែលបានរៀបចំឡើងក្នុងអំឡុងពេលចុះកម្មសិក្សានេះ គឺគ្រាន់តែបានសិក្សាលើផ្នែកនៃការអនុវត្តមួយចំនួនប៉ុណ្ណោះ ដោយមិនទាន់មានលក្ខណៈស៊ីជម្រៅលើដំណើរការនីតិវិធីទាំងអស់នោះទេដោយសារតែដំណើរការនីតិវិធីនៃការបញ្ជូននេះមានលក្ខណៈលម្អិត ជាងនេះទៅទៀតក្នុងការអនុវត្តហើយសម្រាប់រយៈពេលកម្មសិក្សានេះមានរយៈពេលខ្លីដែលមិនអាចធ្វើការសិក្សាឲ្យបានយល់ច្បាស់ទាំងស្រុងលើដំណើរការនីតិវិធីនេះនោះទេគ្រាន់តែសិក្សាបានលើចំណុចមួយចំនួនដែលបានជួបប្រទះក្នុងអំឡុងពេលកម្មសិក្សានេះប៉ុណ្ណោះដោយចំណុចជាច្រើនមិនត្រូវបានជួបប្រទះទើបធ្វើឲ្យការសិក្សាមិនទាន់យល់ច្បាស់ទាំងស្រុងនៅឡើយចំពោះលទ្ធផលដែលបានឆ្លងកាត់ក្នុងអំឡុងពេលចុះកម្មសិក្សានេះចំណុចដែលទទួលបានសម្រាប់ជាចំណេះដឹងក្នុងនីតិវិធីនៃការអនុវត្តច្បាប់លើដំណើរការនីតិវិធីនៃការបញ្ជូននេះគឺមាននូវចំណុចវិជ្ជមានជាច្រើនលើការអនុវត្តហើយក៏បានសង្កេតឃើញក៏មាននូវបញ្ហាប្រឈមមួយចំនួនក្នុងការអនុវត្តផងដែរដូចជាវិធីបញ្ជូនមួយចំនួនមិនត្រូវបានអនុវត្ត និងភាពខ្វះចន្លោះនៃការបំពេញរបាយការណ៍នៃការបញ្ជូនរបស់មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនដែលនាំឲ្យការសិក្សានៅមិនទាន់បានគ្រប់ជ្រុងជ្រោយទាំងអស់នៅឡើយលើដំណើរការនៃការបញ្ជូននេះ។

សម្រាប់ជាអនុសាសន៍ក្រោយពីបានសិក្សាមកឃើញថាភាពខ្វះចន្លោះមួយចំនួននៃការអនុវត្តនឹងសម្រាប់ជាដំណោះស្រាយគប្បីបង្កើតឲ្យមានការតាមដានការអនុវត្ត និង លើកយកចំណុចដែលខ្វះចន្លោះទាំងអស់នោះមកធ្វើការកែតម្រូវឡើងវិញដោយបង្កើតឲ្យមានការប្រជុំពិភាក្សាលើការងារអនុវត្តច្បាប់ដើម្បីធ្វើយ៉ាងណាឲ្យមាននូវនិយ័តភាពលើការអនុវត្តឲ្យកាន់តែល្អប្រសើរ។

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

ក្រោយពីបានសិក្សានូវជំនាញបរិញ្ញាប័ត្រផ្នែកនីតិសាស្ត្ររយៈពេល០៤ឆ្នាំ មកនេះធ្វើឲ្យយើងខ្ញុំទាំងពីរនាក់ទទួលបានចំណេះដឹងជាច្រើនពី លោក លោកស្រី សាស្ត្រាចារ្យ ដែលលោកតែងតែពន្យល់ណែនាំបង្ហាត់បង្ហាញទាំងផ្នែកទ្រឹស្តី និង ការអនុវត្តនីតិវិធីក្នុងវិស័យច្បាប់ដោយលោកតែងតែលើកយកឧទាហរណ៍ដែលមាននៅក្នុងសង្គមសព្វថ្ងៃមកពន្យល់។ បើយើងសិក្សាក្នុងវិស័យច្បាប់យើងប្រាកដជាដឹងហើយថាគេបែងចែករឿងជាក្តីជាពីរប្រភេទ គឺ រឿងរដ្ឋប្បវេណី និង រឿងព្រហ្មទណ្ឌ។ ហើយក្នុងទ្រឹស្តី និង ដំណើរការអនុវត្តនីតិវិធីក្នុងរឿងក្តីទាំងពីរគឺ មានលក្ខណៈខុសគ្នាស្ទើរតែទាំងស្រុង។ ហើយក្នុងនីតិវិធីមួយដំណាក់កាលៗ សុទ្ធតែត្រូវធ្វើឲ្យត្រូវទៅតាមច្បាប់កំណត់ឆ្លៀតក្នុងឱកាសនេះយើងខ្ញុំទាំងពីរសុំលើកយកប្រធានបទមួយដែលទាក់ទង នឹង ដំណើរការនីតិវិធីរដ្ឋប្បវេណីក្រោមប្រធានបទស្តីពីការ " **ការបញ្ជូនក្នុងនីតិវិធីជំនុំជម្រះលើកទី១**"។ ការបញ្ជូនគឺជាការជូនដំណឹងដែលធ្វើឡើងតាមនីតិវិធីដែលច្បាប់បានកំណត់ដើម្បីជូនដំណឹងអំពីខ្លឹមសារនៃឯកសារតាមផ្លូវបណ្តឹងទៅឲ្យភាគី និង អ្នកដទៃទៀតដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍ក្នុងរឿងក្តីរដ្ឋប្បវេណី។ ផលប្រយោជន៍នៃការបញ្ជូននេះគឺធ្វើយ៉ាងណាឲ្យភាគី និង អ្នកដទៃដែលមានផលប្រយោជន៍ទាំងអស់ទទួលបានដំណឹងអំពីខ្លឹមសារនៃឯកសារតាមផ្លូវបណ្តឹង។

ចំពោះប្រធានបទនៃសារណាស្តីពី"**ការបញ្ជូនក្នុងនីតិវិធីជំនុំជម្រះលើកទី១**" ដែលបានរៀបចំឡើងមកនេះគឺផ្អែកទៅលើបទដ្ឋានគតិយុត្តជាធរមាន និង ការសិក្សាស្វែងយល់ពីការអនុវត្តការងារជាក់ស្តែងដោយបានប្រមូលជាឯកសារផ្សេងៗដែលទាក់ទង និង ដំណើរការនីតិវិធីនៃការបញ្ជូននេះមករៀបចំជាសារណានេះដោយរួមមានលិខិតបទដ្ឋានគតិយុត្តនានា ទម្រង់ឯកសារផ្សេងៗ ដែលពាក់ព័ន្ធ នឹងការបញ្ជូនក្នុងនីតិវិធីជំនុំជម្រះលើកទី១ និង របាយការណ៍អំពីការបញ្ជូន។ សារណាបញ្ចប់សិក្សានេះគឺសិក្សាទៅលើខ្លឹមសារសំខាន់ៗដែលទាក់ទងទៅនឹងដំណើរការនីតិវិធីនៃការបញ្ជូនដូចជាស្ថាប័នដែលធ្វើការបញ្ជូនឯកសារដែលត្រូវធ្វើការបញ្ជូនវិធីនៃការបញ្ជូន ការធ្វើរបាយការណ៍អំពីការបញ្ជូន នឹងរួមទាំងការសិក្សាលើការអនុវត្តច្បាប់ដែលបានអនុវត្តជាក់ស្តែងព្រមទាំងទម្រង់ឯកសារនានាទាក់ទងនឹងកិច្ចការបញ្ជូននេះ។

ការជ្រើសរើសយកនូវប្រធានបទខាងលើនេះមករៀបចំធ្វើជាសារណាបញ្ចប់ការសិក្សាដោយសារតែនីតិវិធីនៃការបញ្ជូនពាក់ព័ន្ធយ៉ាងសំខាន់ នឹងដំណើរការនីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណីដែលជាផលប្រយោជន៍តាមផ្លូវច្បាប់របស់គូភាគី ក្នុងការធានាដល់ការផ្តល់ព័ត៌មានដល់ភាគីដែលពាក់ព័ន្ធអំពីខ្លឹមសារនៃឯកសារតាមផ្លូវច្បាប់ដែលច្បាប់តម្រូវឲ្យត្រូវតែធ្វើ ហើយនីតិវិធីនៃការបញ្ជូន ក៏ពាក់ព័ន្ធដល់តួនាទីរបស់ក្រឡាបញ្ជីនៅក្នុងការអនុវត្តការងារជាចម្បងក្នុងកិច្ចការនីតិវិធីនៃការបញ្ជូននេះផងដែរ។

## ១. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការរៀបចំនូវសារណាបញ្ចប់ការសិក្សានេះគឺដើម្បីធ្វើការសិក្សាលើដំណើរការនីតិវិធីនៃការបញ្ជូនក្នុងរឿងក្តីរដ្ឋប្បវេណីនេះក្នុងការស្វែងយល់ថា៖

១.តើស្ថាប័នណាខ្លះ ដែលមានតួនាទីក្នុងការអនុវត្តកិច្ចការនីតិវិធីនៃការបញ្ជូន?

២.តើការបញ្ជូនត្រូវមាននូវដំណើរការនីតិវិធីយ៉ាងដូចម្តេច?

៣.តើត្រូវរៀបចំនូវរបាយការណ៍អំពីការបញ្ជូនយ៉ាងដូចម្តេចបន្ទាប់ពីបានប្រតិបត្តិការបញ្ជូនរួចហើយ?

## ២. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការជ្រើសរើសប្រធានបទនេះ គឺផ្តោតការយកចិត្តទុកដាក់ទៅលើការបញ្ជូនក្នុងនីតិវិធីជំនុំជម្រះលើកទី១ និងកត្តាមួយចំនួនផ្សេងទៀតដូចខាងក្រោម ៖

- ដើម្បីស្វែងយល់ពីលិខិតបទដ្ឋានគតិយុត្តិ
- ដើម្បីស្វែងយល់ពីលក្ខខណ្ឌនីតិវិធីនៃការបញ្ជូនដែលត្រឹមត្រូវ
- ដើម្បីស្វែងយល់ពីការប្រៀបធៀបទ្រឹស្តី និងការអនុវត្តជាក់ស្តែង
- ដើម្បីស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយរបស់មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន។

## ៣. សារៈសំខាន់នៃការស្រាវជ្រាវ

គឺដើម្បីឲ្យយើងបានយល់ឲ្យកាន់តែច្បាស់អំពីការបញ្ជូនក្នុងនីតិវិធីជំនុំជម្រះលើកទី១ ដោយហេតុថាការបញ្ជូននៅក្នុងនីតិវិធីរដ្ឋប្បវេណី គឺ ជាកិច្ចការដ៏សំខាន់មួយដែលត្រូវតែធ្វើដោយខានពុំបាន។ ហើយជាពិសេសជាងនេះទៅទៀតនោះ គឺ ផ្តល់នូវចំណេះដឹងដល់មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន និងនីតិវិធីនៃការបញ្ជូនឲ្យកាន់យល់កាន់ច្បាស់។ ម្យ៉ាងទៀតដើម្បីបំពេញនូវចំណុចខ្វះខាតដែលកើតមានកន្លងមកក្នុងនីតិវិធីនៃការបញ្ជូនក្នុងរឿងក្តីរដ្ឋប្បវេណី និងផ្តល់សារៈសំខាន់ជាច្រើនទៀតដូចជា៖

**-ផលប្រយោជន៍សម្រាប់អ្នកស្រាវជ្រាវ**

- ដើម្បីឲ្យក្រុមយើងខ្ញុំពង្រឹងនូវចំណេះដឹងដែលបានសិក្សាកន្លងមក។
- ដើម្បីឲ្យក្រុមយើងខ្ញុំសិក្សាពីចំណុចខ្វះខាតដែលកើតមានដើម្បីធ្វើជាគ្រឹះសម្រាប់យកទៅបំពេញចន្លោះខ្វះខាតដែលធ្លាប់កើតមានឲ្យកាន់តែប្រសើរឡើង។
- ដើម្បីសិក្សានិងដកស្រង់នូវបទពិសោធន៍ថ្មីៗនៃផ្នែកទ្រឹស្តីជាមួយនឹងការអនុវត្តជាក់ស្តែង។

**-សារៈប្រយោជន៍សម្រាប់មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនរឿងក្តីរដ្ឋប្បវេណី**

- កាត់បន្ថយភាពខ្វះខាតមួយចំនួនដែលពាក់ព័ន្ធ និងការបញ្ជូនរឿងក្នុងនីតិវិធីជំនុំជម្រះលើកទី១

- បំពេញបន្ថែមនូវចំណុចខ្វះខាតមួយចំនួនដែលកើតមានឡើងក្នុងពេលអនុវត្តការងារជាក់ស្តែងរបស់មន្ត្រីទទួលកិច្ចការបញ្ជូន។

**-សារៈប្រយោជន៍សម្រាប់សង្គម**

- សម្រាប់ទុកជាឯកសារដល់អ្នកសិក្សាជំនាន់ក្រោយៗ និងជាជំនួយស្មារតីនៃការសិក្សាស្រាវជ្រាវ។
- សម្រាប់ទុកជាប្រយោជន៍ដល់អ្នកសិក្សាដែលមានបំណងចង់ប្រឡងចូលបំរើការក្នុងវិស័យតុលាការ។
- ដើម្បីជួយសម្រួលដល់អ្នកអានឲ្យបានដឹង និង សិក្សាស្វែងយល់ពីនីតិវិធីនៃការបញ្ជូនឲ្យកាន់តែយល់ច្បាស់។

## ៤. វិធីសាស្ត្រនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវអំពីប្រធានបទ "**ការបញ្ជូនក្នុងនីតិវិធីជំនុំជម្រះលើកទី១**" ដោយក្រុមយើងខ្ញុំបានលើកយកវិធីសាស្ត្រមួយចំនួនដើម្បីធ្វើការស្វែងយល់ពីចំណុចខ្លះៗ។ ដើម្បីទទួលបាននូវភាពងាយស្រួលក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះយើងខ្ញុំបានចែកចេញជាពីរផ្នែកគឺ វិធីសាស្ត្រប្រមូលទិន្នន័យ និង វិធីសាស្ត្រវិភាគទិន្នន័យ។

### ៤.១. វិធីសាស្ត្រប្រមូលទិន្នន័យ

នៅក្នុងវិធីសាស្ត្រប្រមូលទិន្នន័យនេះ ក្រុមយើងខ្ញុំបានលើកយកទិន្នន័យពីរ មកសិក្សាបន្ថែមទៀតគឺ ទិន្នន័យចម្បង និង ទិន្នន័យបន្ទាប់បន្សំ។

**ក. ទិន្នន័យចម្បង**

- ការចុះកម្មសិក្សាអនុវត្តការងារដោយផ្ទាល់នៅស្ថាប័នសាលាដំបូង និង អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។
- ធ្វើការសម្ភាស៍ដោយផ្ទាល់ជាមួយ ចៅក្រម ក្រឡាបញ្ជី និង មន្ត្រីអាជ្ញាសាលា នៅសាលាដំបូង និង អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។
- ការណែនាំពីសាស្ត្រាចារ្យដឹកនាំសារណា។

**ខ. ទិន្នន័យបន្ទាប់បន្សំ**

- រាល់ឯកសារទាំងឡាយត្រូវបានផ្តល់ដោយ ចៅក្រម ក្រឡាបញ្ជី អាជ្ញាសាលា និង មន្ត្រីរដ្ឋបាលនៅលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូង និង អយ្យការអមសាលាដំបូងខេត្តព្រះ សីហនុ។
- ដំណើរការនីតិវិធីនៃការអនុវត្តន៍ច្បាប់ជាក់ស្តែង។
- ឯកសារទទួលបានការស្រាវជ្រាវពីបណ្ណាល័យរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។

- ឯកសារដែលទាក់ទងនឹងរំលឹកទ្រឹស្តីទទួលបានពីលោកគ្រូដឹកនាំសារណា។
- ក្រមនីតិវិធីរដ្ឋប្បវេណី ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះ ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

## ៤.២. វិធីសាស្ត្រវិភាគទិន្នន័យ

ក្រោយពីការប្រមូលទិន្នន័យ តាមការចុះកម្មសិក្សាអនុវត្តការងារដោយផ្ទាល់នៅ ស្ថាប័នសាលាដំបូង និង អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ តម្រូវឲ្យយើងយកទិន្នន័យមកវិភាគ និង ចងក្រងទុកជាខ្លឹមសារនឹងត្រូវបានយកមកធ្វើការវិភាគយ៉ាងល្អិតល្អន់ដោយផ្អែកតាមច្បាប់ និង បែបបទគតិយុត្តលើសពីនេះទៅទៀតក្នុងការវិភាគទិន្នន័យក្រុមយើងខ្ញុំក៏បានវិភាគទៅលើការអនុវត្តន៍ជាក់ស្តែងផងដែរ។ ក្នុងការសិក្សាលើប្រធានបទនេះ វាបានផ្តល់សារៈសំខាន់ណាស់ដល់ការងារទូទៅនាថ្ងៃអនាគត និង ធ្វើឲ្យយើងយល់កាន់តែច្បាស់នូវគោលការណ៍ច្បាប់ និងនីតិវិធីផ្សេងៗក្នុងដំណាក់កាលនីមួយៗដែលបានប្រតិបត្តិនៅក្នុងស្ថាប័នសាលាដំបូង និង អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ ហើយអ្វីដែលសំខាន់នោះគឺទទួលបទពិសោធន៍នូវចំណេះដឹង និង កាន់តែមានភាពច្បាស់លាស់ជាងមុនថែមទៀតដូច្នេះហើយការចុះកម្មសិក្សាក្នុងការអនុវត្តជាក់ស្តែងនេះ គឺ ដើម្បីស្រាវជ្រាវបន្ថែមនៅក្នុងស្ថាប័នផ្ទាល់ និង ឈានទៅកាន់ភាពជោគជ័យនាពេលខាងមុខដូចជា៖

- ដើម្បីផ្សាភ្ជាប់ការសិក្សាទ្រឹស្តី និងការអនុវត្តការងារជាក់ស្តែង
- ទទួលបាននូវចំណេះដឹងផ្អែកក្រមនីតិវិធីព្រហ្មទណ្ឌ និង បរិបទនានារបស់សង្គមនាពេលបច្ចុប្បន្ននេះ
- បានយល់កាន់តែច្បាស់នូវនីតិវិធីនៃការអនុវត្តន៍ច្បាប់នៅសាលាដំបូង និង អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ
- ស្វែងយល់បន្ថែមលើសពីអ្វីដែលលោកគ្រូបានបង្ហាត់បង្រៀន
- អាចទទួលបាននូវចំណេះដឹងយ៉ាងច្រើនសន្ធឹកសន្ធាប់ក្នុងពេលសរសេរសារណា
- ឯកសារដែលពាក់ព័ន្ធនឹងគំនិតថ្មីៗ
- ការទទួលបាននូវកម្រងឯកសាររបាយការណ៍មួយប្រកបដោយភាពល្អប្រសើរ
- ផ្តល់ជាឯកសារសម្រាប់និស្សិត និង អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយៗទៀត

ដូចនេះចំពោះសារណានេះមានវិសាលភាពនៃការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី **“ការបញ្ជូនក្នុងនីតិវិធីជំនុំជម្រះលើកទី១”** នៅក្នុងរឿងរដ្ឋប្បវេណីតែប៉ុណ្ណោះគឺធ្វើការបកស្រាយតាមរយៈការអនុវត្តការងារជាក់ស្តែងនៅពេលចុះកម្មសិក្សានឹងទាញយកខ្លឹមសារសំខាន់ៗនៃលិខិតបទដ្ឋានគតិយុត្តជាពិសេសសម្ភាសន៍ផ្ទាល់ពីលោកគ្រូណែនាំពាក់ព័ន្ធនឹងប្រធានបទខាងលើនេះ។

## ៥. ក្របខ័ណ្ឌ នៃការស្រាវជ្រាវ

**សេចក្តីផ្តើម**

**ជំពូកទី១**
**សញ្ញាណទូទៅនៃការបញ្ជូន**

១. សញ្ញាណទូទៅនៃការបញ្ជូន
២. វិធីនៃការបញ្ជូន និងរបាយការណ៍នៃការបញ្ជូន

**ជំពូកទី២**
**ការរកឃើញលើការអនុវត្តជាក់ស្តែង ឬ ការពិពណ៌នាអំពីការងារ**

១. មន្ត្រីដែលធ្វើការបញ្ជូនក្នុងការអនុវត្តជាក់ស្តែង
២. វិធីបញ្ជូនក្នុងការអនុវត្តជាក់ស្តែង
៣. របាយការណ៍អំពីការបញ្ជូន

**ជំពូកទី៣**
**ការវិភាគប្រៀបធៀបរវាងការអនុវត្តជាក់ស្តែងដែលរកឃើញជាមួយទ្រឹស្តីច្បាប់គតិយុត្តិ**

១.ភាពត្រឹមត្រូវក្នុងការអនុវត្តច្បាប់ក្នុងនីតិវិធីបញ្ជូន

២.នីតិវិធីនៃការបញ្ជូនដែលមិនទាន់បានអនុវត្ត និង ចំណុចខ្វះខាតក្នុងការអនុវត្ត

**សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**

# ជំពូកទី១

# ការសិក្សាលើលិខិតតូបករណ៍គតិយុត្ត និងទ្រឹស្តីច្បាប់ដែលពាក់ព័ន្ធ

# ជំពូកទី១

# ការសិក្សាលើលិខិតតូបករណ៍គតិយុត្ត និងទ្រឹស្តីច្បាប់ដែលពាក់ព័ន្ធ

នៅក្នុងជំពូកទី១ នៃការសិក្សាលើលិខិតូបករណ៍គតិយុត្ត និង ទ្រឹស្តីច្បាប់ដែលពាក់ព័ន្ធគឺជាការលើកយកនូវខ្លឹមសារដែលទាក់ទងទៅ នឹង ទ្រឹស្តីច្បាប់ផ្អែកទៅលើបទដ្ឋានគតិយុត្តជាធរមានដែលសិក្សាពាក់ព័ន្ធទៅលើប្រធានបទនៃសារណា គឺ **ការបញ្ជូនក្នុងនីតិវិធីជំនុំជម្រះលើកទី១** មកធ្វើការសិក្សាឲ្យបានច្បាស់មុន នឹងធ្វើការសិក្សាទៅលើការអនុវត្តច្បាប់ក្នុងការងារជាក់ស្តែងនៅសាលាដំបូងខេត្តព្រះសីហនុ។ ដើម្បីធ្វើការសិក្សាក្នុងផ្នែកនេះឲ្យបានច្បាស់ គឺត្រូវបែងចែកជា **២ (ពីរ)** ចំណុចរួមមាន **ចំណុចទី១** សិក្សាអំពី **សញ្ញាណទូទៅនៃការបញ្ជូន** ដោយត្រូវសិក្សាស្វែងយល់ពីអត្ថន័យនៃការបញ្ជូន, ស្ថាប័នដែលធ្វើការបញ្ជូន និងឯកសារនៃការបញ្ជូន។ **ចំណុចទី២** ដែលត្រូវសិក្សាអំពី **វិធីនៃការបញ្ជូននិងរបាយការណ៍នៃការបញ្ជូន។** នៅក្នុងខ្លឹមសារដែលបានធ្វើការបែងចែកនេះ គឺត្រូវផ្អែកទៅលើមូលដ្ឋាននៃទ្រឹស្តីច្បាប់ និង បទដ្ឋានគតិយុត្តជាធរមានដែលពាក់ព័ន្ធទៅនឹងចំណុចសំខាន់ៗ ស្របតាមផ្នែកនីមួយៗ ដែលបានបែងចែកមកនេះត្រូវធ្វើការសិក្សាដូចខាងក្រោមៈ

## ១. សញ្ញាណទូទៅនៃការបញ្ជូន

### ១.១. និយមន័យ

**ការបញ្ជូន** គឺជាការជូនដំណឹងដែលធ្វើឡើងតាមវិធីដែលច្បាប់បានកំណត់ដើម្បីជូនដំណឹងអំពីខ្លឹមសារនៃឯកសារតាមផ្លូវបណ្តឹងចំពោះភាគី និង អ្នកដទៃទៀតដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍។ **ការទទួលនូវការបញ្ជូន** គឺជាការដាក់ខ្លួនក្រោមសិទ្ធិជម្រះក្តីរបស់តុលាការ។ ហេតុនេះហើយការធ្វើការបញ្ជូនចំពោះជនដែលមិនស្ថិតនៅក្រោមសិទ្ធិ ជម្រះក្តីរបស់តុលាការកម្ពុជាមិនអាចធ្វើបានទេលើកលែងតែក្នុងករណីដែលជននោះយល់ព្រមទទួលការបញ្ជូនដោយស្ម័គ្រចិត្ត។[1] ចំពោះវិធីនៃការបញ្ជូនមានការបែងចែកខុសពីការជូនដំណឹងធម្មតាវិធីនៃការជូនដំណឹងគឺមានលក្ខណៈទូលំទូលាយ និង ងាយស្រួលជាងវិធីនៃការបញ្ជូនដោយអ្នកប្រតិបត្តិការបញ្ជូនអាចប្រើគ្រប់មធ្យោបាយដើម្បីឲ្យអ្នកទទួលការបញ្ជូនបានដឹង។ នីតិវិធីនៃការបញ្ជូនក៏ជាផ្នែកមួយនៃការជូនដំណឹងផងដែរ។ ការប្រតិបត្តិការបញ្ជូនត្រូវធ្វើឡើងដោយមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនជាអ្នកអនុវត្តការអនុវត្តត្រូវតែធ្វើតាមនីតិវិធីដែលច្បាប់កំណត់ដើម្បីធ្វើការជូនដំណឹងអំពីខ្លឹមសារនៃឯកសារតាមផ្លូវបណ្តឹងដល់ភាគី និង អ្នកដទៃទៀតដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍ឲ្យបានត្រឹមត្រូវ

[1] សៀវភៅសេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគទី១៖នីតិវិធីបណ្តឹង ទំព័រទី១១៧

ទៅតាមនីតិវិធីច្បាប់។ ការអនុវត្តនីតិវិធីនៃការបញ្ជូន គឺមានលក្ខណៈមិនទូលំទូលាយដូចជាការជូនដំណឹង ធម្មតាទេគឺមានលក្ខណៈខុសគ្នាត្រង់ចំណុចស្តីពីវិធី ឬ អានុភាពជាអាទិ៍។

## ១.២. មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន

ស្ថាប័នដែលធ្វើការបញ្ជូនមានការបែងចែកជា **២ (ពីរ)** រួមមាន៖ មន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការ បញ្ជូន និងមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន។[2]

### ១.២.១. មន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូន

មន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូនគឺ **មន្ត្រីក្រឡាបញ្ជី**។[3] មុខងារមន្ត្រីរដ្ឋបាលទទួលបន្ទុក កិច្ចការបញ្ជូន គឺការធ្វើឬការផ្តល់សេចក្តីបញ្ជាក់នូវឯកសារសម្រាប់ប្រើក្នុងការបញ្ជូនហើយប្រគល់អំណាច នៃការបញ្ជូនឯកសារនោះ ទៅឲ្យមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន ហើយបន្ទាប់មកទទួលរបាយការណ៍នៃ ការបញ្ជូនពីមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន និង ធ្វើការរក្សារបាយការណ៍នោះជាមួយ នឹងសំណុំរឿង ដោយរៀបចំទុកដាក់ឲ្យបានត្រឹមត្រូវទៅតាមកាលបរិច្ឆេទនៃលំដាប់ឯកសារជាដើម។[4]

### ១.២.២. មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន

មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនរួមមាន **បុគ្គលិកប្រៃសណីយ៍ អាជ្ញាសាលា និងក្រឡាបញ្ជី**។[5] ក្នុងចំណោមមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនមន្ត្រីដែលជាអាជ្ញាសាលា ដែលមានតួនាទីប្រតិបត្តិការបញ្ជូន នៅមានចំនួនតិចហើយការងាររបស់គាត់មានច្រើនពាក់ព័ន្ធនឹងការអនុវត្តរក្សាការពារ និង ការអនុវត្តដោយ បង្ខំនៅសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ ទើបមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនពុំ បានប្រគល់ការងារជាមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនឲ្យទៅអាជ្ញាសាលាជាអ្នកបញ្ជូនឡើយ។ មុខងារ របស់មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនគឺត្រូវបញ្ជូននូវឯកសារដែលត្រូវធ្វើការបញ្ជូនទៅជនដែលត្រូវទទួល ការបញ្ជូន និង ធ្វើរបាយការណ៍អំពីការបញ្ជូនហើយដាក់របាយការណ៍នោះទៅតុលាការ។[6]

## ១.៣. ឯកសារដែលត្រូវធ្វើការបញ្ជូន

**ការបញ្ជូន** គឺត្រូវធ្វើទៅតាមឯកសារតាមផ្លូវច្បាប់មួយចំនួនដែលតម្រូវឲ្យឆ្លងកាត់នូវនីតិវិធីនៃការ បញ្ជូន។ **ឯកសារដែលត្រូវធ្វើការបញ្ជូន** គឺជាឯកសារចម្លងទាំងអស់ដែលពាក់ព័ន្ធលើកលែងតែមានករណី

---

[2] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៤៦

[3] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៤៦ កថាខណ្ឌទី២

[4] សៀវភៅសេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគទី១៖នីតិវិធីបណ្តឹង ទំព័រទី១១៧ ដល់ទំព័រទី១១៨

[5] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៤៦ កថាខណ្ឌទី២

[6] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៥៤

ដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់។[7] ឯកសារដែលច្បាប់កំណត់តម្រូវឲ្យធ្វើនីតិវិធីនៃការបញ្ជូនមានដូចជា **ពាក្យបណ្តឹង** នៅពេលដែលដើមចោទដាក់នូវបណ្តឹងរបស់ខ្លួនជាលាយលក្ខណ៍អក្សរមកតុលាការតាមការប្រគល់ពាក្យបណ្តឹង ដើម្បីឲ្យតុលាការសម្រេចលើការទាមទាររបស់ខ្លួន **ចៅក្រម** ដែលទទួលបន្ទុកត្រូវពិនិត្យមើលភាពស្របឬមិនស្របនឹងលក្ខខណ្ឌទម្រង់នៃ**ពាក្យបណ្តឹង**។[8] នៅពេលដែលពាក្យបណ្តឹងត្រូវបានពិនិត្យថាមានភាពត្រឹមត្រូវតាមលក្ខខណ្ឌទម្រង់តាមផ្លូវច្បាប់រួចហើយ **ពាក្យបណ្តឹង** ត្រូវបញ្ជូនទៅចុងចម្លើយជាចាំបាច់។[9] **ដីកាសម្រេចបង្គាប់ឲ្យកែតម្រូវចំណុចខ្វះខាតចំពោះពាក្យបណ្តឹង**[10] និង **ដីកាសម្រេចបង្គាប់ឲ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ**[11] ដោយក្នុងមាត្រា ៧៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងអំពីការអនុវត្តដូចគ្នានៃការបញ្ជូនពាក្យបណ្តឹង។ **ពាក្យសុំបន្ថែម ឬ ផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង** ដែលដើមចោទបានធ្វើការស្នើសុំការបន្ថែម ឬ ផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹងជាលាយលក្ខណ៍អក្សរឯកសារ នេះត្រូវបញ្ជូនទៅភាគីម្ខាងទៀត។[12] **អនុសារសាលក្រម** នៅពេលដែលតុលាការធ្វើការប្រកាសសាលក្រមក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគតិចាប់ពីថ្ងៃប្រកាសសាលក្រមត្រូវធ្វើការបញ្ជូន **អនុសារសាលក្រម** ទៅឲ្យគូភាគី។[13] អនុសារសាលក្រមគឺជាសេចក្តីសម្រេចចម្លងពី **មូលសាលក្រម (សាលក្រមដើម)** ដែលគ្មាន បញ្ជាក់រូបមន្តអនុវត្ត។ **ពាក្យបណ្តឹងទាស់** ដែលតុលាការពិនិត្យឃើញថាគ្មានខ្វះខាតទេតុលាការត្រូវបញ្ជូនពាក្យបណ្តឹងទាស់នោះទៅភាគីម្ខាងទៀត។[14] **ការដកពាក្យបណ្តឹង** ដើមចោទអាចដកពាក្យបណ្តឹងទាំងអស់ ឬ មួយផ្នែកបានរហូតដល់ពេលដែលសាលក្រមចូលជាស្ថាពរ។ ការដកពាក្យបណ្តឹងអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ និង ដោយផ្ទាល់មាត់។ លិខិតដកពាក្យបណ្តឹងដែលដើមចោទដាក់ជូនតុលាការអំពីការ **ដកពាក្យបណ្តឹង** តុលាការត្រូវបញ្ជូនលិខិតនេះទៅចុងចម្លើយ។ ការដកពាក្យបណ្តឹងដោយផ្ទាល់មាត់នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ កាលបរិច្ឆេទនៃការផ្សះផ្សាករណីចុងចម្លើយមិនបានចូលរួមនៅក្នុងកាលបរិច្ឆេទនោះតុលាការត្រូវបញ្ជូនឯកសារចម្លងនៃកំណត់ហេតុនៃកាលបរិច្ឆេទនេះទៅចុងចម្លើយ។[15] **ដីកាកោះ** ចំពោះកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការ

[7] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៥៥

[8] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៧៩

[9] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៧៨

[10] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៧៨

[11] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៦២

[12] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៨៤

[13] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា១៩០

[14] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២០៦

[15] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៤២

ទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ការកោះហៅតាមកាលបរិច្ឆេទត្រូវធ្វើដោយការបញ្ជូនដីកាកោះ។[16]

# ២. វិធីនៃការបញ្ជូន និងរបាយការណ៍នៃការបញ្ជូន

## ២.១. វិធីនៃការបញ្ជូន និងការបញ្ជូនទៅអសមត្ថជនក្នុងបណ្តឹង

**ការបញ្ជូន** គឺត្រូវធ្វើឡើងតាមវិធីដែលមានលក្ខខណ្ឌចែងនៅក្នុងបញ្ញត្តិច្បាប់ជាធរមានដែលមានការកំណត់យ៉ាងជាក់លាក់ដើម្បីឲ្យធ្វើនីតិវិធីនៃការបញ្ជូន។ មន្ត្រីដែលធ្វើកិច្ចការបញ្ជូននៅពេលដែលធ្វើការប្រតិបត្តិការបញ្ជូនស្របតាមនីតិវិធីរួចហើយត្រូវរៀបចំធ្វើជារបាយការណ៍អំពីការបញ្ជូនថាតើមានវិធីនៃការបញ្ជូន និងការរៀបចំរបាយការណ៍មានលក្ខណៈតាមច្បាប់កំណត់យ៉ាងដូចម្តេច? ត្រូវធ្វើការសិក្សានៅក្នុងលក្ខខណ្ឌដែលច្បាប់កំណត់ដូចខាងក្រោម៖

### ២.១.១. វិធីនៃការបញ្ជូន

វិធីនៃការបញ្ជូនមាន៦(ប្រាំមួយ) ប្រភេទដែលត្រូវសិក្សាលើខ្លឹមសារ និងលក្ខខណ្ឌដូចខាងក្រោម៖

១.ការបញ្ជូនដោយការប្រគល់

២.ការបញ្ជូនដោយការជួបប្រទះ

៣.ការបញ្ជូនបង្គ្រប់កិច្ច

៤.ការបញ្ជូនដោយទុកចោល

៥.ការបញ្ជូនដែលត្រូវធ្វើនៅបរទេស

៦.ការបញ្ជូនតាមការផ្សាយចាសាធារណៈ ។

#### ២.១.១.១. ការបញ្ជូនដោយការប្រគល់

ការបញ្ជូនដោយការប្រគល់ ជាគោលការណ៍ត្រូវធ្វើឡើងដោយការប្រគល់នូវឯកសារដែលត្រូវបញ្ជូនទៅជនដែលត្រូវទទួលការបញ្ជូននោះលើកលែងតែមានករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ដូចជាបញ្ញត្តិនៃមាត្រា២៤៨ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងថាការបញ្ជូនទៅអ្នកជាប់ពន្ធនាគារត្រូវធ្វើទៅចំពោះប្រធានពន្ធនាគារ។[17] កន្លែងដែលត្រូវបញ្ជូនត្រូវធ្វើទៅលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការរបស់ជនដែលត្រូវទទួលការបញ្ជូន។ ប៉ុន្តែចំពោះការបញ្ជូនទៅអ្នកតំណាងដែលច្បាប់បាន

[16] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៤២

[17] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៤៨

កំណត់វិញអាចធ្វើការបញ្ជូនទៅទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការរបស់សាមីខ្លួនបាន។ ការបញ្ជូនតាមការជូនដំណឹងអំពីកន្លែងបញ្ជូនពីភាគី ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ អាចជូនដំណឹងអំពីកន្លែងដែលខ្លួនត្រូវទទួលការបញ្ជូននៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬអ្នកដែលទទួលការបញ្ជូនទៅតុលាការទទួលបណ្តឹង។ ភាគីឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដោយអាណត្តិ អាចជូនដំណឹង ដើម្បីផ្លាស់ប្តូរកន្លែងដែលបានជូនដំណឹងថា ជាកន្លែងដែលខ្លួនត្រូវទទួលការបញ្ជូន ឬ អ្នកដែលបានជូនដំណឹងថាជាអ្នកទទួលការបញ្ជូននោះបាន។ ការជូនដំណឹងនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ។[18]

### ២.១.១.២. ការបញ្ជូនដោយការជួបប្រទះ

ការបញ្ជូនដោយការជួបប្រទះ គឺធ្វើឡើងក្នុងករណីប្រសិនបើជនដែលត្រូវទទួលការបញ្ជូននោះពុំច្បាស់ថាមាន លំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេការបញ្ជូនអាចធ្វើបាននៅកន្លែងដែលបានជួបប្រទះជននោះ។ លើកលែងតែក្នុងករណីដែលមានការជូនដំណឹងអំពីទីកន្លែងដែលត្រូវធ្វើការបញ្ជូនរបស់ភាគី ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកតំណាងដោយអាណត្តិតាមបញ្ញត្តិមាត្រា២៥០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ម្យ៉ាងទៀតទោះបីជាបានដឹងច្បាស់លាស់អំពីលំនៅឋាន ទីសំណាក់ ទីកន្លែង អាជីវកម្ម ឬទីស្នាក់ការនៅក្នុងព្រះរាជណាចក្រកម្ពុជា ឬក៏មានការជូនដំណឹង អំពីទីកន្លែងដែលត្រូវបញ្ជូនក៏ដោយក៏អាចធ្វើការបញ្ជូននៅទីកន្លែងដែលបានជួបប្រទះជននោះបានដែរប្រសិនបើជនដែលទទួលការបញ្ជូននោះមិនប្រកែកចំពោះការទទួលការបញ្ជូនទេ។[19]

**ឧទាហរណ៍៖** ទូរស័ព្ទហៅភាគីមកតុលាការ ឬណាត់ជួបនៅកន្លែងណាមួយក្រៅពីលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការហើយប្រគល់ឯកសារនៃការបញ្ជូន ដោយមានការយល់ព្រមពីអ្នកទទួលការបញ្ជូននោះ។

### ២.១.១.៣. ការបញ្ជូនបង្គ្រប់កិច្ច

ការបញ្ជូនដោយបង្គ្រប់កិច្ច គឺធ្វើឡើងក្នុងករណីប្រសិនបើការបញ្ជូនទៅទីកន្លែងដែលត្រូវបញ្ជូនដូចជាលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការរបស់ជនដែលត្រូវទទួលការបញ្ជូន ហើយពុំបានជួបជននោះនៅទីកន្លែងដែលធ្វើការបញ្ជូន ប៉ុន្តែបានជួបអ្នកបម្រើ ឬ អ្នកផ្សេងដែលធ្វើការនៅទីនោះ ឬ អ្នកនៅជាមួយដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារ។ មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនអាច

[18] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៥១

[19] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៥១

ប្រគល់ឯកសារនោះបាន។[20] អ្នកដែលមានការយល់ដឹងក្នុងការទទួលឯកសារ គឺជាអ្នកដែលយល់ច្បាស់អំពីសារៈសំខាន់នៃការបញ្ជូន ឬ យល់នូវលក្ខណៈនៃឯកសារដែលបានទទួលហើយអាចរំពឹងថាអ្នកនោះមានប្រាជ្ញា នឹងយកឯកសារនោះទៅឲ្យជនដែលត្រូវទទួលការបញ្ជូនបានដោយមិនចាំបាច់ជានីតិជន (មនុស្សពេញវ័យ) ទេ។

**២.១.១.៤. ការបញ្ជូនដោយទុកចោល**

ការបញ្ជូនដោយទុកចោល គឺធ្វើឡើងក្នុងករណីប្រសិនបើជនដែលត្រូវទទួលការបញ្ជូន ឬ អ្នកដែលត្រូវទទួលការប្រគល់ឯកសារដូចជាអ្នកបម្រើ ឬអ្នកផ្សេងដែលធ្វើការនៅទីនោះ ឬ អ្នកនៅជាមួយដែលមានការយល់ដឹងសមរម្យ ដែលអាចទទួលការបញ្ជូនបានប៉ុន្តែជននោះមិនព្រមទទួលការបញ្ជូនដោយគ្មានមូលហេតុត្រឹមត្រូវឯកសារដែលត្រូវធ្វើការបញ្ជូននោះអាចទុកនៅកន្លែងដែលត្រូវបញ្ជូននោះបាន។[21]

**២.១.១.៥. ការបញ្ជូនដែលត្រូវធ្វើនៅបរទេស**

ការបញ្ជូននៅបរទេស គឺធ្វើឡើងក្នុងករណីជនដែលត្រូវទទួលការបញ្ជូន មិនមានលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលអាចធ្វើការបញ្ជូនដោយជនដែលទទួលការបញ្ជូននោះ មានអាសយដ្ឋាននៅបរទេស នីតិវិធីនៃការបញ្ជូននៅបរទេសនេះតាមរបៀបនៃការបញ្ជូននៅបរទេសដោយធ្វើឡើងមាន **២ (ពីរ)** របៀប ។

**របៀបទី១**-ការបញ្ជូនចំពោះជនបរទេសដែលនៅបរទេសគឺអាចប្រគល់ទៅឲ្យក្រសួង ឬ ស្ថាប័នដែលមានសមត្ថកិច្ចនៃប្រទេសនោះ។

**របៀបទី២**-ការបញ្ជូនចំពោះអនិកជនខ្មែរនៅបរទេស គឺអាចបញ្ជូនដោយឯកអគ្គរាជទូតភារធារី ឬ កុងស៊ុលរបស់ព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនោះឲ្យធ្វើបាន។ នីតិវិធីនៃការបញ្ជូននេះដែលត្រូវធ្វើឡើងដោយ ចៅក្រមទទួលបញ្ជា ឬចៅក្រម ដែលទទួលការប្រគល់សិទ្ធិដោយអាចប្រគល់កិច្ចការបញ្ជូននេះឲ្យស្ថាប័នដែលមានសមត្ថកិច្ចនេះបាន។ នីតិវិធីនៃការបញ្ជូនចំពោះបុគ្គល ដែលនៅបរទេសនេះអាចធ្វើតាមសន្ធិសញ្ញា ឬ អនុសញ្ញារវាងប្រទេសនោះ និង ប្រទេសកម្ពុជា ឬ កិច្ចព្រមព្រៀងផ្សេងៗ ឬ តាមការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ដោយផ្អែកទៅលើទំនៀមទម្លាប់។[22] ចំពោះជនបរទេសដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាវិញត្រូវធ្វើតាមនីតិវិធីនៃការបញ្ជូនដូចការបញ្ជូនឲ្យជនជាតិកម្ពុជាដែរ។

---

[20] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៥២ កថាខណ្ឌទី១

[21] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៥២ កថាខណ្ឌទី២

[22] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៥៣

### ២.១.១.៦. ការបញ្ជូនតាមការផ្សាយជាសាធារណៈ

ការបញ្ជូនតាមការផ្សាយជាសាធារណៈ គឺជារបបមួយចាំបាច់ដើម្បីឲ្យដើមចោទអាចធ្វើបណ្តឹងបានបើទោះបីជាមិនដឹងលំនៅឋានជាអាទិ៍ របស់ចុងចម្លើយហើយមិនអាចធ្វើការបញ្ជូនតាមវិធីធម្មតាក៏ដោយ។ ប៉ុន្តែចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈ ត្រូវធ្វើឡើងដោយផ្អែកទៅតាមរបៀបនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ ដោយហេតុថាតាមការពិត មានការពិបាករំពឹងឲ្យជនដែលត្រូវទទួលការបញ្ជូននោះអាចដឹងបាន។ ម្លោះហើយប្រព័ន្ធនេះមានគ្រោះថ្នាក់បន្តិចប្រសិនបើ ដើមចោទ ប្រើប្រព័ន្ធនេះដើម្បីបង្កឲ្យមានអំពើខិលខូចកើតឡើងតុលាការត្រូវធ្វើការពិនិត្យទៅលើលក្ខខណ្ឌធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈនេះដូចជាត្រូវដឹងពីអាសយដ្ឋានភាគីជាដើមចោទឲ្យបានត្រឹមត្រូវ។ ខាងក្រោមនេះគឺជាការបកស្រាយទៅលើការពិនិត្យអំពីដំណើរការនីតិវិធីនៃកាបញ្ជូនផ្សេងៗជាមុនសិនដែលជាលក្ខខណ្ឌចាំបាច់មុននឹងធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបានដោយលើកយកអំពីលក្ខខណ្ឌ និងរបៀបនៃការបញ្ជូនតាមការផ្សាយជាសាធារណៈមកធ្វើការសិក្សាឲ្យបានច្បាស់លាស់។

#### ក. លក្ខខណ្ឌនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ

ដើម្បីធ្វើនីតិវិធីនៃការបញ្ជូន តាមការផ្សាយជាសារធារណៈបានមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន គឺ **ក្រឡាបញ្ជី** ត្រូវធ្វើការពិនិត្យទៅលើលក្ខខណ្ឌកំណត់ដោយច្បាប់ ដើម្បីអាចប្រើប្រាស់វិធីនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ បានដោយអាចធ្វើឡើងតាមរយៈ តាមពាក្យសុំដោយទទួលការអនុញ្ញាតពីតុលាការបានដោយផ្អែកទៅលើករណីនៃលក្ខខណ្ឌដូចខាងក្រោម៖

- ទោះបីបានខំប្រឹងប្រែងធ្វើការស្រាវជ្រាវរកលំនៅឋាន ឬទីសំណាក់របស់ភាគី ឬកន្លែងផ្សេងទៀតដែលត្រូវធ្វើការបញ្ជូនក៏ដោយ ក៏នៅតែរកមិនឃើញអំពីអាសយដ្ឋាននេះ។
- ទោះបីជាស្គាល់អំពីអាសយដ្ឋានរបស់បុគ្គលដែលទទួលការបញ្ជូន ក៏ដោយតែមិនអាចធ្វើការបញ្ជូនតាមវិធីនៃការបញ្ជូនដោយបង្គ្រប់កិច្ច ឬការបញ្ជូនដោយទុកចោលបាន។ ប៉ុន្តែ **ក្រឡាបញ្ជី** គប្បីជូនដំណឹងដោយរបៀបសមរម្យមួយអំពីហេតុការណ៍ដែលបានធ្វើ **ការបញ្ជូន** តាមការផ្សាយជា សាធារណៈទៅភាគីដែលត្រូវទទួលការបញ្ជូននោះ។
- បើជនដែលត្រូវទទួលការបញ្ជូននៅបរទេសការបញ្ជូនមិនអាចធ្វើទៅបាន ឬ ទទួលស្គាល់ថាគ្មានលទ្ធភាពនឹងធ្វើបាន។ **ឧទាហរណ៍**៖ ករណីដែលមិនបានដឹងច្បាស់ថាបុគ្គលដែលទទួលការបញ្ជូនស្ថិតនៅ

ក្នុងប្រទេសណាមួយ ឬ គ្មានទំនាក់ទំនងការទូតចំពោះរដ្ឋបរទេសណាមួយនោះដែលមិនអាចធ្វើការបញ្ជូនបាន។ ការបញ្ជូនដោយត្រឹមត្រូវនៅបរទេសដោយបានធ្វើការប្រគល់ឲ្យទៅក្រសួង ឬ ស្ថាប័នដែលមានសមត្ថកិច្ចនៅបរទេសរួចហើយតែមិនបានទទួលលិខិតបញ្ជាក់អំពីការបញ្ជូននោះក្នុង អំឡុងពេល **៦ (ប្រាំមួយ) ខែ** ចាប់តាំងពីពេលបញ្ជូននោះ។

**ក្រឡាបញ្ជី** ក៏អាចធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ បានដែរដោយការបង្គាប់ពីតុលាការដោយតុលាការអាចប្រើ **ឆន្ទានុសិទ្ធិ** របស់ខ្លួនក្នុងករណីបើយល់ឃើញថាចាំបាច់ដើម្បីជៀសវាងការយឺតយ៉ាវក្នុងដំណើរការនីតិវិធីទោះបីជាគ្មានពាក្យសុំក៏ដោយ ។

**ការបញ្ជូនជាលើកទី២** តាមការផ្សាយជាសាធារណៈចំពោះភាគីដដែលត្រូវធ្វើដោយ **ឆន្ទានុសិទ្ធិ** លើកលែងតែក្នុងករណីនៃការបញ្ជូននៅបរទេសដែលមិនអាចធ្វើការបញ្ជូនបាន ឬ ទទួលស្គាល់ថាគ្មានលទ្ធភាពនឹងធ្វើបានត្រូវតែមានពាក្យសុំមកតុលាការដើម្បីឲ្យតុលាការអាចធ្វើការបញ្ជូនតាមវិធីតាមការផ្សាយជាសាធារណៈជាលើកទី២បាន។[23]

### ខ. របៀបបញ្ជូនតាមការផ្សាយជាសាធារណៈ

របៀបបញ្ជូនតាមការផ្សាយជាសារធារណៈ អាចត្រូវធ្វើតាមរបៀបនៃការបិទប្រកាស ដូចជាត្រូវបិទប្រកាសនៅកន្លែងសម្រាប់បិទប្រកាសរបស់តុលាការដោយ **ក្រឡាបញ្ជី** រក្សាទុកនូវឯកសារដែលត្រូវបញ្ជូន និងអាចប្រគល់ឯកសារនោះទៅជនដែលទទួលការបញ្ជូននៅពេលណាក៏បានប៉ុន្តែការបញ្ជូនដីកាកោះ តាមការផ្សាយជាសាធារណៈវិញត្រូវបិទដីកានោះនៅកន្លែងសម្រាប់បិទប្រកាស។ ចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈមិនអាចធ្វើការបញ្ជូនដោយបង្គ្រប់កិច្ច និង ការបញ្ជូនដោយទុកចោលការបិទប្រកាសអាចធ្វើបាននៅកន្លែងដែលតុលាការយល់ឃើញថាសមរម្យដូចជា នៅប៉ុស្តិ៍នគរបាល ឬ សាលាឃុំ ជាដើមដោយក្រៅពីកន្លែងសម្រាប់បិទប្រកាសរបស់តុលាការ។ តុលាការអាចចុះនៅក្នុងរាជកិច្ច ឬ ក្នុងសារព័ត៌មានផ្សាយថាបានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈហើយ។ ចំពោះការបញ្ជូនដែលត្រូវធ្វើនៅបរទេស **ក្រឡាបញ្ជីតុលាការ** អាចជូនដំណឹងថាបានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ ហើយជំនួយការប្រកាសផ្សាយនៅក្នុងរាជកិច្ច ឬ ក្នុងសារព័ត៌មាន។[24]

### គ. អានុភាពនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ

---

[23] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៥៥

[24] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៥៦

ការបញ្ជូនតាមការផ្សាយជាសាធារណៈនឹងមានអានុភាពនៅក្រោយអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានបិទប្រកាសដូចជានៅកន្លែងបិទប្រកាសរបស់តុលាការជាអាទិ៍។ ប៉ុន្តែចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈដោយការបញ្ជូនជាលើកទី២ ដោយឆន្ទានុសិទ្ធិ ឬ តាមពាក្យសុំមកតុលាការ ដើម្បីឲ្យតុលាការអាចធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈជាលើកទី២ នឹងមានអានុភាពនៅថ្ងៃបន្ទាប់ពីថ្ងៃបិទប្រកាស។ ការបញ្ជូនតាមការផ្សាយជាសាធារណៈ ដែលបានធ្វើឡើងសម្រាប់ការបញ្ជូននៅបរទេសអំឡុងពេលកំណត់គឺ ៦ (ប្រាំមួយ) សប្តាហ៍ បន្ទាប់ពីថ្ងៃបិទប្រកាស ។[25]

### ២.១.២. ការបញ្ជូនទៅអសមត្ថជនក្នុងបណ្តឹង

ការបញ្ជូនទៅបុគ្គលអសមត្ថជនក្នុងបណ្តឹង គឺត្រូវធ្វើការបញ្ជូនទៅចំពោះអ្នកតំណាងដែលច្បាប់បានកំណត់រួមមាន **អនីតិជន** ត្រូវបញ្ជូនទៅអ្នកមានអំណាចមេបារបស់អនីតិជននោះប៉ុន្តែចំពោះករណីដែល **អនីតិជន** អាចធ្វើសកម្មភាពដោយឯករាជ្យមានន័យថា **អនីតិជន** នោះបានទទួលការអនុញ្ញាតឲ្យប្រកបអាជីវកម្មតាមការអនុញ្ញាតពីអ្នកមានអំណាចមេបា ឬ អ្នកមានអ្នកអាណាព្យាបាលសម្រាប់អនីតិជន និង ចំពោះអនីតិជនដែលទទួលបានអគ្គាធិភាព គឺអាចទទួលបានការបញ្ជូន ពីអ្នកធ្វើការបញ្ជូនមកឲ្យខ្លួនបានដោយពុំចាំបាច់មានអ្នកតំណាងដែលច្បាប់បានកំណត់ទទួលយកនូវឯកសារបញ្ជូននោះទេ។ ចំពោះការបញ្ជូនទៅឲ្យជននៅក្រោមអាណាព្យាបាលទូទៅ ត្រូវបញ្ជូនទៅអ្នកអាណាព្យាបាលទូទៅរបស់ជននោះ។ ចំពោះករណីដែលអ្នកមានសិទ្ធិជាតំណាង រួមគ្នាច្រើននាក់ការបញ្ជូន អាចធ្វើទៅចំពោះតែជនណាម្នាក់ជាការគ្រប់គ្រាន់ រីឯការបញ្ជូនទៅឲ្យបុគ្គលដែលកំពុងជាប់ពន្ធនាគារត្រូវធ្វើទៅចំពោះប្រធានពន្ធនាគារ។[26]

## ២.២. របាយការណ៍អំពីការបញ្ជូន

មន្ត្រីទទួលបន្ទុកការបញ្ជូនដែលបានធ្វើការបញ្ជូនរួចហើយត្រូវធ្វើរបាយការណ៍អំពីការបញ្ជូននោះជូនទៅតុលាការ។ ទម្រង់ការធ្វើរបាយការណ៍អំពីការបញ្ជូនត្រូវបានកំណត់ទៅតាមទម្រង់នៃចំណុចដែលត្រូវបញ្ជាក់ដូចតទៅៈ

- សញ្ញាណនៃរឿងក្តី និងឯកសារដែលបានបញ្ជូន
- ជនដែលទទួលការបញ្ជូន
- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងដែលបានធ្វើការបញ្ជូន
- វិធីនៃការបញ្ជូន

---

[25] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៥៧

[26] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៤៨

- ក្នុងករណីដែលអ្នកទទួលឯកសារនៃការបញ្ជូនមិនចេះអក្សរមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនគប្បីពន្យល់នូវខ្លឹមសារនៃឯកសារនៃការបញ្ជូននោះនៅពេលដែលប្រគល់ឯកសារ
- ហត្ថលេខា ឬស្នាមេដៃរបស់អ្នកដែលបានទទួលឯកសារ
- ហេតុការណ៍ដែលមិនព្រមទទួលការបញ្ជូនរបស់ជនដែលត្រូវទទួលការបញ្ជូន ឬ អ្នកដែលត្រូវបានប្រគល់ឯកសារតាមវិធីនៃការបញ្ជូន ដោយការបញ្ជូនដោយបង្គ្រប់កិច្ច និង ការបញ្ជូនដោយទុកចោល
- ហេតុការណ៍នៅក្នុងករណីដែលការបញ្ជូនបានធ្វើតាមការបញ្ជូនដោយបង្គ្រប់កិច្ច និង ការបញ្ជូនដោយទុកចោល
- ហត្ថលេខារបស់អ្នកដែលបានប្រតិបត្តិការបញ្ជូន

ក្នុងករណីដែលបានព្យាយាមបញ្ជូន ហើយតែមិនអាចសម្រេចបានមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនត្រូវធ្វើរបាយការណ៍អំពីហេតុការណ៍នោះ និង ចំណុចដែលបានកំណត់ដូចជាសញ្ញាណនៃរឿងក្តី និងឯកសារដែលបានបញ្ជូន ជនដែលទទួលការបញ្ជូន ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងដែលបានធ្វើការបញ្ជូន, វិធីនៃការបញ្ជូន និងមានហត្ថលេខារបស់អ្នកដែលបានប្រតិបត្តិកិច្ចការបញ្ជូន។[27]

[27] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៥៤

# ជំពូកទី២

# ការរកឃើញលើការអនុវត្ត

# ជាក់ស្តែង

# ឬការពិពណ៌នាអំពីការខារ

# ជំពូកទី២

# ការរកឃើញលើការអនុវត្តជាក់ស្តែង ឬ ការពិពណ៌នាអំពីការងារ

នៅក្នុងផ្នែកទី២ នេះគឺនឹងធ្វើការរៀបរាប់អំពីនីតិវិធីនៃការអនុវត្តការងារជាក់ស្តែងដែលបានចុះកម្មសិក្សានៅសាលាដំបូងខេត្តព្រះសីហនុ និង បានចូលរួមសិក្សាលើដំណើរការនីតិវិធីនៃការបញ្ជូនដោយផ្ទាល់លើការអនុវត្តជាក់ស្តែង។ ដើម្បីធ្វើការសិក្សាក្នុងផ្នែកនេះឲ្យបានច្បាស់ គឺមានការបែងចែកជា ៣ (បី) ចំណុច រួមមាន **ចំណុចទី១** សិក្សាពីមន្ត្រីដែលធ្វើការបញ្ជូនក្នុងការអនុវត្តការងារ ជាក់ស្តែង, **ចំណុចទី២** គឺសិក្សាអំពីវិធីបញ្ជូនក្នុងការអនុវត្តជាក់ស្តែង និង **ចំណុចទី៣** សិស្សាអំពីរបាយការណ៍អំពីការបញ្ជូនដែល នឹង សិក្សាស្របតាមការបែងចែកដូចខាងក្រោមៈ

## ១. មន្ត្រីដែលធ្វើការបញ្ជូនក្នុងការអនុវត្តជាក់ស្តែង

### ១.១. មន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូន

មន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូនគឺជា **ក្រឡាបញ្ជី**។ ក្នុងការអនុវត្តការងារជាក់ស្តែង **ក្រឡាបញ្ជី** មានភារកិច្ចគឺការធ្វើ ឬ ការផ្តល់សេចក្តីបញ្ជាក់នូវឯកសារសម្រាប់ប្រើក្នុងការបញ្ជូនហើយប្រគល់ឯកសារ និងអំណាចនៃការបញ្ជូនឯកសារនោះទៅឲ្យមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន[28] នឹងទទួលរបាយការណ៍អំពីការបញ្ជូនពីមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនដើម្បីយកទៅដាក់ជូនចៅក្រមពិនិត្យ និងរក្សាទុករបាយការណ៍អំពីការបញ្ជូននោះដាក់ក្នុងសំណុំរឿងជាអាទិ៍។

### ១.២. មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន

មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនរួមមាន **បុគ្គលិកប្រៃណីយ៍ អាជ្ញាសាលា និង ក្រឡាបញ្ជី** ។ មុខងាររបស់មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន គឺត្រូវបញ្ជូនឯកសារដែលត្រូវបញ្ជូន ទៅជនដែលត្រូវទទួលការបញ្ជូន និង ធ្វើរបាយការណ៍អំពីការបញ្ជូន ហើយដាក់របាយការណ៍នោះទៅតុលាការ។ មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនក្នុងការអនុវត្តជាក់ស្តែងដែលបានអនុវត្តការងារនេះ គឺមានបុគ្គលិក ប្រៃណីយ៍ និង ក្រឡាបញ្ជី ដែលបានធ្វើកិច្ចការក្នុងនីតិវិធីនៃការបញ្ជូននេះ។ **មន្ត្រីក្រឡាបញ្ជី** បានធ្វើការចាត់ចែងលើកិច្ចការនេះដោយមានដំណើរការនីតិវិធីបានជាធម្មតា ដោយគ្មានបញ្ហាណាមួយខាងនីតិវិធីនៃការបញ្ជូន នេះកើតឡើងឡើយទោះបីជាមិនមានការធ្វើនីតិវិធីប្រតិបត្តិការបញ្ជូនពី **អាជ្ញាសាលា** សម្រាប់ប្រតិបត្តិការបញ្ជូនក៏ដោយ។ ដូច្នេះ

[28] មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនៈ បុគ្គលិកប្រៃណីយ៍ អាជ្ញាសាលា និងក្រឡាបញ្ជី។

ចំពោះមន្ត្រីទទួលប្រតិបត្តិការបញ្ជូនដែលបានធ្វើកិច្ចការបញ្ជូនដែលធ្វើការរៀបរាប់នៅក្នុងរបាយការណ៍នេះគឺនឹងលើកយកតែមន្ត្រីទទួលបន្ទុកប្រតិបត្តិកិច្ចការបញ្ជូន ដែលបានអនុវត្តការងារក្នុងដំណើរការនីតិវិធីនៃការបញ្ជូនមកធ្វើការសិក្សាប៉ុណ្ណោះដោយរួមមាន **បុគ្គលិកប្រៃសណីយ៍ និង ក្រឡាបញ្ជី** ដែលបានចូលរួមអនុវត្តក្នុងដំណើរការនីតិវិធីនៃការបញ្ជូនក្នុងការអនុវត្តការងារជាក់ស្តែងនេះ។

### ១.២.១. ក្រឡាបញ្ជី

**ក្រឡាបញ្ជី** គឺមានតួនាទីដ៏សំខាន់ក្នុងនាមជាមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន និង ក៏ជាមន្ត្រីទទួលបន្ទុកប្រតិបត្តិកិច្ចការបញ្ជូនផងដែរ។ ចំពោះការទទួលបន្ទុកចាត់ចែងកិច្ចការបញ្ជូន និង ប្រតិបត្តិកិច្ចការបញ្ជូនក្នុងការអនុវត្តជាក់ស្តែងដែលបានអនុវត្ត **ក្រឡាបញ្ជី** ត្រូវធ្វើការពិនិត្យទៅលើឯកសារ ដែលត្រូវធ្វើនីតិវិធីនៃការបញ្ជូនបន្ទាប់មក **ក្រឡាបញ្ជី** នៅពេលដែលធ្វើការបញ្ជូនឯកសារដែលត្រូវធ្វើការបញ្ជូនរួចរាល់ហើយត្រូវតែធ្វើជារបាយការណ៍អំពីការបញ្ជូនដើម្បីដាក់រក្សាទុកក្នុងសំណុំរឿង។

### ១.២.២. បុគ្គលិកប្រៃសណីយ៍

បុគ្គលិកប្រៃសណីយ៍ គឺមានតួនាទីជាមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន បន្ទាប់ពីបានទទួលនូវឯកសារពីមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន។ ក្នុងការអនុវត្តជាក់ស្តែងបុគ្គលិកប្រៃសណីយ៍នៅពេលដែលប្រតិបត្តិកិច្ចការបញ្ជូនក្រោយពីទទួលឯកសារពី **មន្ត្រីក្រឡាបញ្ជី** ដែលជាមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនរួចហើយត្រូវតែបញ្ជូនឯកសារនៃការបញ្ជូននោះ ទៅឲ្យបុគ្គលដែលត្រូវទទួលការបញ្ជូន និង ត្រូវធ្វើជារបាយការណ៍អំពីការបញ្ជូន និង មានភ្ជាប់នូវវិក័យបត្រទទួលប្រាក់ដាក់ជូនមន្ត្រី ទទួលបន្ទុកកិច្ចការបញ្ជូន **(ក្រឡាបញ្ជី)** ដើម្បីដាក់បញ្ចូលក្នុងសំណុំរឿង។ ប៉ុន្តែការអនុវត្តជាក់ស្តែងមួយចំនួន នៅពេលដែលបុគ្គលិកប្រៃសណីយ៍បានទទួលឯកសារបញ្ជូនពីមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនរួចហើយគឺពុំបានធ្វើរបាយការណ៍នៃការបញ្ជូននោះទេគឺមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន **(ក្រឡាបញ្ជី)** ជាអ្នកធ្វើរបាយការណ៍អំពីការបញ្ជូនដែលខុសពីលក្ខខណ្ឌច្បាប់កំណត់ដែលការធ្វើរបាយការណ៍អំពីការបញ្ជូនជាតួនាទីរបស់មន្ត្រីទទួលបន្ទុកប្រតិបត្តិកិច្ចការបញ្ជូន ។

## ២. វិធីបញ្ជូនក្នុងការអនុវត្តជាក់ស្តែង

វិធីបញ្ជូនដែលបានអនុវត្តនៅក្នុងការអនុវត្តជាក់ស្តែង គឺ មិនបានធ្វើទៅតាមគ្រប់វិធីទាំងអស់ដែលមានចែងស្របទៅតាមបញ្ញត្តិច្បាប់នោះទេ ដោយវិធីមួយចំនួនមិនទាន់បានប្រតិបត្តិដើម្បីធ្វើការបញ្ជូនដូច្នេះចំពោះការអនុវត្តវិធីនៃការបញ្ជូនដែលបានអនុវត្តក្នុងការងារជាក់ស្តែងវិធីនៃការបញ្ជូន ដែលបានអនុវត្តរួមមានការបញ្ជូន

ដោយការប្រគល់ការបញ្ជូនដោយការជួបប្រទះ ការបញ្ជូនដោយបង្គ្រប់កិច្ច និងវិធីនៃការបញ្ជូនតាមការផ្សាយជាសាធារណៈដែលបានអនុវត្ត និង បានសិក្សាជួបប្រទះក្នុងអំឡុងពេលកម្មសិក្សាមានដូចខាងក្រោម៖

## ២.១. ការបញ្ជូនដោយការប្រគល់

ការបញ្ជូនដោយការប្រគល់ គឺជាការបញ្ជូនដែលត្រូវធ្វើឡើងដោយផ្ទាល់ទៅបុគ្គលដែលត្រូវទទួលការបញ្ជូននៅលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការ របស់ជនដែលត្រូវទទួលការបញ្ជូននោះ ឬ កន្លែងដែលបុគ្គលដែលទទួលការបញ្ជូនបានជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីទីកន្លែងដើម្បីឲ្យធ្វើការបញ្ជូន។ មន្ត្រីទទួលបន្ទុកប្រតិបត្តិកិច្ចការបញ្ជូននៅពេលដែលមានឯកសារដែលពាក់ព័ន្ធ នឹង ការបញ្ជូនត្រូវតែពិនិត្យមើលទៅលើអាសយដ្ឋានរបស់បុគ្គលដែល ត្រូវធ្វើការបញ្ជូននោះ រួចហើយធ្វើការបញ្ជូននូវឯកសារនៃការបញ្ជូននោះទៅតាមអាសយដ្ឋានដែលត្រូវធ្វើការបញ្ជូន និង ត្រូវប្រគល់ឲ្យដោយផ្ទាល់នូវឯកសារដែលត្រូវធ្វើការបញ្ជូនទៅបុគ្គលដែលត្រូវទទួលការបញ្ជូននោះនៅទីកន្លែងដែលត្រូវធ្វើការបញ្ជូន។ ការបញ្ជូនដោយការប្រគល់នៅក្នុងការអនុវត្តជាក់ស្តែងនៅពេលដែល មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន បានអនុវត្តវិធីនៃការបញ្ជូននេះដំបូងឡើយត្រូវពិនិត្យលើឯកសារដែលត្រូវបញ្ជូនរួចហើយត្រូវមើលទៅលើទីកន្លែងដែលត្រូវធ្វើការបញ្ជូន។ នៅពេលដែលធ្វើការបញ្ជូន ដល់ទីកន្លែងនៃការធ្វើការបញ្ជូន រួចហើយមន្ត្រីទទួលបន្ទុកប្រតិបត្តិកិច្ចការបញ្ជូនត្រូវធ្វើរបាយការណ៍អំពីការបញ្ជូន និង ប្រគល់របាយការណ៍អំពីការបញ្ជូននោះជូនទៅមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនដើម្បីធ្វើការរក្សាទុករបាយការណ៍អំពីការបញ្ជូននោះដាក់ក្នុងសំណុំរឿង។

## ២.២. ការបញ្ជូនដោយការជួបប្រទះ

ការបញ្ជូនដោយការជួបប្រទះ គឺប្រសិនបើជនដែលត្រូវទទួលការបញ្ជូននោះពុំច្បាស់លាស់ថាមានអាសយដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ឬ គ្មានការជូនដំណឹងអំពីទីកន្លែងដែលត្រូវធ្វើការបញ្ជូនរបស់ភាគី ឬ អ្នកតំណាងតាមផ្លូវបណ្តឹង ឬ ក៏ទោះបីជាបានដឹងច្បាស់លាស់អំពីអាសយដ្ឋានរបស់ជនដែលត្រូវទទួលការបញ្ជូននៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ មានការជូនដំណឹងអំពីទីកន្លែងដែលត្រូវបញ្ជូនក៏ដោយ ក៏អាចធ្វើការបញ្ជូននៅទីកន្លែង ដែលបានជួបប្រទះជននោះបានដែរប្រសិនបើជនដែលទទួលការបញ្ជូននោះមិនប្រកែកចំពោះការទទួលការបញ្ជូនទេ។ ការបញ្ជូនដោយការជួបប្រទះ ក្នុងការអនុវត្តជាក់ស្តែង នៅពេលដែលមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន ធ្វើការបញ្ជូនឯកសារ ដែលត្រូវបញ្ជូនទៅបុគ្គលដែលត្រូវទទួលការបញ្ជូន គឺ នៅពេលដែលមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនបានដឹងអំពីអាសយដ្ឋានរបស់ជនដែលត្រូវទទួលការបញ្ជូនហើយក៏ដោយ ប៉ុន្តែមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូននៅពេលអនុវត្តបានធ្វើការហៅជនដែលត្រូវទទួលការបញ្ជូនតាមរយៈ

ទូរស័ព្ទជាអាទិ៍ ដើម្បីឲ្យជននោះមកទទួលយកឯកសារ ដែលត្រូវបញ្ជូននៅតុលាការដោយផ្ទាល់ហើយធ្វើការប្រគល់ឯកសារដែលត្រូវបញ្ជូននោះរួចធ្វើរបាយការណ៍អំពីការបញ្ជូនដើម្បីរក្សាទុកក្នុងសំណុំរឿង។

### ២.៣. ការបញ្ជូនដោយបង្គ្រប់កិច្ច

ការបញ្ជូនដោយបង្គ្រប់កិច្ច គឺមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនអាចប្រគល់ឯកសារដែលត្រូវធ្វើការបញ្ជូនទៅឲ្យអ្នកដែលមានការយល់ដឹងសមរម្យដូចជា អ្នកបម្រើ ឬ អ្នកផ្សេងទៀតដែលធ្វើ ការនៅទីនោះ ឬ អ្នកនៅជាមួយក្នុងករណីដែលមិនបានជួបជន ដែលត្រូវទទួលការបញ្ជូននៅទីកន្លែង ដែលត្រូវប្រគល់នោះទេករណីនេះហៅថា "**ការបញ្ជូនដោយបង្គ្រប់កិច្ច**"។ ចំពោះអ្នកមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារសំដៅលើអ្នកដែលអាចយល់ច្បាស់អំពីសារៈសំខាន់ នៃការបញ្ជូន អាចយល់ពីអត្ថន័យនៃឯកសារដែលបានទទួល និង មានសមត្ថភាពអាចយកឯកសារ នោះទៅប្រគល់ឲ្យបុគ្គលដែលត្រូវទទួលការបញ្ជូននោះ។ មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនត្រូវឲ្យជនដែលទទួលដោយការបញ្ជូនដោយបង្គ្រប់កិច្ចនោះសន្យាថា នឹង ប្រគល់ឯកសារចំពោះជនដែលត្រូវទទួលនោះនៅពេលដែលជននោះត្រឡប់មកវិញ។

### ២.៤. ការបញ្ជូនដោយទុកចោល

ការបញ្ជូនដោយទុកចោលនៅពេលដែលនីតិវិធីនៃការបញ្ជូនដោយប្រគល់ការបញ្ជូនដោយជួបប្រទះ និងការបញ្ជូនដោយបង្គ្រប់កិច្ចបានធ្វើការបញ្ជូនអស់លទ្ធភាពហើយប្រសិនជាជនដែលត្រូវទទួលការបញ្ជូន ឬ ជនដែលត្រូវទទួលការបញ្ជូនដោយបង្គ្រប់កិច្ច បដិសេធមិនព្រមទទួលការបញ្ជូន ដោយគ្មានមូលហេតុត្រឹមត្រូវទេ មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន អាចទុកឯកសារដែលត្រូវបញ្ជូនចោលនៅទីកន្លែងនោះបានការបញ្ជូនបែបនេះហៅថា"**ការបញ្ជូនដោយទុកចោល**" ។[29]

### ២.៥. ការបញ្ជូនទៅបរទេស

ការបញ្ជូនទៅបរទេស គឺជាការបញ្ជូនចេញទៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ករណីដែលជនត្រូវទទួលការបញ្ជូននោះមិនមានលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការ ដែលអាចបញ្ជូនបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ មូលហេតុដោយជននោះរស់នៅបរទេសដូច្នេះមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនអាចបញ្ជូនទៅបរទេសបាន។ ការបញ្ជូនទៅបរទេសតុលាការត្រូវប្រគល់កិច្ចការនេះឲ្យក្រសួងឬស្ថាប័នដែលមានសមត្ថកិច្ចទទួលបន្ទុកកិច្ចការបញ្ជូននៃប្រទេសនោះ ឬ **ឯកអគ្គរាជទូត ឬភារធារី ឬកុងស៊ុល** របស់ព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនោះឲ្យអនុវត្តបាន។ ប៉ុន្តែមុននឹងធ្វើការបញ្ជូនតុលាការគប្បីពិនិត្យមើល

[29] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៥២កថាខណ្ឌទី២

អនុសញ្ញា ឬ សន្ធិសញ្ញារវាងប្រទេសនោះ និងប្រទេសកម្ពុជា ឬកិច្ចព្រមព្រៀងផ្សេងទៀត ឬ ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ដោយផ្អែកលើ ទំនៀមទម្លាប់ ព្រោះមានករណីខ្លះបទដ្ឋានគតិយុត្តទាំងនោះមិនកំណត់អំពីរបៀបនៃការបញ្ជូននោះទេ។[30]

**-ការបញ្ជូនទៅបរទេសអាចធ្វើតាម ២ករណីគឺ៖**

**ករណីទី១៖** ជនដែលត្រូវទទួលការបញ្ជូននោះជាជនជាតិខ្មែរតែរស់នៅបរទេស គប្បីបញ្ជូនដោយប្រគល់ឲ្យឯកអគ្គរាជទូត ឬភារធារី ឬកុងស៊ុល របស់ព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនោះជាអ្នកអនុវត្ត។ មានន័យថាករណីនេះចៅក្រមដែលទទួលបន្ទុក ឬបានទទួលការប្រគល់សិទ្ធិមិនមែនជាអ្នកបញ្ជូនដោយផ្ទាល់នោះទេ ចៅក្រមត្រូវរៀបចំឯកសារដែលត្រូវបញ្ជូននោះទៅឲ្យ ឯកអគ្គរាជទូត ឬ ភារធារី ឬកុងស៊ុល របស់ប្រទេសកម្ពុជាប្រចាំប្រទេស ដែលត្រូវធ្វើការបញ្ជូនទៅជាអ្នកអនុវត្តការបញ្ជូននោះ។[31]

**ករណីទី២៖**ករណីដែលជនដែលត្រូវទទួលការបញ្ជូនជាជនជាតិបរទេសហើយរស់នៅបរទេស **ចៅក្រម** ត្រូវរៀបចំឯកសារដែលត្រូវបញ្ជូនប្រគល់ឲ្យក្រសួង ឬ ស្ថាប័នដែលមានសមត្ថកិច្ចនៃប្រទេសជាអ្នកធ្វើការអនុវត្តការបញ្ជូន។[32] ឯកអគ្គរាជទូត ឬភារធារី គឺជាប្រមុខនៃបេសកកម្មការទូតដែលរដ្ឋដាក់ទូត បានបញ្ជូនឲ្យមកធ្វើជាតំណាងដើម្បីទទួលបន្ទុកភារកិច្ចការទូតទាំងមូលដែលកើតឡើងក្នុងទំនាក់ទំនងរដ្ឋដាក់ទូតនឹងរដ្ឋម្ចាស់ផ្ទះ ហើយឥស្សរជនដែលត្រូវបានតែតាំងជាឯកអគ្គរាជទូត ឬ ភារធារីមានឋានានុក្រមខ្ពស់ជាងគេបំផុតក្នុងចំណោមមន្ត្រីការទូតទាំងអស់។ នីតិវិធីនៃការតែងតាំងប្រមុខនៃបេសកកម្ម ការទូតកុងស៊ុល មានមុខងារផ្តល់ទិដ្ឋាការ ឬ រៀបចំចាត់ចែងបែបបទអន្តោប្រវេសន៍ដល់ជនបរទេសសម្រាប់ការចូលទៅក្នុងរដ្ឋដាក់កុងស៊ុស ឬបញ្ជាក់ពី ភាពត្រឹមត្រូវនៃឯកសារអត្រានុកូលដ្ឋានផ្សេងៗ សម្រាប់ពលរដ្ឋរបស់ខ្លួនប្រើប្រាស់នៅក្នុងរដ្ឋម្ចាស់ផ្ទះ ដូចជាសំបុត្រកំណើតសំបុត្រអាពាហ៍ពិពាហ៍ជាអាទិ៍។ ក្រៅពីនេះកុងស៊ុលអាចជួយដោះស្រាយករណីដែលពលរដ្ឋរបស់ខ្លួនបានបាត់លិខិតឆ្លងដែនក្នុងពេលធ្វើដំណើរ ឬ កំពុងស្នាក់នៅក្នុងទឹកដីនៃរដ្ឋម្ចាស់ផ្ទះដោយចេញឯកសារបញ្ជាក់ដើម្បីឲ្យពលរដ្ឋរបស់ខ្លួនអាចធ្វើដំណើរបន្តទៀតបាន។ ចំពោះជនដែលត្រូវទទួលការបញ្ជូនជាជនជាតិបរទេសហើយរស់នៅក្នុងប្រទេសកម្ពុជា ដូច្នេះត្រូវយកវិធីនៃការបញ្ជូនចំពោះជនជាតិខ្មែរមកអនុវត្តក្នុងករណីនេះ។

## ២.៦. ការបញ្ជូនតាមការផ្សាយជាសាធារណៈ

[30] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៥៣

[31] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៥៣ ចំណុចទី២

[32] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៥៣ ចំណុចទី២

ការបញ្ជូនតាមការផ្សាយជាសាធារណៈ គឺជារបបមួយជាចាំបាច់ដើម្បីឲ្យដើមចោទអាចធ្វើបណ្ដឹងបាន ទោះបីជាមិនដឹងលំនៅឋានជាអាទិ៍របស់ចុងចម្លើយ ហើយមិនអាចធ្វើការបញ្ជូនតាមវិធីធម្មតាក៏ដោយ។ ប៉ុន្តែ ចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈត្រូវធ្វើឡើងដោយផ្អែកទៅតាមរបៀបនៃការបញ្ជូនតាមការផ្សាយ ជាសាធារណៈដោយហេតុថាជាក់ស្តែងពិតមានការពិបាករំពឹងថាជនដែលត្រូវទទួលការបញ្ជូននោះអាចដឹងបាន។ ម្លោះហើយប្រព័ន្ធនេះមានការគ្រោះថ្នាក់បន្តិចប្រសិនបើដើមចោទបានប្រើប្រព័ន្ធនេះដើម្បីធ្វើឲ្យការជម្រះក្តីនោះ លម្អៀងមករកខ្លួននៅពេលដែលចុងចម្លើយមិនបានដឹង។ ហេតុនេះដើម្បីការពារកុំឲ្យមានអំពើខិលខូចនេះកើត ឡើងតុលាការត្រូវធ្វើការពិនិត្យទៅលើលក្ខខណ្ឌដើម្បីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ។ ដូចជាត្រូវដឹងពី អាសយដ្ឋានភាគីជាដើមចោទឲ្យបានលម្អិត នឹងច្បាស់លាស់។ ខាងក្រោមនេះគឺជាការបកស្រាយទៅលើការ ពិនិត្យអំពីដំណើរការនីតិវិធីនៃការបញ្ជូនផ្សេងៗជាមុនសិនដែលជាលក្ខខណ្ឌចាំបាច់មុននឹងធ្វើការបញ្ជូនតាម ការផ្សាយជាសាធារណៈបានដោយលើកយកអំពីលក្ខខណ្ឌនិងរបៀបនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ មកធ្វើការសិក្សាឲ្យ បានច្បាស់លាស់។

### ២.៦.១. លក្ខខណ្ឌនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ

ដើម្បីធ្វើនីតិវិធីនៃការបញ្ជូនតាមការផ្សាយជាសាធារណៈបានមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនគឺ **ក្រឡាបញ្ជី** ត្រូវធ្វើការពិនិត្យទៅលើលក្ខខណ្ឌកំណត់ដោយច្បាប់ ដើម្បីអាចប្រើប្រាស់វិធី នៃការបញ្ជូនតាមការផ្សាយជា សាធារណៈបានដោយអាចធ្វើឡើងតាមរយៈពាក្យសុំដោយទទួលការអនុញ្ញាតពីតុលាការបានដោយផ្អែកលើ ករណីនៃលក្ខខណ្ឌដូចខាងក្រោម៖

- ទោះបីបានខំប្រឹងប្រែងធ្វើការស្រាវជ្រាវរកលំនៅឋាន ឬទីសំណាក់របស់ភាគី ឬកន្លែងផ្សេងទៀតដែល ត្រូវធ្វើការបញ្ជូនក៏ដោយក៏នៅតែរកមិនឃើញអំពីអាសយដ្ឋាននេះ។

- ទោះបីជាស្គាល់អំពីអាសយដ្ឋាន របស់បុគ្គលដែលទទួលការបញ្ជូនក៏ដោយ តែមិនអាចធ្វើការបញ្ជូនតាម វិធីនៃការបញ្ជូនដោយបង្គ្រប់កិច្ច ឬ ការបញ្ជូនដោយទុកចោល។ ប៉ុន្តែ **ក្រឡាបញ្ជី** គប្បីជូនដំណឹងដោយ របៀបសមរម្យមួយអំពីហេតុការណ៍ដែលបានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈទៅភាគីដែលត្រូវទទួល ការបញ្ជូននោះ។

- បើជនដែលទទួលការបញ្ជូនទៅបរទេសការបញ្ជូនមិនអាចធ្វើការបញ្ជូនបាន ឬ ទទួលស្គាល់ថាគ្មាន លទ្ធភាពនឹងធ្វើបាន។ **ឧទាហរណ៍៖** ករណីដែលមិនបានដឹងច្បាស់ថា បុគ្គលដែលទទួលការបញ្ជូនស្ថិតនៅ ក្នុងប្រទេសណាមួយ ឬ គ្មានទំនាក់ទំនងការទូតចំពោះរដ្ឋបរទេសណាមួយនោះដែលមិនអាចធ្វើការបញ្ជូន បាន។ ការបញ្ជូនដោយត្រឹមត្រូវទៅបរទេសដោយបានធ្វើការប្រគល់ឲ្យទៅក្រសួង ឬ ស្ថាប័នដែលមាន

សមត្ថកិច្ចនៅបរទេសរួចហើយតែមិនបានទទួលលិខិតបញ្ជាក់អំពីការបញ្ជូននោះក្នុងអំឡុងពេល **៦ (ប្រាំមួយ) ខែ** ចាប់តាំងពីពេលបញ្ជូននោះ។

**ក្រឡាបញ្ជី** ក៏អាចធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបានដែរដោយការបង្គាប់ពីតុលាការ ដោយតុលាការអាចប្រើឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងករណីឃើញថាចាំបាច់ដើម្បីជៀសវាងការយឺតយ៉ាវក្នុងដំណើរការនីតិវិធីទោះបីជាគ្មានពាក្យសុំក៏ដោយ។

**ការបញ្ជូនជាលើកទី២** តាមការផ្សាយជាសាធារណៈចំពោះភាគីដដែលត្រូវធ្វើដោយឆន្ទានុសិទ្ធិលើកលែងតែក្នុងករណីនៃការបញ្ជូនទៅបរទេសដែលមិនអាចធ្វើការបញ្ជូនបាន ឬ ទទួលស្គាល់ថាគ្មានលទ្ធភាពនឹងធ្វើបាន ត្រូវមានពាក្យសុំមកតុលាការដើម្បីឲ្យតុលាការអាចធ្វើការបញ្ជូនតាមវិធីតាមការផ្សាយជាសាធារណៈជាលើកទី២ បាន។[33]

### ២.៦.២. របៀបបញ្ជូនតាមការផ្សាយជាសាធារណៈ

របៀបបញ្ជូនតាមការបញ្ជូនតាមការផ្សាយជាសាធារណៈ អាចត្រូវធ្វើតាមរបៀបនៃការបិទប្រកាសដូចជាត្រូវបិទប្រកាសនៅកន្លែងសម្រាប់បិទប្រកាសរបស់តុលាការដោយថា **ក្រឡាបញ្ជី** រក្សាទុកនូវឯកសារដែលត្រូវបញ្ជូន និង អាចប្រគល់ឯកសារនោះទៅជនដែលទទួលការបញ្ជូន នៅពេលណាក៏បាន។ ប៉ុន្តែការបញ្ជូនដីកាកោះតាមការផ្សាយជាសាធារណៈវិញត្រូវបិទដីការនោះនៅកន្លែងសម្រាប់បិទប្រកាស។ ចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈដោយមិនអាចធ្វើការបញ្ជូនដោយការបញ្ជូននៅពេលណាក៏បាន។ ប៉ុន្តែការបញ្ជូនដីកាកោះតាមការផ្សាយជាសាធារណៈវិញត្រូវបិទដីកានោះនៅកន្លែងសម្រាប់បិទប្រកាស។ ចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈដោយមិនអាចធ្វើការបញ្ជូនដោយការបញ្ជូនដោយបង្គ្រប់កិច្ច និង ការបញ្ជូនដោយទុកចោល ការបិទប្រកាសអាចធ្វើបាននៅកន្លែងដែលតុលាការយល់ឃើញថាសមរម្យដូចជាអាចនៅប៉ុស្តិ៍នគរបាល ឬ សាលាឃុំ ជាដើមដោយក្រៅពីកន្លែងសម្រាប់បិទប្រកាសរបស់តុលាការ។ តុលាការអាចចុះនៅក្នុងរាជកិច្ច ឬ ក្នុងសារព័ត៌មានផ្សាយថាបានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈហើយ។ ចំពោះការបញ្ជូនដែលត្រូវធ្វើនៅបរទេស **ក្រឡាបញ្ជីតុលាការ** អាចជូនដំណឹងថាបានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈហើយ។ ចំពោះការបញ្ជូនដែលត្រូវធ្វើនៅបរទេស **ក្រឡាបញ្ជីតុលាការ** អាចជូនដំណឹងថាបានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈហើយជំនួយការប្រកាសផ្សាយនៅក្នុងរាជកិច្ច ឬ ក្នុងសារព័ត៌មាន។[34]

### ២.៦.៣. អានុភាពនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ

[33] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៥៥

[34] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៥៦

ការបញ្ជូនតាមការផ្សាយជាសាធារណៈនឹងមានអានុភាពនៅក្រោយអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានបិទប្រកាសដូចជា នៅកន្លែងបិទប្រកាសរបស់តុលាការជាអាទិ៍។ ប៉ុន្តែចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈដោយការបញ្ជូនជាលើកទី២ ដោយឆន្ទានុសិទ្ធិ ឬ តាមពាក្យសុំមកតុលាការដើម្បីឲ្យតុលាការអាចធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈជាលើកទី២ នឹង មានអានុភាពនៅថ្ងៃបន្ទាប់ពីថ្ងៃបិទប្រកាស។ ការបញ្ជូនតាមការផ្សាយជាសាធារណៈ ដែលបានធ្វើឡើងសម្រាប់ការបញ្ជូនទៅបរទេសអំឡុងពេលកំណត់គឺ **៦ (ប្រាំមួយ) សប្តាហ៍** បន្ទាប់ពីថ្ងៃបិទប្រកាស។[35]

### ២.៧. ការបញ្ជូនទៅអសមត្ថជនក្នុងបណ្តឹង

ការបញ្ជូនទៅបុគ្គលអសមត្ថជនក្នុងបណ្តឹង គឺត្រូវធ្វើការបញ្ជូនទៅចំពោះអ្នកតំណាងដែលច្បាប់បានកំណត់រួមមាន **អនីតិជន** ត្រូវបញ្ជូនទៅអ្នកមានអំណាចមេបារបស់អនីតិជននោះប៉ុន្តែចំពោះករណីដែលអនីតិជនអាចធ្វើសកម្មភាពដោយឯករាជ្យមានន័យថា អនីតិជន នោះបានទទួលការអនុញ្ញាតឲ្យប្រកបអាជីវកម្មតាមការអនុញ្ញាតពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន និង ចំពោះអនីតិជនដែលទទួលបានអត្តាធិនភាព គឺអាចទទួលការបញ្ជូនពីអ្នកធ្វើការបញ្ជូនមកឲ្យខ្លួនបាន ដោយពុំចាំបាច់មានអ្នកតំណាងដែលច្បាប់បានកំណត់ទទួលយកនូវឯកសារបញ្ជូននោះទេ។ ចំពោះការបញ្ជូនទៅឲ្យជននៅក្រោមអាណាព្យាបាលទូទៅត្រូវបញ្ជូនទៅអ្នកអាណាព្យាបាលទូទៅរបស់ជននោះ។ ចំពោះករណីដែលអ្នកមានសិទ្ធិជាតំណាងរួមគ្នាច្រើននាក់ការបញ្ជូនអាចធ្វើទៅចំពោះតែជនណាម្នាក់ជាការគ្រប់គ្រាន់ រីឯការបញ្ជូនទៅឲ្យបុគ្គលដែលកំពុងជាប់ពន្ធនាគារត្រូវធ្វើទៅចំពោះប្រធានពន្ធនាគារ។[36]

## ៣. របាយការណ៍អំពីការបញ្ជូន

### ៣.១. គំរូរបាយការណ៍អំពីការបញ្ជូន

របាយការណ៍អំពីការបញ្ជូន ដែលត្រូវបានប្រើប្រាស់នៅក្នុងការអនុវត្តជាក់ស្តែង គឺមាននូវចំណុចដូចខាងក្រោម៖

-កាលបរិច្ឆេទផ្ញើចេញ, លេខសំណុំរឿង, ឈ្មោះឯកសារដែលត្រូវបានបញ្ជូន, អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន និងឈ្មោះជនដែលត្រូវទទួលការបញ្ជូន។

-ហត្ថលេខាឬស្នាមម្រាមដៃអ្នកទទួលឯកសារបញ្ជូនជាក់ស្តែង។

-ទីកន្លែងដែលបានធ្វើការបញ្ជូននិងកាលបរិច្ឆេទនៃការបញ្ជូន។

[35] ក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦ មាត្រា២៥៧

[36] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា២៥៨

-វិធីដាក់ស្តែងក្នុងការបញ្ជូន។

-កាលបរិច្ឆេទធ្វើរបាយការណ៍ ឈ្មោះ និងហត្ថលេខាងអ្នកធ្វើរបាយការណ៍។

## ៣.២. ការបំពេញរបាយការណ៍អំពីការបញ្ជូន

របាយការណ៍អំពីការបញ្ជូនក្រោយពេលអនុវត្តការបញ្ជូនរួចហើយមន្ត្រីទទួលបន្ទុកប្រតិបត្តិកិច្ចការបញ្ជូន ត្រូវបំពេញឲ្យបានច្បាស់លាស់នូវកិច្ចដូចខាងក្រោមៈ

- កាលបរិច្ឆេទធ្វើរចេញ មន្ត្រីទទួលបន្ទុកប្រតិបត្តិកិច្ចការបញ្ជូនបានទទួលឯកសារ និង របាយការណ៍អំពីការបញ្ជូនពីមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន
- លេខសំណុំរឿងត្រូវបំពេញទាក់ទង នឹង លេខសំណុំរឿងដែលស្ថិតក្នុងនីតិវិធីដែលត្រូវបានធ្វើការបញ្ជូនដើម្បីដាក់បញ្ចូលរបាយការណ៍អំពីការបញ្ជូនក្នុងសំណុំរឿងនោះ
- ឈ្មោះឯកសារដែលត្រូវបានបញ្ជូន ត្រូវសរសេរឈ្មោះឯកសារដែលត្រូវធ្វើការបញ្ជូន
- អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូនត្រូវសរសេរពីតុលាការដែលមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនស្ថិតនៅ
- ឈ្មោះជនដែលត្រូវទទួលការបញ្ជូន គឺជនដែលពាក់ព័ន្ធនឹងនីតិវិធីអាចជាដើមចោទ, ចុងចម្លើយ ជាអាទិ៍ដែលមានបញ្ជាក់អំពីអត្តសញ្ញាណ ច្បាស់លាស់ដើម្បីទទួលយកឯកសារបញ្ជូន
- ហត្ថលេខា ឬស្នាមម្រាមដៃអ្នកទទួលឯកសារជាក់ស្តែង គឺជនដែលទទួលយកឯកសារបញ្ជូនដោយផ្ទាល់អាចជាភាគីដែលត្រូវទទួលឯកសារការបញ្ជូន ឬ អ្នកផ្សេងដែលមានលក្ខណៈសម្បត្តិសមរម្យគ្រប់គ្រាន់ដែលច្បាប់បានកំណត់ដែលអាចទទួលយកឯកសារ បញ្ជូនបាន
- ទីកន្លែងដែលបានធ្វើការបញ្ជូនគឺជាទីកន្លែងដែលមន្ត្រីទទួលបន្ទុកប្រតិបត្តិកិច្ចការបញ្ជូនបានធ្វើការប្រគល់ឯកសារនោះ ទៅឲ្យជនដែលត្រូវទទួលការបញ្ជូន ឬជនដែលទទួល ឯកសារជាក់ស្តែង។
- កាលបរិច្ឆេទនៃការបញ្ជូនគឺពេលដែលមន្ត្រីទទួលបន្ទុកប្រតិបត្តិកិច្ចការបញ្ជូនបានប្រគល់ឯកសារដែលត្រូវបញ្ជូន ទៅឲ្យជនដែលត្រូវទទួលការបញ្ជូន ឬអ្នកទទួលឯកសារជាក់ស្តែង។
- កាលបរិច្ឆេទធ្វើរបាយការណ៍នៅពេលដែលមន្ត្រីទទួលបន្ទុកប្រតិបត្តិកិច្ចការបញ្ជូនបានបញ្ជូនឯកសារបញ្ជូនរួចហើយត្រូវធ្វើរបាយការណ៍បញ្ជូន។
- ឈ្មោះ និង ហត្ថលេខាអ្នកធ្វើរបាយការណ៍ មន្ត្រីប្រតិបត្តិកិច្ចការបញ្ជូន ដែលធ្វើការបញ្ជូនត្រូវចុះហត្ថលេខានិងឈ្មោះនៅក្នុងរបាយការណ៍បញ្ជូនរបស់ខ្លួន។

**វិធីជាក់ស្តែងក្នុងការបញ្ជូន** គឺនៅក្នុងទម្រង់ដែលត្រូវបំពេញករណីជាក់ស្តែងរួមមាន **៣** (**បី**) ចំណុច ដែលពាក់ព័ន្ធនឹងវិធីនៃការបញ្ជូនរួមមាន៖

**ចំណុចទី១៖** ការប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ (**ហៅថាការបញ្ជូនដោយការប្រគល់ និងការបញ្ជូនដោយជួបប្រទះ**) ។

**ចំណុចទី២៖** ការប្រគល់ឯកសារទៅអ្នកដែលមានការយល់ដឹងសមរម្យចំពោះការទទួលយកឯកសារនេះ ព្រោះមិនបានជួបអ្នកដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់នៅទីកន្លែងដែលត្រូវបញ្ជូននោះទេប៉ុន្តែបានជួបនឹង ប្រគល់ឲ្យទៅអ្នកបម្រើ, អ្នកផ្សេងដែលធ្វើការនៅទីនោះ ឬ អ្នកនៅជាមួយដោយត្រូវបំពេញឈ្មោះបុគ្គលដែល បានទទួលឯកសារជាក់ស្តែងនេះ (**ហៅថាការបញ្ជូនដោយបង្គ្រប់កិច្ច**) ។

**ចំណុចទី៣៖** ឯកសារត្រូវបានទុកនៅទីកន្លែងដែលត្រូវធ្វើការបញ្ជូនដោយហេតុថាបុគ្គលដែលត្រូវទទួល ការបញ្ជូនដោយអ្នកបម្រើអ្នកនៅជាមួយ អ្នកផ្សេងដែលធ្វើការនៅទីនោះមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុ ផលសមរម្យ និង ត្រូវសរសេរឈ្មោះបុគ្គលនោះផងដែរ (**ហៅថាការបញ្ជូនដោយទុកចោល**) ។

**កំណត់សម្គាល់៖** នៅក្នុងគំរូបាយការណ៍អំពីការបញ្ជូនក្នុងការអនុវត្តជាក់ស្តែងពុំមានកំណត់អំពី ចំណុចដែលជាវិធីនៃការបញ្ជូនទៅបរទេស និង ការបញ្ជូនតាមការផ្សាយជាសាធារណៈនោះទេដោយនៅក្នុង ការអនុវត្តជាក់ស្តែងការបញ្ជូនតាមការផ្សាយជាសាធារណៈគឺ **មន្ត្រីក្រឡាបញ្ជី** មិនបានធ្វើរបាយការណ៍អំពី ការបញ្ជូននោះទេ គឺគ្រាន់តែយកនូវលិខិតជូនដំណឹងអំពីការបញ្ជូនតាមការផ្សាយជាសាធារណៈទៅរក្សាទុក នៅក្នុងសំណុំរឿងតែម្តងដោយមិនធ្វើរបាយការណ៍បញ្ជូននោះទេ។

# ជំពូកទី៣

# ការវិភាគប្រៀបធៀបរវាងការ
# អនុវត្តជាក់ស្តែងដែលរកឃើ
# ញជាមួយទ្រឹស្តីច្បាប់គតិយុត្ត

# ជំពូកទី៣
# ការវិភាគប្រៀបធៀបរវាងការអនុវត្តជាក់ស្តែងដែលរកឃើញជាមួយទ្រឹស្តីច្បាប់គតិយុត្ត

ក្រោយពីបានសិក្សាលើទ្រឹស្តីច្បាប់ និង ការអនុវត្តជាក់ស្តែងដែលបានរៀបរាប់នៅក្នុងសារណានៅក្នុងជំពូកទី១ និងជំពូកទី២ រួចមកគឺបានធ្វើការសិក្សា និង រកឃើញថាមានចំណុចសំខាន់ៗជាច្រើនដែលមានលក្ខណៈច្បាស់លាស់ និង ចំណុចមួយចំនួននៅមិនទាន់មានការជួបប្រទះក្នុងការអនុវត្តជាក់ស្តែងស្របតាមច្បាប់កំណត់នៅឡើយទេហើយចំណុចខ្លះទៀតក៏មិនទាន់មានការឯកភាពគ្នាទាំងស្រុងតាមការអនុវត្តនីតិវិធីនៅឡើយដែរ។ ដែលជាមូលហេតុក្នុងការគួរយកមកពិចារណាដើម្បីរកដំណោះស្រាយសមស្របមួយក្នុងការអនុវត្តច្បាប់ឲ្យមានភាពល្អប្រសើរនិងត្រឹមត្រូវទៅតាមច្បាប់កំណត់។ ខាងក្រោមនេះគឺជាចំណុចសំខាន់ដែលត្រូវលើកយកមកសិក្សាក្នុងការវិភាគប្រៀបធៀប រវាងការអនុវត្តជាក់ស្តែង ដែលរកឃើញជាមួយទ្រឹស្តីច្បាប់គតិយុត្ត អំពីចំណុចណាខ្លះដែលបានអនុវត្តសមស្របតាមច្បាប់កំណត់ និង ចំណុចណាខ្លះដែលមិនទាន់អនុវត្តបានសមស្របតាមច្បាប់កំណត់នៅឡើយ ។

## ១. ភាពត្រឹមត្រូវក្នុងការអនុវត្តច្បាប់ក្នុងនីតិវិធីបញ្ជូន

### ១.១. មន្ត្រីដែលធ្វើការបញ្ជូន

#### ១.១.១. មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន

មន្ត្រីដែលទទួលបន្ទុកកិច្ចការបញ្ជូន គឺបានបំពេញតួនាទីរបស់នាទីរបស់ខ្លួនបានល្អស្របទៅតាមច្បាប់កំណត់ក្នុងតួនាទីគឺការផ្ញើ ឬ ការផ្តល់សេចក្តីបញ្ជាក់នូវឯកសារសម្រាប់ប្រើក្នុងការបញ្ជូនហើយប្រគល់ឯកសារ និង អំណាចនៃការបញ្ជូនឯកសារនោះទៅឲ្យមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន និង ទទួលរបាយការណ៍អំពីការបញ្ជូនដាក់រក្សាទុកក្នុងសំណុំរឿង។ ដែលនៅក្នុងនេះផងដែរការអនុវត្តការងារដែលមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន (មន្ត្រីក្រឡាបញ្ជី) គឺបានយល់ច្បាស់អំពីឯកសារដែលត្រូវផ្ញើនីតិវិធីនៃការបញ្ជូនហើយក៏បានធ្វើការរៀបចំឲ្យមានរបាយការណ៍អំពីការបញ្ជូន ដើម្បីដាក់បញ្ចូលក្នុងសំណុំរឿងនៅពេលដែលមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនបានប្រតិបត្តិការបញ្ជូនរួចហើយ។ ដូច្នេះចំពោះការអនុវត្តការងាររបស់មន្ត្រីដែលទទួលបន្ទុកកិច្ចការបញ្ជូនគឺមានភាពត្រឹមត្រូវស្របតាមច្បាប់កំណត់។ នីតិវិធីនៃការបញ្ជូន និងធ្វើការប្រគល់របាយការណ៍អំពីការបញ្ជូននៅពេលដែលបានប្រតិបត្តិការបញ្ជូនរួចហើយព្រមទាំងធ្វើការពិនិត្យ និង បានទទួលនូវរបាយការណ៍អំពីបញ្ជូននោះដើម្បីរក្សាទុកក្នុងសំណុំរឿង។

### ១.១.២. មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន

មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនដែលច្បាប់កំណត់រួមមានដូចជា **បុគ្គលិកប្រៃសណីយ៍ អាជ្ញាសាលា និង ក្រឡាបញ្ជី** ប៉ុន្តែសម្រាប់ការអនុវត្តជាក់ស្តែង មន្ត្រីដែលទទួលបន្ទុកប្រតិបត្តិការបញ្ជូនមានតែបុគ្គលិកប្រៃសណីយ៍ និង ក្រឡាបញ្ជី តែប៉ុណ្ណោះដែលបានអនុវត្តកិច្ចការប្រតិបត្តិការបញ្ជូននេះ។ ការអនុវត្តការងារជាក់ស្តែងមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន (ក្រឡាបញ្ជី) គឺគ្រាន់តែប្រគល់នូវអំណាចក្នុងការបញ្ជូននេះទៅឲ្យបុគ្គលិកប្រៃសណីយ៍ និង ក្រឡាបញ្ជីខ្លួនឯង ក៏ដំណើរការនីតិវិធីនៃការបញ្ជូននេះមានលក្ខណៈគ្រប់គ្រាន់ដែលអាចទទួលយកបានស្របទៅតាមច្បាប់កំណត់ហើយអាចបន្តនីតិវិធីបានធម្មតាដោយគ្មានបញ្ហាចោទណាមួយកើតឡើងឡើយច្បាប់ក៏មិនបានចងនូវកាតព្វកិច្ច តម្រូវឲ្យមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន ត្រូវតែប្រគល់ការងារប្រតិបត្តិការបញ្ជូន ទៅគ្រប់មន្ត្រីទទួលប្រតិបត្តិការបញ្ជូនទាំងអស់អនុវត្តគ្រប់គ្នាដែរ គឺអាស្រ័យលើសិទ្ធិអំណាចក្នុងការចាត់ចែងរបស់មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនជាអ្នកចាត់ចែង។ ហេតុដូច្នេះទោះបីជាមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនមានតែ បុគ្គលិកប្រៃសណីយ៍ និង ក្រឡាញ្ជី ដែលបានអនុវត្តកិច្ចការបញ្ជូននេះក៏ដោយក៏ការអនុវត្ត មានលក្ខណៈល្អប្រសើរដែលអាចទទួលយកបាន ដោយគ្មានបញ្ហាចោទណាមួយដែលមានការខុសទៅនឹងលក្ខខណ្ឌដែលច្បាប់កំណត់នោះទេ។ ដើម្បីសិក្សាអំពីភាពត្រឹមត្រូវក្នុងការអនុវត្តកិច្ចការបញ្ជូនរបស់មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនដែលបានអនុវត្តកិច្ចការបញ្ជូនថា មានការអនុវត្តស្របទៅតាមច្បាប់កំណត់យ៉ាងដូចម្តេចនោះ? គឺត្រូវធ្វើការសិក្សាលើការអនុវត្តតួនាទីរបស់មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនដែលអនុវត្តដូចខាងក្រោម៖

#### ១.១.២.១. ក្រឡាបញ្ជី

ក្រឡាបញ្ជី គឺជាមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនផង និង ជាមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនផង។ ការអនុវត្តរបស់ក្រឡាបញ្ជី ក្នុងតួនាទីជាមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន គឺបានអនុវត្តតួនាទីនេះបានល្អដោយបានយល់ច្បាស់នូវឯកសារណាដែលត្រូវធ្វើនីតិវិធីនៃការបញ្ជូន និង រៀបចំនូវសេចក្តីបញ្ជាក់នូវឯកសារសម្រាប់ប្រើក្នុងការបញ្ជូនដោយបានប្រគល់ឯកសារ នៃការបញ្ជូននោះ ទៅឲ្យមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន។ ករណីដែលមន្ត្រីក្រឡាបញ្ជីបានអនុវត្តការងារក្នុងនាម ជាមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន គឺក្រោយពីបានទទួលបានឯកសារដែលត្រូវធ្វើការបញ្ជូនរួចហើយ គឺបានអនុវត្តការបញ្ជូនឯកសារនោះទៅឲ្យបុគ្គលដែលត្រូវទទួលការបញ្ជូនតាមវិធីផ្សេងៗដែលបានកំណត់ដោយច្បាប់ក្នុងការអនុវត្តជាក់ស្តែង និង បានរៀបចំជារបាយការណ៍អំពីការបញ្ជូនរក្សាទុកក្នុងសំណុំរឿងបានយ៉ាងត្រឹមត្រូវស្របតាមច្បាប់កំណត់។

#### ១.១.២.២. បុគ្គលិកប្រៃសណីយ៍

បុគ្គលិកប្រៃសណីយ៍ គឺជាមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនដែលក្នុងការអនុវត្តជាក់ស្ដែង ក្រោយពីទទួលបានឯកសារបញ្ជូន ពីមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនរួចហើយ បានធ្វើការបញ្ជូនឯកសារនោះទៅឲ្យអ្នកដែលត្រូវទទួលការបញ្ជូនស្របតាមការណែនាំរបស់មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន និង បានធ្វើជារបាយការណ៍អំពីការបញ្ជូននៅពេលដែលបានបញ្ជូន ឯកសារបញ្ជូនទៅឲ្យបុគ្គលដែលទទួលការបញ្ជូនរួចហើយ និង ធ្វើការប្រគល់របាយការណ៍បញ្ជូននោះ ទៅឲ្យមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន ដើម្បីដាក់របាយការណ៍នោះដើម្បីរក្សាទុកក្នុងសំណុំរឿង។

## ១.២. វិធីបញ្ជូន និងការធ្វើរបាយការណ៍បញ្ជូន

### ១.២.១. វិធីបញ្ជូន

វិធីបញ្ជូនដែលច្បាប់កំណត់គឺមាន ៦ (ប្រាំមួយ) វិធី ដែលអាចឲ្យមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនប្រើប្រាស់ក្នុងការបញ្ជូនបានមានដូចជា ការបញ្ជូនដោយការប្រគល់,ការបញ្ជូនដោយបង្គ្រប់កិច្ច,ការបញ្ជូនដោយទុកចោល ការបញ្ជូនដោយជួបប្រទះ ការបញ្ជូននៅបរទេស និង ការបញ្ជូនតាមការផ្សាយជាសាធារណៈ ប៉ុន្តែសម្រាប់ការអនុវត្តជាក់ស្ដែង មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនពុំបានប្រើប្រាស់វិធីបញ្ជូនដែលច្បាប់បានកំណត់អស់នោះទេ។ សម្រាប់ការអនុវត្តវិធីដែលបានយកមកអនុវត្តក្នុងការបញ្ជូន គឺមានភាពត្រឹមត្រូវច្រើនដែលសមស្របតាមលក្ខខណ្ឌច្បាប់កំណត់នូវ វិធីនៃការបញ្ជូន នេះដែលត្រូវបានយកមកអនុវត្តនៅក្នុងសាលាដំបូងខេត្តព្រះសីហនុដែលពាក់ព័ន្ធ នឹង ដំណើរការនីតិវិធីនៃការបញ្ជូនក្នុងរឿងក្ដីរដ្ឋប្បវេណីដែលបានជួបប្រទះនៅពេលចុះកម្មសិក្សា។ ចំពោះវិធីនៃការបញ្ជូនមួយចំនួនទៀតក៏មិនបានជួបប្រទះនៅក្នុងការអនុវត្តក្នុងដំណើរការនីតិវិធីនៃការបញ្ជូននៅឡើយដោយសារករណីនេះមិនមែនមកពីមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនមិនបានប្រើវិធីនៃការបញ្ជូនទាំងនេះដែលមិនស្របតាមច្បាប់កំណត់នោះទេ គឺមកពីការអនុវត្តមិនទាន់មានការជួបប្រទះនូវលក្ខខណ្ឌតាមផ្លូវច្បាប់ដែលតម្រូវឲ្យ ប្រើនូវវិធីនៃការបញ្ជូននោះសម្រាប់ធ្វើការបញ្ជូនក្នុងនោះរួមមានការបញ្ជូនទៅបរទេស និង ការបញ្ជូនដោយទុកចោលដែលវិធីទាំងពីរនេះសម្រាប់អនុវត្តនៅសាលាដំបូងខេត្តព្រះសីហនុដែលបានសិក្សាក្នុងអំឡុងពេលកម្មសិក្សានេះពុំត្រូវបានយកមកអនុវត្តនោះទេ។

### ១.២.២. ការធ្វើរបាយការណ៍អំពីការបញ្ជូន

ការធ្វើរបាយការណ៍បញ្ជូន គឺមានការអនុវត្តបានត្រឹមត្រូវតាមច្បាប់ដោយនៅក្រោយពេលដែលមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនបានអនុវត្តការបញ្ជូនរួចហើយមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនការធ្វើរបាយការណ៍នៃការបញ្ជូនស្របតាមទម្រង់ ដែលបានផ្ដល់ឲ្យដោយមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនរួចហើយ

ប្រគល់ឲ្យមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនដើម្បីរក្សាទុកក្នុងសំណុំរឿងដែលនេះជាការអនុវត្តបានល្អស្របទៅតាមច្បាប់កំណត់ដោយពុំមានការអនុវត្តណាមួយដែលត្រូវបានអនុវត្តហើយមិនបានធ្វើជារបាយការណ៍បញ្ជូននោះទេ។

# ២. នីតិវិធីនៃការបញ្ជូនដែលមិនទាន់បានអនុវត្ត និង ចំណុចខ្វះខាតក្នុងការអនុវត្ត

## ២.១. ស្ថាប័នដែលមិនបានបំពេញកិច្ចនីតិវិធីនៃការបញ្ជូន

ស្ថាប័នដែលមិនបានបំពេញកិច្ចនីតិវិធីនៃការបញ្ជូន គឺមន្ត្រីអាជ្ញាសាលា ដោយសារមន្ត្រីអាជ្ញាសាលានៅសាលាដំបូងខេត្តព្រះសីហនុ មានភាពមមាញឹកច្រើនក្នុងរឿងអនុវត្តដោយបង្ខំចំពោះចលនវត្ថុ អចលនវត្ថុ និងអនុវត្តក្នុងរឿងរក្សាការពារ។ ទើបមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន (ក្រឡាបញ្ជី) មិនបានប្រគល់កិច្ចការនេះទៅឲ្យអាជ្ញាសាលាក្នុងការបញ្ជូនឯកសារ នៃការបញ្ជូនក្នុងរឿងក្តីរដ្ឋប្បវេណីឡើយដែលការចាត់ចែងនេះនាំឲ្យមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនដែលមាន អាជ្ញាសាលា មិនបានប្រតិបត្តិការបញ្ជូនក្នុងនាមជាមន្ត្រីទទួលបន្ទុកប្រតិបត្តិកិច្ចការបញ្ជូននេះ។ តែទោះបីជាច្បាប់ចែងអំពីមុខងារ និងតួនាទីនៃការប្រតិបត្តិការបញ្ជូនក៏ដោយតែបើមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនមិនបានប្រគល់សិទ្ធិអំណាចក្នុងការប្រតិបត្តិការបញ្ជូនមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនក៏នៅតែមិនអាចបំពេញការអនុវត្តក្នុងតួនាទីជាមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន បានដែលដោយសារនេះជាសិទ្ធិអំណាចរបស់ មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនជាអ្នកចាត់ចែង។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយសម្រាប់ការអនុវត្តជាក់ស្តែងទោះបីជាអាជ្ញាសាលាមិនត្រូវបានចាត់ចែងឲ្យធ្វើការប្រតិបត្តិការបញ្ជូនក៏ដោយ ក៏នីតិវិធីនៃការបញ្ជូននេះត្រូវបានអនុវត្តដោយមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនផ្សេងទៀតដូចជាបុគ្គលិកប្រៃសណីយ៍ និងក្រឡាបញ្ជី ក៏ដំណើរការនីតិវិធីនៃការបញ្ជូនប្រព្រឹត្តទៅបានក្នុងដំណើរការនីតិវិធីនៃការបញ្ជូននេះជាធម្មតាដោយពុំមានបញ្ហាខាងនីតិវិធីណាមួយកើតឡើងឡើយហើយការចាត់ចែងនេះក៏ជាសិទ្ធិអំណាចរបស់មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនជាអ្នកចាត់ចែង។

## ២.២. វិធីបញ្ជូន និង ការបំពេញរបាយការណ៍នៃការបញ្ជូន

### ២.២.១. វិធីបញ្ជូន

វិធីបញ្ជូនដែលមិនត្រូវបានអនុវត្តតាមច្បាប់កំណត់នៅក្នុងការអនុវត្តជាក់ស្តែងគឺវិធីនៃការបញ្ជូននៅបរទេស និង ការបញ្ជូនដោយទុកចោលដែលនៅមិនទាន់បានជួបប្រទះក្នុងការអនុវត្តនៅឡើយសម្រាប់រយៈពេលកម្មសិក្សានេះដោយសារតែក្នុងនីតិវិធីនៃការបញ្ជូននេះពុំទាន់មានករណីដែលត្រូវក្នុងលក្ខខណ្ឌដែលច្បាប់កំណត់ក្នុងស្ថានភាពជាក់ស្តែងដែលត្រូវអនុវត្តវិធីនៃការបញ្ជូននេះហេតុនេះហើយទើបការអនុវត្តនូវវិធីនៃការបញ្ជូននេះមិនត្រូវបានយកមកប្រើក្នុងដំណើរការនីតិវិធីសម្រាប់វិធីនៃការបញ្ជូននេះបាន។

### ២.២.២. ការបំពេញរបាយការណ៍អំពីការបញ្ជូន

របាយការណ៍អំពីការបញ្ជូន គឺនៅពេលដែលមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនបានប្រតិបត្តិការបញ្ជូនរួចហើយត្រូវតែរៀបចំធ្វើរបាយការណ៍អំពីកាបញ្ជូនសម្រាប់ប្រគល់ឲ្យមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនដើម្បីរក្សាទុកនូវរបាយការណ៍នោះទុកក្នុងសំណុំរឿង។ ប៉ុន្តែទោះបីជារបាយការណ៍អំពីការបញ្ជូនត្រូវបានធ្វើឡើងដោយមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនហើយក៏ដោយក៏នៅតែមានចំណុចខ្វះខាតមួយចំនួនទាក់ទងនឹងភាពខ្វះខាតក្នុងការបំពេញនូវទម្រង់ក្នុងរបាយការណ៍អំពីការបញ្ជូន។ ដែលក្នុងនៅសម្រាប់ការអនុវត្តការងារនៃការបំពេញនូវទម្រង់របាយការណ៍អំពីការបញ្ជូននៅមិនទាន់មានការយល់ឃើញដូចគ្នានោះទេ។ នៅក្នុងរបាយការណ៍អំពីបញ្ជូនចំពោះវិធីនៃការបញ្ជូនក៏មិនបានរៀបចំនូវិធីនៃការបញ្ជូនឲ្យបានគ្រប់ចំនួននៅឡើយនាំឲ្យវិធីនៃការបញ្ជូនខ្លះនៅមានភាពមិនទាន់ច្បាស់លាស់នៅឡើយដូចជាវិធីទី១ នៃវិធីជាក់ស្តែងក្នុងការបញ្ជូន[37] គឺ វិធីនៃការបញ្ជូនដោយការប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃដែលជាវិធីនៃការបញ្ជូនហៅថាការបញ្ជូនដោយការប្រគល់ ឬ វិធីបញ្ជូនដោយការជួបប្រទះនេះគឺជាភាពមិនច្បាស់លាស់នៃការចែកឲ្យបានដាច់ពីគ្នានៅក្នុងគំរូនៃរបាយការណ៍អំពីការបញ្ជូននៅឡើយ។ ម្យ៉ាងវិញទៀតវិធីនៃការបញ្ជូននៅបរទេស និង វិធីនៃការបញ្ជូនតាមការផ្សាយតាមរយៈដែលវិធីនៃការបញ្ជូនទាំងពីរនេះមិនមានក្នុងគំរូនៃរបាយការណ៍អំពីការបញ្ជូននោះទេចំពោះការអនុវត្តជាក់ស្តែងនៅពេលមានការបញ្ជូនតាមការផ្សាយជាសាធារណៈ គឺ មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន (ក្រឡាបញ្ជី) មិនបានធ្វើរបាយការណ៍អំពីការបញ្ជូននោះទេគឺយកលិខិតជូនដំណឹងអំពីការបញ្ជូនតាមការផ្សាយជាសាធារណៈ[38] ដាក់បញ្ចូលក្នុងសំណុំរឿងជំនួសឲ្យការធ្វើរបាយការណ៍បញ្ជូន។ រីឯវិធីនៃការបញ្ជូននៅបរទេសក៏ពុំមាននៅក្នុងគំរូនៃរបាយការណ៍អំពីការបញ្ជូនក្នុងការអនុវត្តជាក់ស្តែងនៅពេលធ្វើការចាត់ចែងការបញ្ជូនទៅឲ្យបុគ្គលិកប្រៃសណីយ៍ទៀតសោតដែលជាមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនដែរនោះបានប្រគល់ឲ្យនូវរបាយការណ៍អំពីការបញ្ជូនដែរហើយការអនុវត្តក៏មិនទាន់បានធ្លាប់អនុវត្តនៅឡើយ។ មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនក្នុងការអនុវត្តជាក់ស្តែង នៅពេលធ្វើការចាត់ចែងការបញ្ជូនទៅឲ្យបុគ្គលិកប្រៃសណីយ៍ទៀតសោតដែលជាមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូននោះបានប្រគល់ឲ្យនូវរបាយការណ៍អំពីការបញ្ជូនទៅឲ្យបុគ្គលិកប្រៃសណីយ៍ធ្វើការបំពេញនូវរបាយការណ៍អំពីការបញ្ជូននោះទេសម្រាប់ការអនុវត្តរបស់មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនសម្រាប់បំពេញនូវរបាយការណ៍ អំពីការបញ្ជូននោះទេសម្រាប់ការអនុវត្តរបស់មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនសម្រាប់ការអនុវត្តខ្លះ គឺគ្រាន់តែប្រគល់នូវឯកសារនៃការបញ្ជូនទៅឲ្យបុគ្គលិកប្រៃសណីយ៍រួចហើយ រីឯចំពោះ

[37] ឧបសម្ព័ន្ធទី៣៖ គំរូរបាយការណ៍បញ្ជូន

[38] ឧបសម្ព័ន្ធទី២៖ លិខិតជូនដំណឹងអំពីការបញ្ជូនតាមការផ្សាយជាសាធារណៈ

ការធ្វើរបាយការណ៍អំពីការបញ្ជូនវិញមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនជាអ្នកធ្វើរបាយការណ៍ដោយខ្លួនឯងនេះជាការអនុវត្តមិនទាន់បានត្រឹមត្រូវនៅឡើយប៉ុន្តែការអនុវត្តនេះមិនមែនមានលក្ខណៈជាទូទៅនោះទេ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាទៅលើជំពូកទាំងបីនៃរបាយការណ៍ស្តីអំពីការបញ្ជូនក្នុងនីតិវិធីនៃការបញ្ជូនលើកទី១ រួចមកគឺផ្តល់នូវសារៈសំខាន់ជាច្រើនដែលទទួលបានពីការសិក្សា និង ស្វែងយល់នៅក្នុងដំណើរការនីតិវិធីនៃការបញ្ជូននេះម្យ៉ាងវិញទៀតបានធ្វើឲ្យយើងយល់កាន់តែច្បាស់ទាំងផ្នែកទ្រឹស្តី និងការអនុវត្តការងារជាក់ស្តែងក្នុងវិស័យការងារផ្នែកច្បាប់។ ឃើញថាបែបបទការងារនៃ"**ការបញ្ជូនក្នុងនីតិវិធីជំនុំជម្រះលើកទី១**" ដែលបានអនុវត្តរួចកន្លងមក គឺអនុវត្តមានលក្ខណៈល្អប្រសើរ។ ដែលធ្វើឲ្យយើងខ្ញុំបានការយល់កាន់តែច្បាស់ទៅលើកិច្ចការនៃការអនុវត្តនីតិវិធីនៃការបញ្ជូនកាន់តែច្បាស់។ បន្ទាប់ពីបានចូលរួមសិក្សាដោយផ្ទាល់ក្នុងការអនុវត្តវិស័យការងារផ្នែកច្បាប់នៅសាលាដំបូងខេត្តព្រះសីហនុ រួចមកឃើញថា ដើម្បីឲ្យការអនុវត្តនូវដំណើរការនីតិវិធីនៃការបញ្ជូនមានលក្ខណៈត្រឹមត្រូវស្របទៅតាមច្បាប់កំណត់។ មន្ត្រីដែលទទួលបន្ទុកកិច្ចការបញ្ជូនគប្បីត្រូវយល់ឲ្យបានច្បាស់ជាមុននូវឯកសារដែលត្រូវធ្វើការបញ្ជូន។ ការរៀបចំនិងចាត់ចែងការបញ្ជូននេះត្រូវប្រគល់ឲ្យទៅមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនដើម្បីអនុវត្តព្រមទាំងប្រាប់អំពីវិធីនៃការបញ្ជូនដើម្បីណែនាំដល់មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន ពីការអនុវត្តន៍ការងារ នៅពេលធ្វើការបញ្ជូនឯកសារដើម្បីឲ្យការបញ្ជូននេះធ្វើឡើងត្រឹមត្រូវ និង ត្រូវណែនាំផងដែរក្នុងការធ្វើរបាយការណ៍បញ្ជូននៅពេលដែលឯកសារនៃការបញ្ជូននោះបញ្ជូនទៅដល់បុគ្គលដែលត្រូវទទួលឯកសារការបញ្ជូន។ រីឯមន្ត្រីទទួលបន្ទុកប្រតិបត្តិការវិញគប្បីយល់ឲ្យបានច្បាស់ពីកិច្ចការរបស់ខ្លួនដូចជានៅពេលដែលទទួលបានឯកសារនៃការបញ្ជូន និង របាយការណ៍នៃការបញ្ជូនពីមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនរួចហើយ គឺត្រូវអនុវត្តតាមការណែនាំស្របតាមច្បាប់កំណត់ដោយត្រូវយល់ពីសញ្ញាណនៃការបញ្ជូនរួមមាន បុគ្គលដែលត្រូវទទួលការបញ្ជូននូវឯកសារនោះ វិធីដែលត្រូវបញ្ជូននិងត្រូវយល់ដឹងពីការធ្វើរបាយការណ៍បញ្ជូននៅពេលដែលបានអនុវត្តការបញ្ជូនរួចហើយព្រមទាំងប្រគល់នូវរបាយការណ៍បញ្ជូននោះមកឲ្យមន្ត្រីទទួលបន្ទុក កិច្ចការបញ្ជូនវិញ ។

នៅក្នុងការអនុវត្តជាក់ស្តែងដែលបានជួបប្រទះទោះបីជានីតិវិធីនៃការបញ្ជូនបានអនុវត្តបានត្រឹមត្រូវស្របតាមច្បាប់កំណត់ក៏ដោយក៏នៅតែមានមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន និង មន្ត្រីទទួលបន្ទុកប្រតិបត្តិការដែលបានអនុវត្តការងារនៅតែមានចំណុចខ្វះខាតមួយចំនួនដែលអនុវត្តមិនទាន់សមស្របតាមការកំណត់របស់ច្បាប់ទាំងស្រុងនៅឡើយដោយសារតែមិនទាន់យល់ច្បាស់នូវចំណុចសំខាន់ៗដែលបានកំណត់ដោយច្បាប់នៅពេលអនុវត្តដូចដែលបានរៀបរាប់ខាងលើ។ ប៉ុន្តែចំណុចខ្វះខាតដែលបានលើកឡើងនៅក្នុងសារណានេះគឺមានលក្ខណៈតិចតួចប៉ុណ្ណោះដែលការអនុវត្តមិនទាន់បានត្រឹមត្រូវ។ ភាគច្រើន គឺអនុវត្តបានសមស្របទៅតាមច្បាប់កំណត់បានត្រឹមត្រូវដែលធ្វើឲ្យយើងខ្ញុំការទទួលបាននូវបទពិសោធន៍ជាច្រើនក្នុងការអនុវត្តជាក់ស្តែង

ក្នុងនីតិវិធីនៃការបញ្ជូននឹងដើម្បីយកមកសិក្សាស្វែងយល់ឲ្យបានច្បាស់ពីដំណើរការបញ្ជូនក្នុងនីតិវិធីជំនុំជម្រះលើកទី១។

បន្ទាប់ពីបានចូលរួមសិក្សាដោយផ្ទាល់លើការអនុវត្តរួចមកធ្វើឲ្យយើងខ្ញុំមានការយល់ដឹងច្បាស់លាស់ជាងមុនពីការអនុវត្តច្បាប់ និងចំណុចមួយចំនួនធំដែលមាននៅក្នុងទ្រឹស្តីច្បាប់ដែលបានបង្ហាញឲ្យឃើញតាមរយៈការចូលរួមសិក្សាលើការអនុវត្តច្បាប់នៅសាលាដំបូងខេត្តព្រះសីហនុ ពាក់ព័ន្ធនឹងដំណើរការបញ្ជូនក្នុងនីតិវិធីជំនុំជម្រះលើកទី១នេះ។ រីឯចំណុចនៃការអនុវត្តនៅមានចំណុចខ្វះចន្លោះមួយចំនួនក៏ត្រូវបានលើកយកមកសិក្សាផងដែរឃើញថាមានលក្ខណៈ មិនទាន់បានអនុវត្តឲ្យបានពេញលេញសមស្របតាមកំណត់របស់ច្បាប់នៅឡើយរួមមានទាំងការមិនបានឲ្យ មន្ត្រីអាជ្ញាសាលា អនុវត្តការងារជាមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន និងវិធីនៃការបញ្ជូនមួយចំនួនដោយសារការមិនបានជួបប្រទះលើការអនុវត្តជាក់ស្តែងដែលនាំឲ្យការស្វែងយល់ពីដំណើរការនីតិវិធីនេះមិនទាន់ទទួលបានចំណេះដឹងក្នុងការអនុវត្តនៅឡើយ។ ចំណុចសំខាន់មួយទៀតគឺការធ្វើរបាយការណ៍បញ្ជូនក៏នៅមានភាពខ្វះចន្លោះមួយចំនួនដែលបានកើតឡើងលើការមិនបានប្រគល់នូវរបាយការណ៍បញ្ជូនទៅឲ្យមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន **(បុគ្គលិកប្រៃសណីយ៍)** ដើម្បីធ្វើការបំពេញនូវរបាយការណ៍បញ្ជូននោះ រីឯការបំពេញរបាយការណ៍ការបញ្ជូនឃើញថាការអនុវត្តមួយចំនួននៅមិនទាន់មានការបំពេញឲ្យបានត្រឹមត្រូវស្របតាមចំណុចដែលមាននៅក្នុងរបាយការណ៍នៅឡើយ។ ចំណុចដែលបានលើកឡើងទាំងនេះគឺជាភាពខ្វះចន្លោះមួយចំនួនដែលបានជួបប្រទះក្នុងអំឡុងពេលដែលបានធ្វើការចុះកម្មសិក្សាលើការងារអនុវត្តជាក់ស្តែង។

សរុបសេចក្តីមកដើម្បីឲ្យការអនុវត្តនៃដំណើរការបញ្ជូនក្នុងនីតិវិធីជំនុំជម្រះលើកទី១ មានភាពត្រឹមត្រូវស្របតាមការកំណត់របស់ច្បាប់នោះគប្បីមន្ត្រីដែលទទួលបន្ទុកកិច្ចការបញ្ជូន និងមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនត្រូវតែយល់ឲ្យបានច្បាស់អំពីចំណុចសំខាន់ៗ ដូចជាឯកសារដែលត្រូវធ្វើការបញ្ជូន, បុគ្គលដែលត្រូវទទួលការបញ្ជូន និងអាសយដ្ឋានដែលត្រូវបញ្ជូន, វិធីនៃការបញ្ជូន, ការធ្វើរបាយការណ៍នៃការបញ្ជូន និងការបំពេញរបាយការណ៍បញ្ជូន ព្រមទាំងការរក្សាទុកឲ្យបានត្រឹមត្រូវនូវរបាយការណ៍នៃការបញ្ជូននោះឲ្យបានល្អនៅក្នុងសំណុំរឿង។ ចំណុចដែលបានរៀបរាប់មកនេះ គឺជាចំណុចសំខាន់ណាស់ដើម្បីឲ្យមន្ត្រីដែលទទួលបន្ទុកកិច្ចការបញ្ជូន និង មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនអាចធ្វើការអនុវត្តការងារក្នុងនីតិវិធីនៃការបញ្ជូនបានល្អស្របតាមច្បាប់កំណត់។

# ការផ្តល់អនុសាសន៍

# ការផ្តល់អនុសាសន៍

តាមរយៈការបកស្រាយលើប្រធានបទសារណាស្តីពី "ការបញ្ជូនក្នុងនីតិវិធីជំនុំជម្រះលើកទី១" រួចមកឃើញថាការបញ្ជូននៅក្នុងរឿងក្តីរដ្ឋប្បវេណី ពិតជាមានសារៈសំខាន់ណាស់ គឺនីតិវិធីនៃការបញ្ជូនក្នុងរឿងក្តីរដ្ឋប្បវេណីអនុវត្តត្រូវគោរពនូវគោលការណ៍ចំពោះមុខ គោលការណ៍នៃការទទួលខុសត្រូវរបស់ភាគីនៃរឿងក្តី និងគោលការណ៍ស្មើភាពគ្នាចំពោះមុខច្បាប់ និងការគោរពនូវផលប្រយោជន៍របស់ភាគី និង ភាគីដែលពាក់ព័ន្ធ។ ដូចនេះយើងខ្ញុំសូមចូលរួមផ្តល់នូវអនុសាសន៍ផ្ទាល់ខ្លួនមួយចំនួន ដើម្បីជាការចូលរួមចំណែកតិចតួចក្នុងការអភិវឌ្ឍទៅលើវិស័យនេះឲ្យឆ្ពោះទៅកាន់ភាពរីកចម្រើន និងកាន់តែប្រសើរឡើងថែមមួយកម្រិតទៀត។

ទាក់ទងទៅនឹងនីតិវិធីជំនុំជម្រះលើកទី១ នៅក្នុងប្រទេសកម្ពុជាយើងសព្វថ្ងៃឃើញថាច្បាប់ និង ស្ថាប័នដែលគ្រប់គ្រងបានកំណត់ឲ្យក្រុមមន្ត្រីបច្ចេកទេសមានដូចជា **មន្ត្រីប្រៃណីយ៍ អាជ្ញាសាលា ក្រឡាបញ្ជី** ជាអ្នកធ្វើការអនុវត្តនៃការបញ្ជូននូវឯកសារដែលចេញដោយតុលាការឲ្យទៅក្រុមបុគ្គលដែលពាក់ព័ន្ធក្នុងរឿងក្តីឃើញថាការកំណត់ដែនសមត្ថកិច្ចរបស់តុលាការបែបនេះវាបង្កឲ្យមានផលរំខានដូចជាការបញ្ជូនមានការយឺតយាវវាធ្វើឲ្យខាតប្រយោជន៍បុគ្គលដែលពាក់ព័ន្ធក្នុងរឿងក្តីហេតុដូចនេះស្ថាប័នតុលាការគួរតែកំណត់ឲ្យច្បាស់លាស់ និង គួរតែផ្តល់សិទ្ធិជូនមន្ត្រីមួយចំនួនដូចជា៖

- ស្ថាប័នតុលាការគួរតែផ្តល់អត្តិភាពតាមរយៈផ្លូវរដ្ឋបាលដោយសហការជាមួយ មេភូមិ មេឃុំ ឬចៅសង្កាត់ និងមេប៉ុស្តិ៍នគរបាល ដែលជាអ្នកគ្រប់គ្រងនូវទិន្នន័យអាស័យដ្ឋានរបស់ភាគីដែលពាក់ព័ន្ធក្នុងរឿងក្តី ព្រោះវាបង្កឲ្យមានភាពងាយស្រួល ព្រមទាំងជួយកាត់បន្ថយកិច្ចការរបស់មន្ត្រីបច្ចេកទេសព្រមទាំងជំរុញឲ្យនីតិវិធីនៃការបញ្ជូនកាន់តែមានភាពងាយស្រួល និងឆាប់រហ័សថែមមួយកម្រិតទៀត។
- ស្ថាប័នពាក់ព័ន្ធគួរតែកំណត់ឲ្យបានច្បាស់លាស់អំពីសោហ៊ុយចំណាយសម្រាប់ថ្លៃធ្វើការបញ្ជូនគឺសំដៅដល់តម្លៃដែលភាគីត្រូវបង់ប្រាក់សម្រាប់ធ្វើការបញ្ជូនមន្ត្រីអនុវត្តកិច្ចការបញ្ជូនគួរចៀសវាងការទាមទារលើសចំនួនចំពោះប្រាក់ដែលបានចំណាយទៅលើការបញ្ជូនដែលជាហេតុនាំឲ្យប៉ះពាល់ផលប្រយោជន៍របស់គូភាគីនៃរឿងក្តីណាមួយ។
- ឃើញថា **បុគ្គលិកប្រៃសណីយ៍** មិនមែនជាអ្នកអនុវត្តច្បាប់នោះទេដើម្បីឲ្យពួកគាត់អាចអនុវត្តកិច្ចការបញ្ជូនបានត្រឹមត្រូវតាមច្បាប់កំណត់គួរតែបើកវគ្គបណ្តុះបណ្តាលស្តីអំពីនីតិវិធីនៃការបញ្ជូនក្នុងរឿងក្តីរដ្ឋប្បវេណីនេះឲ្យបានទូលំទូលាយចំពោះនីតិវិធីនៃការបញ្ជូនដល់បុគ្គលិកប្រៃណីយ៍ដើម្បីឲ្យពួកគាត់យល់ដឹងអំពីតួនាទីនិងភារកិច្ចព្រមទាំងសារៈសំខាន់របស់វា។បន្ថែមទៅទៀតនោះគឺជំរុញឲ្យការ

អនុវត្តនីតិវិធីនៃការបញ្ជូនកាន់តែមានប្រសិទ្ធភាពស្របទៅតាមការកំណត់ដូចមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។

- ចំណុចចុងក្រោយឃើញថាការអនុវត្តការងារជាក់ស្តែងនីតិវិធីនៃការបញ្ជូនក្នុងរឿងក្តីរដ្ឋប្បវេណីឃើញថា **ក្រឡាបញ្ជី** ពុំសូវបានយកចិត្តទុកដាក់ក្នុងការធ្វើរបាយការណ៍នៃការបញ្ជូនឡើយដោយគាត់យល់ឃើញថាឲ្យតែមានដីកាបង្វិលមកវិញគឺ ការបញ្ជូនមានលក្ខណៈត្រឹមត្រូវហើយហេតុនេះហើយបានជាគាត់មិនធ្វើរបាយការណ៍អំពីការបញ្ជូន។ ដូច្នេះនៅត្រង់ចំណុចនេះ **ក្រឡាបញ្ជី** គួរគប្បីធ្វើអោយអស់ពីលទ្ធភាពរបស់ខ្លួនទៅតាមនីតិវិធីច្បាប់ដើម្បីបង្ការចំពោះការបំពានសិទ្ធិទៅលើភាគីណាមួយនៃរឿងក្តី។

# ឯកសារយោង

# ឯកសារយោង

➢ **សៀវភៅ**

- វចនានុក្រមសម្ដេចព្រះសង្ឃ ជួន ណាត។
- ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម/ ០៧០៦/១២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។
- សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ នីតិវិធីបណ្តឹង។
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២០៧/ ០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ និង អនុវត្តទូទាំងប្រទេសនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១១។

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

**************

| | | |
|---|---|---|
| **ឧបសម្ព័ន្ធទី១** | ៖ | ពាក្យបណ្ដឹង។ |
| **ឧបសម្ព័ន្ធទី២** | ៖ | ដីកាបង្គាប់ឲ្យបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ។ |
| **ឧបសម្ព័ន្ធទី៣** | ៖ | ដីកាកោះហៅធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ |
| **ឧបសម្ព័ន្ធទី៤** | ៖ | ដីកាបញ្ជូន។ |
| **ឧបសម្ព័ន្ធទី៥** | ៖ | កំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ |
| **ឧបសម្ព័ន្ធទី៦** | ៖ | កំណត់ហេតុស្ដីពីនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។ |
| **ឧបសម្ព័ន្ធទី៧** | ៖ | ពាក្យសុំធ្វើការផ្សាយជាសាធារណៈ។ |
| **ឧបសម្ព័ន្ធទី៨** | ៖ | ដីកាសម្រេចស្ដីពីការអនុញ្ញាតឲ្យធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ។ |
| **ឧបសម្ព័ន្ធទី៩** | ៖ | លិខិតជូនដំណឹងអំពីការបញ្ជូនតាមការផ្សាយជាសាធារណៈ ។ |
| **ឧបសម្ព័ន្ធទី១០** | ៖ | របាយការណ៍អំពីការបញ្ជូន។ |

សាលាដំបូងខេត្តព្រះសីហនុ
សំណុំរឿងរដ្ឋប្បវេណីលេខៈ 171
ចុះថ្ងៃទី 24 ខែ 07 ឆ្នាំ 2019

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តព្រះសីហនុ
ចូល លេខ:...
ថ្ងៃទី២៥ ខែ០៧ ឆ្នាំ១៩
ម៉ោង:...០៣:០០...

## ពាក្យបណ្ដឹង

**ដើមចោទ:** ឈ្មោះ សយ សុភាព ភេទប្រុស អាយុ៥២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីលំនៅ
សព្វថ្ងៃនៅភូមិកែវផុស ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង ។

**ចុងចម្លើយ:** ឈ្មោះ សុខ វុឌ្ឍី ភេទប្រុស អាយុ៥៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីលំនៅសព្វ
ថ្ងៃនៅភូមិ៣ សង្កាត់១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

**សូមគោរពចូលមក**

**លោកប្រធានសាលាដំបូងខេត្តព្រះសីហនុ**

**កម្មវត្ថុ:** សំណើសុំចេញសាលក្រមដែលមានខ្លឹមសារនៃសេចក្តីសម្រេចថា:
១. ទទួលស្គាល់កិច្ចសន្យាលក់ផ្តាច់ចុះថ្ងៃទី១៥ ខែ០៦ ឆ្នាំ២០១៦ និងលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី
១៥ ខែ០៦ ឆ្នាំ២០១៦ រវាងខ្ញុំបាទ និងឈ្មោះ សុខ ចន្ទី ជាមួយឈ្មោះ សុខ វុឌ្ឍី ។
២. បង្គាប់ឲ្យប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ
ចុះវាស់វែងនិងចុះបញ្ជីធ្វើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លីលើដីទំហំប្រហែល៤៧១៥៧
ម² មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។
៣. ទាមទារជំងឺចិត្ត និងការបាត់បង់ផលប្រយោជន៍ពីចុងចម្លើយចំនួន៣០០០០$ (បីម៉ឺនដុល្លារអាមេរិក) ។
៤. សាលក្រមនេះអាចអនុវត្តបណ្តោះអាសន្នតាមអំណាចមាត្រា១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។
៥. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

**យោង:** ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ១១៣២ ចុះថ្ងៃទី១៣ ខែ១០ ឆ្នាំ១៩៩៤
ចេញដោយប្រធានសុរិយោដីក្រុងព្រះសីហនុ ។

- កំណត់ហេតុអង្កេតដីចុះថ្ងៃទី១៣ ខែ១០ ឆ្នាំ១៩៩៤ របស់ឈ្មោះ សុខ វុឌ្ឍី ។
- លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១៥ ខែ០៦ ឆ្នាំ២០១៦ ពីឈ្មោះ សុខ វុឌ្ឍី មកលោក សយ សុភាព និង សុខ ចន្ទី (បានថតចម្លងត្រឹមត្រូវតាមផ្លូវច្បាប់)។
- លិខិតលក់ដីចុះថ្ងៃទី០៧ ខែ០៥ ឆ្នាំ១៩៩៨ រវាងឈ្មោះ ហៃ ចាន់ថន លក់ឲ្យឈ្មោះ សុខ វុឌ្ឍី (បានថតចម្លងត្រឹមត្រូវតាមផ្លូវច្បាប់)។
- លិខិតលក់ដីចុះថ្ងៃទី០៥ ខែ០៧ ឆ្នាំ១៩៩៨ ពីឈ្មោះ ទស់ វិច មកឲ្យឈ្មោះ សុខ វុឌ្ឍី (បានថតចម្លងត្រឹមត្រូវតាមផ្លូវច្បាប់)។
- លិខិតលក់ដីចុះថ្ងៃទី០៩ ខែ១០ ឆ្នាំ២០០៣ រវាងឈ្មោះ ចំរើន សុវុឌ្ឍីកា ឲ្យទៅឈ្មោះ សុខ វុឌ្ឍី (បានថតចម្លងត្រឹមត្រូវតាមផ្លូវច្បាប់)។
- កិច្ចសន្យាលក់ផ្តាច់ចុះថ្ងៃទី០៩ ខែ០៦ ឆ្នាំ២០០៦ ពីឈ្មោះ យក់ សុផល ទៅឲ្យឈ្មោះ សុខ វុឌ្ឍី (បានថតចម្លងត្រឹមត្រូវតាមផ្លូវច្បាប់)។

### I.អំពីអង្គហេតុចាំបាច់ដែលបញ្ជាក់ពីការទាមទារ

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន លោកប្រធាន មេត្តាជ្រាបថា: កាលពីថ្ងៃទី១៥ ខែ០៦ ឆ្នាំ២០១៦ ឈ្មោះ សុខ វុឌ្ឍី បានព្រមព្រៀងលក់ផ្តាច់នូវដី

- ដីកាសម្រេចចាត់ចែងបណ្តោះអាសន្នលេខ៣៨៦ត.រ/១៩ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ ។
- ដីកាបញ្ជូនលេខ២២២ជ.ប/០៦ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៦ របស់ស្នងការដ្ឋាននគរបាលក្រុងព្រះសីហនុ ។
- លិខិតលេខ១១២៩ របក/០៦ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៦ របស់ស្នងការនគរបាលក្រុងព្រះសីហនុ ។
- កំណត់ហេតុសួរបំភ្លឺលេខ១៣៥កណហ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៥ របស់ស្នងការនគរបាលក្រុងព្រះសីហនុ ។
- លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី០២ ខែ០១ ឆ្នាំ២០១៦ រវាងឈ្មោះ សុខ វុឌ្ឍី ជាមួយឈ្មោះ សុខ ចន្ទី និងឈ្មោះ សយ សុភាព ។
- កំណត់ហេតុចុះវាស់វែងដីទំនាស់ជាក់ស្តែងចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តព្រះសីហនុ ។
- ញាត្តិគាំទ្រចុះថ្ងៃទី៣១ ខែ០៥ ឆ្នាំ២០១៩ ។

២. ភស្តុតាងជាសាក្សី
- សាក្សីទាំង១៨នាក់ ដូចមានញាត្តិគាំទ្រចុះថ្ងៃទី៣១ ខែ០៥ ឆ្នាំ២០១៩ ។
- ឈ្មោះ ចំរើន វុឌ្ឍីកា ភេទប្រុស អាយុ៦០ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ អាសយដ្ឋានសព្វថ្ងៃនៅសង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។
- ឈ្មោះ ហួត ផុន ភេទប្រុស អាយុ៦២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ អាសយដ្ឋានសព្វថ្ងៃនៅសង្កាត់២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

ហេតុនេះដើម្បីការពារសិទ្ធិ កម្មសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្ញុំបាទផង និងក្នុងគោលបំណងអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់ផងខ្ញុំបាទសូមសំណូមពរ លោកប្រធានមេត្តាសម្រេចតាមសំណើររបស់យើងខ្ញុំខាងលើដោយក្តីអនុគ្រោះ ។

សូម លោកប្រធាន ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ធ្វើនៅថ្ងៃទី ០១ ខែ ០៧ ឆ្នាំ 2019

ស្នាមមេដៃ

[redacted]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះសីហនុ
លេខ [illegible]

# ដីកាបង្គាប់ឱ្យបង់ប្រាក់
# ប្រដាប់ក្តីតុលាការក្រៅពីពន្ធ

(មាត្រា ៦៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

យើង [illegible] ចៅក្រម នៃសាលាដំបូងខេត្តព្រះសីហនុ

បានឃើញ មាត្រា ៦៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ ២០០៦។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ: [illegible] ចុះថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១[illegible]

## យល់ឃើញថា:

អ្នកដាក់ពាក្យសុំដែលមានកាតព្វកិច្ចបង់ប្រាក់សម្រាប់សកម្មភាពចាំបាច់របស់តុលាការក្នុងនីតិវិធីរណ្តឹង ដូចមានចែងក្នុងមាត្រា ៦៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនទាន់បានបង់ប្រាក់នេះនៅឡើយ ដែលគប្បីតុលាការសម្រេចបង្គាប់តាមកំណត់ច្បាប់។

## ហេតុដូច្នេះសម្រេច:

១ បង្គាប់ឲ្យអ្នកដាក់ពាក្យសុំ ឬពាក្យបណ្តឹង ឈ្មោះ [illegible] បង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ សរុបចំនួន [illegible] ([illegible])។

២. ដីកាសម្រេចនេះធ្វើនៅថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១[illegible]។

ចៅក្រមទទួលបន្ទុក

[redacted]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះសីហនុ
សំណុំរឿងរដ្ឋប្បវេណីលេខ ៧០
ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥

# ដីកាកោះ

<table>
<tr><td colspan="2">បង្គាប់មកឈ្មោះ ឈិត សុខា ភេទស្រី ទីលំនៅផ្ទះលេខ ៧០អា ផ្លូវ១៥៦ ក្រុម១១ សង្កាត់ផ្សារដេប៉ូ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។</td></tr>
<tr><td>ឱ្យចូលមកសាលាដំបូងខេត្តព្រះសីហនុ</td><td>ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៦ វេលាម៉ោង ៨កន្លះព្រឹក</td></tr>
<tr><td>ដើម្បី</td><td>ធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល</td></tr>
<tr><td colspan="2">សំណុំរឿងរដ្ឋប្បវេណីលេខ ៧០ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥<br>ដើមចោទ៖ ១. ឈ្មោះ ភិន ហុង ហៅ ប៊ុន លី ភេទប្រុស ទីលំនៅផ្ទះលេខ ៧០អា ផ្លូវ១៥៦ ក្រុម១១ សង្កាត់ផ្សារដេប៉ូ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។<br>២. ឈ្មោះ សាន សុខា ឬ ឈិត សុខា ហៅ លី សុខា ភេទស្រី ទីលំនៅផ្ទះលេខ ៧០អា ផ្លូវ១៥៦ ក្រុម១១ សង្កាត់ផ្សារដេប៉ូ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។<br>ចុងចម្លើយ ឯកឧត្តម នាង ស៊ីផុង ទីលំនៅផ្ទះលេខ ៧១ ផ្លូវ២៩៨ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ មានលោកមេធាវី អន សុភ័ក្ត្រ ជាមេធាវីតំណាងដោយអាណត្តិ។</td></tr>
<tr><td>កម្មវត្ថុបណ្តឹង</td><td>- សុំឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយប្រគល់សិទ្ធិកាន់កាប់ដីទំហំ ទទឹងខាងមុខ (ទល់ចំណីសមុទ្រ) ប្រវែង៥៩ម៉ែត្រ ទទឹងខាងក្រោយទល់អូរ ប្រវែង៥២ម៉ែត្រ បណ្តោយ(ទល់ដីម៉ុក ឆឺ) ប្រវែង១១០ម៉ែត្រ និងបណ្តោយម្ខាងទៀតប្រវែង៨០ម៉ែត្រ ស្ថិតនៅក្នុងភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ</td></tr>
</table>

ខេត្តព្រះសីហនុ, ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦
**ចៅក្រម**

[redacted]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះសីហនុ
លេខៈ ៣៣៨៥ រ.ប.២១

## ដីកាបញ្ជូន
## ផ្ញើជូន លោកចៅសង្កាត់លេខ១

| ល.រ | ភាពឈ្មោះលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ០១ | ដីកាកោះហៅឈ្មោះ តៅ សៀក និងប្រពន្ធឈ្មោះ គុយ វួច | ០២ច្បាប់ | |
| ០២ | ពាក្យសុំចេញដីកាសម្រេចរក្សាការពាររបស់ឈ្មោះ ស៊ុន ហេង ចុះថ្ងៃទី២៩ ខែមិនា ឆ្នាំ២០២១ | ០១ច្បាប់ | |

ថ្ងៃពុធ ១២កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
ធ្វើនៅខេត្តព្រះសីហនុ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១
**ចៅក្រម**

[redacted]

សំណុំរឿងរក្សាការពារលេខ ៨៥
ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២១
របស់សាលាដំបូងខេត្តព្រះសីហនុ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តព្រះសីហនុ**
សំណុំរឿងរដ្ឋប្បវេណីលេខ ១៧១
ចុះថ្ងៃទី២៤-០៧-២០១៩

## កំណត់ហេតុ
## ស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ឆ្នាំពីរពាន់ដប់ប្រាំបួន ខែសីហា ថ្ងៃទីម្ភៃប្រាំបួន វេលាម៉ោង ១០និង៣០ ព្រឹក នៅក្នុងបន្ទប់លេខ១០ នៃ សាលាដំបូងខេត្តព្រះសីហនុ បានធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មានសមាសភាពដូចតទៅ ៖

លោក [redacted] ចៅក្រមទទួលបន្ទុក
លោក [redacted] ក្រឡាបញ្ជី

-**ដើមចោទ៖** ឈ្មោះ**សយ សុភាព** ភេទប្រុស អាយុ៥២ឆ្នាំ មានទីលំនៅភូមិកែវផុស ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង។ (វត្តមាន)។

-**មានមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ៖** លោកមេធាវី **ខៀវ សុផល** អត្តលេខ ០៩៩ មានការិយាល័យផ្ទះលេខ ៣១សេ ផ្លូវលេខ៣៤៨ ក្រុម១០ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ។ (វត្តមាន)។

-**ចុងចម្លើយ ៖** ឈ្មោះ **សុខ ចន្ទី** ភេទប្រុស អាយុ៥៧ឆ្នាំ មានទីលំនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះ សីហនុ ខេត្តព្រះសីហនុ ។ (អវត្តមាន)។

### ខ្លឹមសារនៃការទាមទារដោយដើមចោទ

១.ទទួលស្គាល់កិច្ចសន្យាលក់ផ្តាច់ចុះថ្ងៃទី១៥.៦.២០១៦ និងលិខិតចុះថ្ងៃទី១៥.៦.២០១៦ ។

២.បង្គាប់ឱ្យប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ ចុះវាស់វែងនិងចុះបញ្ជីធ្វើ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លីលើដីទំហំប្រហែល៤៧១៥៧ម២ មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

៣.ទាមទារជំងឺចិត្ត និងការបាត់បង់ផលប្រយោជន៍ពីចុងចម្លើយចំនួន ៣០០០០ដុល្លាអាមេរិក ។

៤.សុំអនុវត្តសាលក្រមជាបណ្តោះអាសន្ន។

៥.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

### សេចក្តីថ្លែងការណ៍របស់ដើមចោទ

**លោក សយ សុភាព** បានថ្លែងការណ៍ថាៈ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ឈ្មោះ សុខ វុឌ្ឍីបាន ព្រមព្រៀងលក់ផ្តាច់នូវដីរបស់គាត់ដែលមានទំហំសរុបប្រហែល ៤៧១៥៧ម២ មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់ លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ តាមកិច្ចសន្យាលក់ផ្តាច់ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ និងលិខិតផ្ទេរ សិទ្ធិចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ រវាងឈ្មោះ សុខ វុឌ្ឍី និងឈ្មោះ សុខ ចន្ទី និងឈ្មោះ សយ សុភាព។ ក្រោយ ពីបានទទួលការផ្ទេរសិទ្ធិកាន់កាប់ដីនេះពីឈ្មោះ សុខ វុឌ្ឍី រួចមកខ្ញុំបាទបានកាន់កាប់ដីនេះរហូតមកដល់បច្ចុប្បន្ន ការដែលខ្ញុំបាទចុះ ដោយបានធ្វើបង្គោលរបងថ្មព័ទ្ធជុំវិញដី និងបានសង់ផ្ទះរស់នៅលើដីនេះរហូតមកដល់បច្ចុប្បន្ន

**-អំពីចុងចម្លើយ**

ឈ្មោះ សុខ វុឌ្ឍី ត្រូវបានតុលាការចេញដីកាកោះឱ្យចូលមកធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង៨និង៣០នាទីព្រឹក ប៉ុន្តែដោយសារអយដ្ឋានចុងក្រោយរបស់គាត់ចុងចម្លើយស្ថិតនៅក្នុងភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ប៉ុន្តែអាជ្ញាធរភូមិបានបញ្ជាក់ក្នុងនីតិវិធីត្រៀមថាឈ្មោះ សុខ វុឌ្ឍី នេះមិនមានចុះស្ថិតិនៅក្នុងភូមិ៣ សង្កាត់លេខ៤ នេះឡើយ ហេតុដូច្នេះតុលាការបានធ្វើការបញ្ជូនផ្សាយដីកាកោះអញ្ជើញឈ្មោះ សុខ វុឌ្ឍី នេះតាមរយៈវិទ្យុជាតិដែលមានវិក័យបត្រទទួលផ្សាយលេខ ០៦៦ /១៩ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ និងបានផ្សាយតាមការសែតរស្មីកម្ពុជាលេខ ៨០៥៧ នៅថ្ងៃសុក្រ ទី១៨ ខែតុលា ឆ្នាំ២០១៩ តែពុំឃើញគាត់ចុងចម្លើយឈ្មោះ សុខ វុឌ្ឍី ចូលខ្លួនមកសាលាដំបូងខេត្តព្រះសីហនុ ដើម្បីធ្វើការថ្លែងការណ៍ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នេះ ។

-ក្រោយពីបញ្ចប់ការសាកសួរដេញដោលនាពេលទាញហេតុផលដោយផ្ទាល់មាត់ តុលាការបានសម្រេចលើកពេលប្រកាសសាលក្រមក្នុងសំណុំរឿងនេះទៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង ៨និង៣០នាទីព្រឹក ។

បញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ វេលាម៉ោង ដប់ប្រាំ និងហាសិបនាទី ៕

| ដើមចោទ | មេធាវីដើមចោទ | ចុងចម្លើយ | ក្រឡាបញ្ជី | ចៅក្រមជំនុំជំរះ |
|---|---|---|---|---|
| | | (អវត្តមាន) | | |
| សយ សុភាព , | ខៀវ សុផល | សុខ វុឌ្ឍី , | [redacted] | [redacted] |

សាក្សី

ណៃ វណ្ណា, រស់ សំណាង, យ៉េត យី, ជ្រុយ ចូត

កិច្ចសន្យាទិញលក់ផ្តាច់ និងផ្ទេរសិទ្ធិកាន់កាប់ដីនេះជាមួយនឹងឈ្មោះ សុខ វុឌ្ឍី គឺធ្វើឡើងដោយឆន្ទៈព្រមព្រៀងរបស់គូភាគីដោយពិតប្រាកដ និងដោយសេរី គ្មានការបង្ខិតបង្ខំពីអ្នកណាឡើយ។ ហេតុដូច្នេះតាមច្បាប់ កិច្ចសន្យាទិញលក់គឺជាច្បាប់របស់ភាគីអ្នកទិញ និងអ្នកលក់ ហេតុនេះអ្នកទិញនិងអ្នកលក់ត្រូវគោរពកាតព្វកិច្ចនៃកិច្ចសន្យាទៅវិញទៅមកឱ្យបានត្រឹមត្រូវតាមការព្រមព្រៀង និងតាមច្បាប់ជាធរមាន ចំពោះខ្ញុំបាទនិងប្រពន្ធគឺបានប្រគល់ប្រាក់ថ្លៃដីជូនទៅអ្នកលក់រួចរាល់អស់ហើយ នៅឡើយតែអ្នកលក់ឈ្មោះ សុខ វុឌ្ឍី ផ្តិតមេដៃលើឯកសារបែបបទចុះបញ្ជីរបស់សុរិយោដីផ្ទេរសិទ្ធិកាន់កាប់មកឱ្យខ្ញុំបាទកាន់កាប់ជាកម្មសិទ្ធិស្របច្បាប់តែប៉ុណ្ណោះ។ ហេតុដូច្នេះផ្អែកតាមមាត្រា ៥៥៤ និងមាត្រា ៥៥៥ នៃក្រមរដ្ឋប្បវេណីបានចែងថា "ក្នុងករណីអ្នកទិញបានបង់ប្រាក់ថ្លៃទិញលក់រួចឱ្យទៅអ្នកលក់ គឺអ្នកលក់មានសិទ្ធិធ្វើសកម្មភាពស្នើសុំចុះបញ្ជីដីនេះបាន"។ ហេតុដូចនេះដោយខ្ញុំបាទបានចុះកិច្ចសន្យាទិញលក់ដីផ្តាច់ជាមួយឈ្មោះ សុខ វុឌ្ឍី រួចហើយ និងបានបង់ប្រាក់ថ្លៃទិញលក់ឱ្យទៅឈ្មោះសុខ វុឌ្ឍី រួចហើយដែរដូច្នេះខ្ញុំបានស្នើសុំតុលាការមេត្តាសម្រេចអនុញ្ញាតឱ្យមន្ត្រីជំនាញសុរិយោដីចុះវាស់វែង និងចុះបញ្ជីធ្វើបណ្ណកម្មសិទ្ធិលើដីទំហំប្រហែល៤៧១៥៧ម២ មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ឱ្យខ្ញុំបាទកាន់កាប់ជាកម្មសិទ្ធិចាប់ពីពេលនេះតទៅ។

ខ្ញុំបាទមានភស្តុតាងនិងសាក្សីដូចតទៅ ៖

១.កិច្ចសន្យាលក់ផ្តាច់ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ រវាងឈ្មោះ សុខ វុឌ្ឍី ជាមួយឈ្មោះ សយ សុភាព និងឈ្មោះ សុខ ចន្នី ។

២.លិខិតលក់ដីចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៩៨ រវាងឈ្មោះ ហៃ ចានថន ជាមួយឈ្មោះ សុខ វុឌ្ឍី។

៣.លិខិតលក់ដីចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៨ រវាងឈ្មោះ ទស់ វិច ជាមួយឈ្មោះ សុខ វុឌ្ឍី។

៤.លិខិតលក់ដីចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៣ រវាងឈ្មោះ ចំរើន វុឌ្ឍីកា ជាមួយឈ្មោះ សុខ វុឌ្ឍី។

៥.លិខិតលកផ្តាច់ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៦ រវាងឈ្មោះ យក់ សុផល ជាមួយឈ្មោះ សុខ វុឌ្ឍី។

៦.លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៦ រវាងឈ្មោះ សុខ វុឌ្ឍី ជាមួយឈ្មោះ សុខ ចន្នី និងឈ្មោះ សយ សុភាព។

៧.សាក្សីឈ្មោះ ចំរើន វុឌ្ឍីកា ភេទប្រុស អាយុ៦០ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានសង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

៨.សាក្សីឈ្មោះ ហួត ផុន ភេទប្រុស អាយុ៦២ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានសង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

៩.សាក្សីទាំង១៤នាក់ ដូចមានញត្តិគាំទ្រ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩។

**អំពីសេចក្តីថ្លែងការណ៍តបរបស់ចុងចម្លើយ**

**ចុងចម្លើយឈ្មោះ សុខ វុឌ្ឍី** តាមពាក្យបណ្តឹងរបស់ដើមចោទបានបញ្ជាក់អាសយដ្ឋានរបស់ចុងចម្លើយឈ្មោះ សុខ វុឌ្ឍី ភេទប្រុស អាយុ៥៧ឆ្នាំ មានអាសយដ្ឋានភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ តុលាការបានកោះហៅចុងចម្លើយឈ្មោះ សុខ វុឌ្ឍី ឱ្យចូលធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប៉ុន្តែត្រូវបានអនុភូមិ៣ឈ្មោះ ញៀត បុណ្ណា បានសរសេរបញ្ជាក់នៅលើដីកាកោះថា ឈ្មោះ សុខ វុឌ្ឍី បានរុះរើលំនៅដ្ឋានភូមិ៣ សង្កាត់លេខ១ តាំងពីយូណាស់មកហើយ មិនដឹងទៅរស់នៅទីណាទេ។

បញ្ឈប់កំណត់ហេតុនៅវេលាម៉ោង ដប់មួយនិងដប់ប្រាំនាទីព្រឹក ថ្ងៃខែឆ្នាំដូចខាងលើ បានអានឱ្យគូភាគីស្តាប់ឆ្លើយថាត្រឹមត្រូវ និងយល់ព្រមផ្តិតមេដៃ ឬ ចុះហត្ថលេខាជាមួយយើង ។

| ដើមចោទ | មេធាវីដើមចោទ | ចុងចម្លើយ | ក្រឡាបញ្ជី | ចៅក្រម |
|---|---|---|---|---|

[redacted]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តព្រះសីហនុ**
សំណុំរឿងរដ្ឋប្បវេណីលេខ ១៧១
ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៩

## កំណត់ហេតុ
## ស្តីពីការទាញហេតុផលដោយផ្ទាល់មាត់

*ឆ្នាំពីរពាន់ដប់ប្រាំបួន ខែវិច្ឆិកា ថ្ងៃទីប្រាំមួយ វេលាម៉ោងដប់បួនកន្លះ នៅសាលជម្រះក្តីនៃសាលាដំបូងខេត្តព្រះសីហនុ បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈមានសមាសភាពដូចតទៅ ៖*

**ចៅក្រមជំនុំជម្រះ**

*លោក* [redacted] *អនុប្រធានសាលាដំបូងខេត្តព្រះសីហនុ*

**ក្រឡាបញ្ជីសវនាការ**

*លោក* [redacted] *ក្រឡាបញ្ជី*

-**ដើមចោទ៖** ឈ្មោះ**សយ សុភាព** ភេទប្រុស អាយុ៥២ឆ្នាំ មានទីលំនៅភូមិកែវផុស ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង។ (វត្តមាន)។

-**មានមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ ៖** លោកមេធាវី **ខៀវ សុផល** អត្តលេខ ០៨៩ មានការិយាល័យផ្ទះលេខ ៣១សេ ផ្លូវលេខ៣៤៨ ក្រុម១០ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ។ (វត្តមាន)។

-**ចុងចម្លើយ ៖** ឈ្មោះ **សុខ ឧត្តរ៉ា** ភេទប្រុស អាយុ៥៧ឆ្នាំ មានទីលំនៅភូមិ៤ សង្កាត់លេខ៤ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។ (អវត្តមាន)។

**-ខ្លឹមសារនៃការទាមទារដោយដើមចោទ**

១.ទទួលស្គាល់កិច្ចសន្យាលក់ផ្តាច់ចុះថ្ងៃទី១៥.៦.២០១៦ និងលិខិតចុះថ្ងៃទី១៥.៦.២០១៦ ។

២.បង្គាប់ឱ្យប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ ចុះវាស់វែងនិងចុះបញ្ជីធ្វើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លីលើដីទំហំប្រហែល៤៧១៥៧$ម^2$ មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

៣.ទាមទារជំងឺចិត្ត និងការបាត់បង់ផលប្រយោជន៍ពីចុងចម្លើយចំនួន ៣០០០០ដុល្លាអាមេរិក ។

៤.សុំអនុវត្តសាលក្រមជាបណ្តោះអាសន្ន។

៥.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

**-សេចក្តីថ្លែងការណ៍របស់ដើមចោទ**

លោក សយ សុភាព បានថ្លែងការណ៍ថា: ខ្ញុំបាទសូមសំណូមសុំកែតម្រូវកម្មវត្ថុនៃពាក្យបណ្តឹងរបស់ខ្ញុំបាទចំណុចលេខ៦ នៃពាក្យបណ្តឹងចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៩ ទៅជា -សេចក្តីសម្រេចសាលក្រមអនុញ្ញាតដើមចោទឈ្មោះ សយ សុភាព មានអត្ថិភាពនៃសិទ្ធិធ្វើលទ្ធកម្មកម្មសិទ្ធិ ចុះបញ្ជីស្របតាមនីតិវិធីនៅលើដីទំហំប្រហែល ៤៧១៥៧ម$^2$ មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ- វិញ។ ចំណុចផ្សេងៗក្នុងកម្មវត្ថុនៃពាក្យបណ្តឹងចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៩ រក្សាទុកជាបានការដដែល ។ និងសូមរក្សាសេចក្តីថ្លែងការណ៍នៅក្នុងកំណត់ហេតុនីតិវិធីត្រៀមសម្រាប់ការទាញហេតុលើកទី១ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ ដែលមានខ្លឹមសារដូចតទៅ ៖ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ឈ្មោះ សុខ វុន្នី បានព្រមព្រៀងលក់ផ្តាច់នូវដីរបស់គាត់ដែលមានទំហំសរុបប្រហែល ៤៧១៥៧ម$^2$ មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ តាមកិច្ចសន្យាលក់ផ្តាច់ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ និងលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ រវាងឈ្មោះ សុខ វុន្នី និងឈ្មោះ សុខ ចន្ទី និងឈ្មោះ សយ សុភាព ដោយខ្ញុំបាទនិងប្រពន្ធបានទូទាត់ថ្លៃដីឱ្យ សុខ វុន្នី រួចអស់ហើយនៅពេលនោះ។ ក្រោយពីបានទទួលការផ្ទេរសិទ្ធិកាន់កាប់ដីនេះពីឈ្មោះ សុខ វុន្នី រួចមកខ្ញុំបាទបានកាន់កាប់ដីនេះរហូតមកដល់បច្ចុប្បន្ន ដោយបានធ្វើបង្គោលរបងថ្មព័ទ្ធជុំវិញដី និងបានសង់ផ្ទះរស់នៅលើដីនេះរហូតមកដល់បច្ចុប្បន្ន ការដែលខ្ញុំបាទចុះកិច្ចសន្យាទិញលក់ផ្តាច់ និងផ្ទេរសិទ្ធិកាន់កាប់ដីនេះជាមួយនឹងឈ្មោះ សុខ វុន្នី គឺធ្វើឡើងដោយឆន្ទៈព្រមព្រៀងរបស់គូភាគីដោយពិតប្រាកដនិងដោយសេរី គ្មានការបង្ខិតបង្ខំពីអ្នកណាឡើយ។ ហេតុដូច្នេះតាមច្បាប់ កិច្ចសន្យាទិញលក់គឺជាច្បាប់របស់ភាគីអ្នកទិញ និងអ្នកលក់ ហេតុនេះអ្នកទិញនិងអ្នកលក់ត្រូវគោរពកាតព្វកិច្ចនៃកិច្ចសន្យាទៅវិញទៅមកឱ្យបានត្រឹមត្រូវតាមការព្រមព្រៀង និងតាមច្បាប់ជាធរមាន ចំពោះខ្ញុំបាទនិងប្រពន្ធគឺបានប្រគល់ប្រាក់ថ្លៃដីជូនទៅអ្នកលក់រួចរាល់អស់ហើយ នៅឡើយតែអ្នកលក់ឈ្មោះ សុខ វុន្នី ផ្តិតមេដៃលើឯកសារបែបបទចុះបញ្ជីរបស់សុរិយោដីផ្ទេរសិទ្ធិកាន់កាប់មកឱ្យខ្ញុំបាទកាន់កាប់ជាកម្មសិទ្ធិស្របច្បាប់តែប៉ុណ្ណោះ។ ហេតុដូច្នេះផ្អែកតាមមាត្រា ៥៥៤ និងមាត្រា ៥៥៥ នៃក្រមរដ្ឋប្បវេណីបានចែងថា -ក្នុងករណីអ្នកទិញបានបង់ប្រាក់ថ្លៃទិញលក់រួចឱ្យទៅអ្នកលក់ គឺអ្នកលក់មានសិទ្ធិធ្វើសកម្មភាពស្នើសុំចុះបញ្ជីដីនេះបាន-។ ហេតុដូចនេះដោយខ្ញុំបាទបានចុះកិច្ចសន្យាទិញលក់ដីផ្តាច់ជាមួយឈ្មោះ សុខ វុន្នី រួចហើយ និងបានបង់ប្រាក់ថ្លៃទិញលក់ឱ្យទៅឈ្មោះ សុខ វុន្នី រួចហើយដែរ ដូច្នេះខ្ញុំបាទស្នើសុំតុលាការមេត្តាសម្រេចអនុញ្ញាតឱ្យមន្ត្រីជំនាញសុរិយោដីចុះវាស់វែង និងចុះបញ្ជីធ្វើបណ្ណកម្មសិទ្ធិលើដីទំហំប្រហែល៤៧១៥៧ម$^2$ មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ឱ្យខ្ញុំបាទកាន់កាប់ជាកម្មសិទ្ធិចាប់ពីពេលនេះតទៅ។

ខ្ញុំបាទមានភស្តុតាងនិងសាក្សីដូចតទៅ ៖

១.កិច្ចសន្យាលក់ផ្តាច់ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ រវាងឈ្មោះ សុខ វុន្នី ជាមួយឈ្មោះ សយ សុភាព និងឈ្មោះ សុខ ចន្ទី ។

កក្កដា ឆ្នាំ១៩៩៨ ទិញពីឈ្មោះ ចំរើន វុន្ណារីកា តាមលិខិតលក់ដីចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៣ និងទិញពីឈ្មោះ យក់ សុផល តាមកិច្ចសន្យាលក់ផ្តាច់ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៦ សរុបផ្ទៃដីដែលឈ្មោះ សុខ វុន្ណារី បានទិញតាមកិច្ចសន្យានិងលិខិតលក់ផ្តាច់ខាងលើនេះទំហំ ២៣២៨៨ម២ ហេតុនេះសរុបដីកម្មសិទ្ធិរបស់ឈ្មោះ សុខ វុន្ណារី ទាំងមានបណ្ណសំគាល់សិទ្ធិ និងមានលិខិតទិញលក់គឺសរុបទាំងអស់ ៤៧១៥៧ម២ មានទីតាំងស្ថិតនៅភូមិមណ្ឌល៣ សង្កាត់លេខ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ លុះក្រោយមកឈ្មោះ សុខ វុន្ណារី បានធ្លាក់ខ្លួនឈឺហើយស្ថិតនៅក្នុងបន្ទុករបស់បងស្រីបង្កើតឈ្មោះ សុខ ចន្ទី និងសយ សុភាព ក្នុងពេលនៅ ឈ្មោះ សុខ វុន្ណារី បានស្ម័គ្រចិត្តដោយឆន្ទៈពិតប្រាកដ និងដោយសេរីលក់ផ្តាច់ដីដែលមានបណ្ណសំគាល់សិទ្ធិលេខ A1-1941 ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៤ និងលក់ដីឱ្យទៅបងស្រីឈ្មោះ សុខ ចន្ទី និងឈ្មោះ សយ សុភាព កាន់កាប់ជាកម្មសិទ្ធិដែលទំហំសរុប ៤៧១៥៧ម២ (តាមការវាស់វែងជាក់ស្តែង) តាមកិច្ចសន្យាលក់ផ្តាច់ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ និងលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ដែលពេលនោះកូនក្តីខ្ញុំបានទូទាត់ប្រាក់ថ្លៃដីឱ្យឈ្មោះ សុខ វុន្ណារី រួចរាល់អស់ហើយ ដែលមានឈ្មោះ ចំរើន វុន្ណារីកា ជាអ្នកសរសេរលិខិតផ្ទេរសិទ្ធិហើយក៏បានធ្វើកិច្ចសន្យាលក់ផ្តាច់មានការដឹងឮនិងបញ្ជាក់ពីលោក សៀន ប៊ុនឈឿន អនុភូមិកែវផុស មានការដឹងឮពីសាក្សីឈ្មោះ ហួត ផុត នៅចំពោះមុខទៀតផង ហើយពីនេះក៏មានសាក្សីជាច្រើនបានដឹងឮថាឈ្មោះ សុខ វុន្ណារី ពិតជាបានលក់ផ្តាច់នូវដីទំហំសរុបប្រហែល ៤៧១៥៧ម២ មានទីតាំងស្ថិតនៅភូមិមណ្ឌល៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដែលមានសាក្សីទាំងនេះនិងបំភ្លឺជូនតុលាការដូចខាងក្រោម។

ក្រោយពីបានទទួលការផ្ទេរសិទ្ធិកាន់កាប់ដីនេះពីឈ្មោះ សុខ វុន្ណារី រួចមកកូនក្តីខ្ញុំបាទបានកាន់កាប់ដីនេះរហូតមកដល់បច្ចុប្បន្ន ដោយបានធ្វើបង្គោលរបងថ្មព័ទ្ធជុំវិញដី និងបានសង់ផ្ទះរស់នៅលើដីនេះរហូតមកដល់បច្ចុប្បន្ន ការដែលកូនក្តីខ្ញុំបាទចុះកិច្ចសន្យាទិញលក់ផ្តាច់ និងផ្ទេរសិទ្ធិកាន់កាប់ដីនេះជាមួយនឹងឈ្មោះ សុខ វុន្ណារី គឺធ្វើឡើងដោយឆន្ទៈព្រមព្រៀងរបស់គូភាគីដោយពិតប្រាកដ និងដោយសេរី គ្មានការបង្ខិតបង្ខំពីអ្នកណាឡើយ។ ហេតុដូច្នេះតាមច្បាប់ កិច្ចសន្យាទិញលក់គឺជាច្បាប់របស់ភាគីអ្នកទិញ និងអ្នកលក់ ហេតុនេះអ្នកទិញនិងអ្នកលក់ត្រូវគោរពកាតព្វកិច្ចនៃកិច្ចសន្យាទៅវិញទៅមកឱ្យបានត្រឹមត្រូវតាមការព្រមព្រៀង និងតាមច្បាប់ជាធរមាន ចំពោះខ្ញុំបាទនិងប្រពន្ធគឺបានប្រគល់ប្រាក់ថ្លៃដីជូនទៅអ្នកលក់រួចរាល់អស់ហើយ នៅឡើយតែអ្នកលក់ឈ្មោះ សុខ វុន្ណារី ផ្តិតមេដៃលើឯកសារបែបបទចុះបញ្ជីរបស់សុរិយោដីផ្ទេរសិទ្ធិកាន់កាប់មកឱ្យខ្ញុំបាទកាន់កាប់ជាកម្មសិទ្ធិស្របច្បាប់តែប៉ុណ្ណោះ។ ហេតុដូច្នេះផ្អែកតាមមាត្រា ៥៥៤ និងមាត្រា ៥៥៥ នៃក្រមរដ្ឋប្បវេណីបានចែងថា "ក្នុងករណីអ្នកទិញបានបង់ប្រាក់ថ្លៃទិញលក់រួចឱ្យទៅអ្នកលក់ គឺអ្នកលក់មានសិទ្ធិធ្វើសកម្មភាពស្នើសុំចុះបញ្ជីដីនេះបាន"។ ហេតុដូចនេះដោយខ្ញុំបាទបានចុះកិច្ចសន្យាទិញលក់ដីផ្តាច់ជាមួយឈ្មោះ សុខ វុន្ណារី រួចហើយ និងបានបង់ប្រាក់ថ្លៃទិញលក់ឱ្យទៅឈ្មោះ សុខ វុន្ណារី រួចហើយដែរ ដូច្នេះខ្ញុំបាទស្នើសុំតុលាការមេត្តាសម្រេច

២.លិខិតលក់ដីចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៩៨ រវាងឈ្មោះ ហៃ ចានថន ជាមួយឈ្មោះ សុខ វុន្នី ។

៣.លិខិតលក់ដីចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ១៩៩៨ រវាងឈ្មោះ ទស់ រិច ជាមួយឈ្មោះ សុខ វុន្នី ។

៤.លិខិតលក់ដីចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៣ រវាងឈ្មោះ ចំរើន វុន្នីកា ជាមួយឈ្មោះ សុខ វុន្នី ។

៥.លិខិតលកផ្តាច់ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៦ រវាងឈ្មោះ យក់ សុផល ជាមួយឈ្មោះ សុខ វុន្នី ។

៦.សាក្សីឈ្មោះ ចំរើន វុន្នីកា ភេទប្រុស អាយុ៦០ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានសង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

៧.សាក្សីឈ្មោះ ហួត ផុន ភេទប្រុស អាយុ៦២ឆ្នាំ ជាតិខ្មែរ អាសយដ្ឋានសង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

៨.សាក្សីឈ្មោះ ណៃ វណ្ណា ភេទប្រុស អាយុ៤០ឆ្នាំ ទីលំនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

៩.សាក្សីឈ្មោះ ជ្រុយ ជូត ភេទប្រុស កើតឆ្នាំ១៩៨០ ទីលំនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

១០.សាក្សីឈ្មោះ យ៉េត យី ភេទស្រី កើតឆ្នាំ១៩៧៤ ទីលំនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

១១.សាក្សីឈ្មោះ រស់ សំណាង ភេទប្រុស អាយុ៣៥ឆ្នាំ មានទីលំនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

**-សេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ**

លោក ខៀវ សុផល បានថ្លែងការណ៍ថាៈ ខ្ញុំបាទសូមជម្រាបលោកចៅក្រមអំពីប្រវត្តិដីដូចតទៅ នៅឆ្នាំ១៩៩៤ ឈ្មោះ សុខ វុន្នី បានកាន់កាប់ដីមួយកន្លែងដែលមានទំហំ ៣ហិចតា ៣៩អា ២៣សង្ទីអា មានទីតាំងស្ថិតនៅមណ្ឌល៣ សង្កាត់លេខ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដោយមានពាក្យស្នើសុំកាន់កាប់ដីចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩៤ និងបង្កាន់ដៃបង់ថ្លៃអង្កេតលេខ ១៩០ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៤ ដូចមានចុះក្នុងកំណត់ហេតុអង្កេតជូនភ្ជាប់ជាមួយស្រាប់ ហើយក៏បានទទួលនូវប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ A$_1$-1132 ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៤ លុះក្រោយមកឈ្មោះ សុខ វុន្នី បានលក់ដីដែលមានទំហំទីតាំងក្នុងប័ណ្ណសម្គាល់សិទ្ធិខាងលើនេះឱ្យអតិថិជនរបស់ខ្លួនអស់ទំហំប្រហែល១០០៥៤ម$^{២}$ ហេតុនេះដីនៅសល់គឺទំហំ ២៣៨៦៩ម$^{២}$ ដែលមានបណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លីលេខ A$_1$ 941 ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៤ វិញ។ ដីនេះគឺឈ្មោះ សុខ វុន្នី បានលក់ផ្តាច់និងផ្ទេរសិទ្ធិកាន់កាប់ដីទាំងអស់ឱ្យកូនក្តីខ្ញុំឈ្មោះ សយ សុភាព និង សុខ ចន្ទី រួមជាមួយដីរបស់គ្មានបណ្ណសំគាល់សិទ្ធិដីទំហំ ២៣២៨៨ម$^{២}$ ដែលបានទិញពីឈ្មោះ ទស់ រិច តាមលិខិតលក់ដីចុះថ្ងៃទី៥ ខែ

អនុញ្ញាតឱ្យមន្ត្រីជំនាញសុរិយោដីចុះវាស់វែង និងចុះបញ្ជីធ្វើបណ្ណកម្មសិទ្ធិលើដីទំហំប្រហែល ៤៧១៥៧ម² មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ឱ្យខ្ញុំបាទកាន់កាប់ជាកម្មសិទ្ធិចាប់ពីពេលនេះតទៅ ។

ករណីនេះខ្ញុំបាទមានសាក្សីដូចខាងក្រោម ៖

១.សាក្សីឈ្មោះ ណៃ វណ្ណា ភេទប្រុស អាយុ៤០ឆ្នាំ ទីលំនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

២.សាក្សីឈ្មោះ ជ្រុយ ជូត ភេទប្រុស កើតឆ្នាំ១៩៨០ ទីលំនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

៣.សាក្សីឈ្មោះ យ៉េត យី ភេទស្រី កើតឆ្នាំ១៩៧៤ ទីលំនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

៤.សាក្សីឈ្មោះ រស់ សំណាង ភេទប្រុស អាយុ៣៥ឆ្នាំ មានទីលំនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

៥.ឈ្មោះ ចំរើន វុឌ្ឍីកា ប៉ុន្តែមានការសោកស្តាយដែលគាត់ត្រូវបានគ្រោះថ្នាក់ចរាចរណ៍ស្លាប់កាលពីខែមុន។

៦.ឈ្មោះ ហួត ផុន មានជំងឺជាទំងន់មិនអាចមកឆ្លើយជូនតុលាការបានទេ ។

ហេតុដូច្នេះ សំណូមសូមតុលាការចាត់ការសាកសួរតាមនីតិវិធី និងសំណូមពរចេញសាលក្រមតាមការប្តឹងសុំថា ៖

ទី១. ទទួលស្គាល់កិច្ចសន្យាលក់ផ្តាច់ចុះថ្ងៃទី១៥.៦.២០១៦ និងលិខិតចុះថ្ងៃទី១៥.៦.២០១៦ រវាងឈ្មោះ សយ សុភាព និងឈ្មោះ សុខ ចន្ទី ជាមួយឈ្មោះ សុខ វុឌ្ឍី ។

ទី២. ចេញសាលក្រមអនុញ្ញាតដើមចោទឈ្មោះ សយ សុភាព មានអត្ថិភាពនៃសិទ្ធិធ្វើលទ្ធកម្មកម្មសិទ្ធិ ចុះបញ្ជីស្របតាមនីតិវិធីនៅលើដីទំហំប្រហែល ៤៧១៥៧ម² មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

ទី៣.ទាមទារជំងឺចិត្ត និងការបាត់បង់ផលប្រយោជន៍ពីចុងចម្លើយចំនួន ៣០០០០ដុល្លាអាមេរិក ។

ទី៤.សុំអនុវត្តសាលក្រមជាបណ្តោះអាសន្ន។

ទី៥.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

**-សេចក្តីថ្លែងការណ៍របស់សាក្សី**

១.ឈ្មោះ ណៃ វណ្ណា បានឆ្លើយថា ខ្ញុំបាទសូមឆ្លើយតែការពិតថា កន្លងមកខ្ញុំបាទនិងគ្នាបីនាក់ទៀតតែងតែជួយយាមឱ្យឈ្មោះ សុខ វុឌ្ឍី ហើយនៅអំឡុងឆ្នាំ២០១៦ ខ្ញុំបាទបានជួបជាមួយឈ្មោះ សុខ វុឌ្ឍី ហើយក្រោយពីនិយាយសួរសុខទុក្ខគាត់ឈឺមក គាត់បាននិយាយប្រាប់គេឯងថានៅទីនោះមានឈ្មោះ ជ្រុយ ចូត និងឈ្មោះ យ៉េត យី និងអ្នកផ្សេងជាច្រើននាក់ទៀត ថាគាត់បានផ្ទេរសិទ្ធិកាន់កាប់ដី

និងលក់ផ្តាច់នូវដីទំហំប្រហែល៤៧១៥៧ម$^2$ មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់លេខ១ ខណ្ឌមិត្តភាព ខេត្តព្រះសីហនុ ទាំងដីក្នុងបណ្ណ និងដីគ្មានបណ្ណឱ្យទៅបងស្រីបង្កើតឈ្មោះ សុខ ចន្នី និងបង សយ សុភាព កាន់កាប់ជាកម្មសិទ្ធិស្របច្បាប់តទៅ ព្រោះគាត់ជាអ្នកមានគុណលើខ្ញុំណាស់ដូចម្តាយឪពុកអញ្ចឹង។

២.ឈ្មោះ ជ្រុយ ចូត បានឆ្លើយថា ខ្ញុំបាទសូមឆ្លើយតែការពិតថា កន្លងមកខ្ញុំបាទនិងគ្នាបីនាក់ទៀតតែងតែជួយយាមឱ្យឈ្មោះ សុខ វុន្ឍី ហើយ នៅអំឡុងឆ្នាំ២០១៦ ខ្ញុំបាទបានជួបជាមួយឈ្មោះ សុខ វុន្ឍី ហើយក្រោយពីនិយាយសួរសុខទុក្ខគាត់ឈឺមក គាត់បាននិយាយប្រាប់គេឯងថានៅទីនោះមានឈ្មោះ ណៃ វណ្ណា និងឈ្មោះ យ៉េត យី និងអ្នកផ្សេងជាច្រើននាក់ទៀត ថាគាត់បានផ្ទេរសិទ្ធិកាន់កាប់ដីនិងលក់ផ្តាច់នូវដីទំហំប្រហែល៤៧១៥៧ម$^2$ មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់លេខ១ ខណ្ឌមិត្តភាព ខេត្តព្រះសីហនុ ទាំងដីក្នុងបណ្ណ និងដីគ្មានបណ្ណឱ្យទៅបងស្រីបង្កើតឈ្មោះ សុខ ចន្នី និងបង សយ សុភាព កាន់កាប់ជាកម្មសិទ្ធិស្របច្បាប់តទៅ ព្រោះគាត់ជាអ្នកមានគុណលើខ្ញុំណាស់ដូចម្តាយឪពុកអញ្ចឹង។

៣.ឈ្មោះ យ៉េត យី បានឆ្លើយថា នាងខ្ញុំសូមឆ្លើយតែការពិតថា កន្លងមកនាងខ្ញុំនិងគ្នាបីនាក់ទៀតតែងតែជួយយាមឱ្យឈ្មោះ សុខ វុន្ឍី ហើយនៅអំឡុងឆ្នាំ២០១៦ ខ្ញុំបាទបានជួបជាមួយឈ្មោះ សុខ វុន្ឍី ហើយក្រោយពីនិយាយសួរសុខទុក្ខគាត់ឈឺមក គាត់បាននិយាយប្រាប់គេឯងថានៅទីនោះមានឈ្មោះ ណៃ វណ្ណា និងឈ្មោះ ជ្រុយ ចូត និងអ្នកផ្សេងជាច្រើននាក់ទៀត ថាគាត់បានផ្ទេរសិទ្ធិកាន់កាប់ដីនិងលក់ផ្តាច់នូវដីទំហំប្រហែល៤៧១៥៧ម២ មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់លេខ១ ខណ្ឌមិត្តភាព ខេត្តព្រះសីហនុ ទាំងដីក្នុងបណ្ណ និងដីគ្មានបណ្ណឱ្យទៅបងស្រីបង្កើតឈ្មោះ សុខ ចន្នី និងបង សយ សុភាព កាន់កាប់ជាកម្មសិទ្ធិស្របច្បាប់តទៅ ព្រោះគាត់ជាអ្នកមានគុណលើខ្ញុំណាស់ដូចម្តាយឪពុកអញ្ចឹង។

៤.ឈ្មោះ រស់ សំណាង បានឆ្លើយថា ខ្ញុំបាទសូមជម្រាបជូនតុលាការតែការពិតថា ខ្ញុំបាទបានរស់នៅលើដីគាត់ឈ្មោះ សុខ វុន្ឍី យាមដីឱ្យគាត់រហូតមក លុះដល់ឆ្នាំ២០១៦ ឈ្មោះ សុខ វុន្ឍី ធ្លាក់ខ្លួនឈឺក៏រស់នៅក្នុងបន្ទុករបស់លោកស្រី សុខ ចន្នី និងលោក សយ សុភាព ចិញ្ចឹមនិងចេញថ្លៃព្យាបាលរហូតហើយគាត់ក៏បានលើកឡើងថាដោយគាត់ចតែឈឺហើយត្រូវការចំណាយច្រើនទើបបងគាត់ឈ្មោះ សុខ ចន្នី និងសយ សុភាព ហេតុនេះគាត់ក៏ បានស្ម័គ្រចិត្តដោយឆន្ទៈរបស់គាត់ផ្ទាល់យល់ព្រមលក់ដីផ្តាច់ឱ្យមកឈ្មោះ សុខ ចន្នី និងឈ្មោះ សយ សុភាព ពេលនោះឈ្មោះ សយ សុភាព និង សុខ ចន្នី បានហៅអនុភូមិកែវផុសឈ្មោះ សៀន ប៊ុនឈឿន និងលោក ចំរើន វុន្ឍីកា ឱ្យសរសេរលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ និង សុខ វុន្ឍី បានធ្វើលិខិតលលក់ផ្តាច់ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ឱ្យមកឈ្មោះ សុខ ចន្នី និង សយ សុភាព ដោយមានសាក្សីខ្ញុំបាទ ចំរើន វុន្ឍីកា និង លោក ហួត ផុន ដីងឮចុះហត្ថលេខដោយលោក សៀន ប៊ុនឈឿន ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមមេធាវី ជាតិ និង អន្តរជាតិ**
**NATIONAL AND INTERNATIONAL LAW FIRM**
**មេធាវី** [redacted]
**KHIEV SOPHAL Avocat , Attorney-At-Law**

សាលាដំបូងខេត្តព្រះសីហនុ
ចូល លេខ:...១៩៤២...ត.ក.
ថ្ងៃទី.០៣..ខែ០៩..ឆ្នាំ២០១៩
ម៉ោង:.....០៩...៣០.......

## ពាក្យសុំផ្សាយជាសាធារណៈ

ខ្ញុំមេធាវី [redacted] សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជា ប្រធានក្រុមមេធាវីជាតិ និងអន្តរជាតិ អត្តលេខ០៨៩។ មានអាស័យដ្ឋានផ្ទះលេខ៣១ ផ្លូវ៣៨៨ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌ ចំការមន រាជធានីភ្នំពេញ។

**សូមគោរពចូលមក**

**លោកប្រធានសាលាដំបូងខេត្តព្រះសីហនុ** (ព. គីមសៀ)

**កម្មវត្ថុ:** សំណើរសុំផ្សាយជាសាធារណៈនូវដីកាកោះ ដីកាផ្សេងៗ សាលក្រម ឬលិខិតផ្សេងៗ ទៀត ដែលត្រូវផ្សព្វផ្សាយដើម្បីឲ្យចុងចម្លើយ បានដឹងអំពីខ្លឹមសារនៃចំណាត់ការ របស់តុលាការតាមលិខិតទាំងនោះ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ១៧១ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩ របស់សាលា ដំបូងខេត្តព្រះសីហនុ ។

**យោង:** មាត្រា២៥៥ និងមាត្រា២៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

- សំណុំរឿងរដ្ឋប្បវេណីលេខ១៧១ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩ របស់សាលា ដំបូងខេត្តព្រះសីហនុ ទទួលចំណាត់ការដោយលោកចៅក្រម តាក់ គីមសៀ ។
- ពាក្យតំណាងដោយអាណត្តិដែលមានក្នុងសំណុំរឿងស្រាប់ ។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយស សូមជម្រាបជូន លោកប្រធាន មេត្តាជ្រាបថា: ដោយហេតុថា តុលាការបានយកដីកាកោះឲ្យឈ្មោះ សុខ វុឌ្ឍី តាមអាសយ ដ្ឋានក្នុងពាក្យបណ្ដឹងនៃសំណុំរឿងខាងលើ ប៉ុន្តែចុងចម្លើយឈ្មោះ សុខ វុឌ្ឍី បានផ្លាស់ប្ដូរទីលំ នៅរបស់ខ្លួនដែលមានទីលំនៅស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ទៅកន្លែងផ្សេង គឺពុំដឹងទៅស្នាក់នៅទីណាវិញទេ ហើយបច្ចុប្បន្នកូនក្ដីខ្ញុំបាទពុំបានដឹងអំពី អាសយដ្ឋានថ្មីរបស់ចុងចម្លើយឈ្មោះ សុខ វុឌ្ឍី នោះទេ ដែលជាហេតុបង្កជាផលវិបាកក្នុង ការបន្តដំណើរការរឿងក្ដីនេះតាមនីតិវិធី ហេតុដូចនេះខ្ញុំបាទសូមសំណូមពរ លោកប្រធាន មេត្តាសម្រេចផ្សាយជាសាធារណៈនូវដីកាកោះ ដីកាផ្សេងៗ សាលក្រម ឬលិខិតផ្សេងទៀត របស់តុលាការ ដែលត្រូវផ្សព្វផ្សាយបញ្ជូនឲ្យចុងចម្លើយបានដឹងអំពីខ្លឹមសារចំណាត់ការ សំណុំរឿងក្នុងលិខិតទាំងនោះ និងដើម្បីបន្តដំណើរការនីតិវិធីបានធម្មតា ។

អាស្រ័យហេតុនេះ ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់កូនក្ដីខ្ញុំ និងក្នុងគោល បំណងអនុវត្តអោយបានត្រឹមត្រូវតាមច្បាប់ផង ខ្ញុំបាទសូមសំណូមពរ **លោកប្រធាន** មេត្តា សម្រេចតាមសំណើររបស់ខ្ញុំបាទក្នុងកម្មវត្ថុខាងលើដោយក្ដីអនុគ្រោះ។

សូម **លោកប្រធាន** ទទួលនូវការគោរពរាប់អាន ពីខ្ញុំ ។

**ធ្វើភ្នំពេញនៅថ្ងៃទី០២ ខែ០៩ ឆ្នាំ២០១៩**

**ហត្ថលេខា និងត្រា**

ព្រះរាជាណាចក្រកម្ពុជា
មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

**មេធាវី** [redacted]

របស់ខ្លួនដែលមានទំហំសរុបប្រហែល៨៧១៥៧ម$^2$ មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ តាមកិច្ចសន្យាលក់ផ្តាច់ចុះថ្ងៃទី១៥ ខែ០៦ ឆ្នាំ២០១៦ និងលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១៥ ខែ០៦ ឆ្នាំ២០១៦ រវាងឈ្មោះ សុខ វន្នី និងឈ្មោះ សុខ ចន្ទី និងឈ្មោះ សយ សុភាព។ ក្រោយពីបានទទួលការផ្ទេរសិទ្ធិកាន់កាប់ដីនេះពីឈ្មោះ សុខ វន្នី រួចមកខ្ញុំបាទបានកាន់កាប់ដីនេះរហូតមកដល់បច្ចុប្បន្ន ដោយបានធ្វើបង្គោលរបងថ្មព័ទ្ធជុំវិញដី និងបានសង់ផ្ទះរស់នៅលើដីនេះតាំងពីពេលនោះរហូតមកដល់បច្ចុប្បន្ន ការដែលខ្ញុំបាទចុះកិច្ចសន្យាទិញលក់ផ្តាច់ និងផ្ទេរសិទ្ធិកាន់កាប់ដីនេះជាមួយនឹង ឈ្មោះ សុខ វន្នី គឺធ្វើឡើងដោយឆន្ទៈព្រមព្រៀងរបស់គូភាគីដោយពិតប្រាកដ និងដោយសេរី គ្មានការបង្ខិតបង្ខំពីអ្នកណាឡើយ។ ហេតុដូច្នេះតាមច្បាប់ កិច្ចសន្យាទិញលក់គឺជាច្បាប់របស់ ភាគីអ្នកទិញ និងអ្នកលក់ ហេតុនេះអ្នកទិញ និងអ្នកលក់ត្រូវគោរពកាតព្វកិច្ចនៃកិច្ចសន្យាទៅ វិញទៅមកឲ្យបានត្រឹមត្រូវតាមការព្រមព្រៀង និងតាមច្បាប់ជាធរមាន ចំពោះខ្ញុំបាទ និងប្រពន្ធវិញគឺបានប្រគល់ប្រាក់ថ្លៃដីជូនទៅអ្នកលក់រួចរាល់អស់ហើយ នៅឡើយតែអ្នកលក់ ឈ្មោះ សុខ វន្នី ផ្តិតមេដៃលើឯកសារបែបបទចុះបញ្ជីរបស់សុរិយោដីផ្ទេរសិទ្ធិកាន់កាប់មកឲ្យខ្ញុំបាទកាន់កាប់ជាកម្មសិទ្ធិស្របច្បាប់តែប៉ុណ្ណោះ។ ហេតុដូច្នេះ ផ្អែកតាមមាត្រា៥៥៤ និងមាត្រា៥៥៥ នៃក្រមរដ្ឋប្បវេណីបានចែងថា "**ក្នុងករណីអ្នកទិញបានបង់ប្រាក់ថ្លៃទិញលក់រួចឲ្យទៅអ្នកលក់ គឺអ្នកលក់មានសិទ្ធិធ្វើសកម្មភាពស្នើសុំចុះបញ្ជីដីនេះបាន។**" ហេតុដូច្នេះ ដោយខ្ញុំបាទបានចុះកិច្ចសន្យាទិញលក់ដីផ្តាច់ជាមួយនឹងឈ្មោះ សុខ វន្នី រួចហើយ ហើយក៏បានបង់ ប្រាក់ថ្លៃទិញលក់ឲ្យទៅឈ្មោះ សុខ វន្នី រួចហើយដែរ ដូច្នេះខ្ញុំបាទស្នើសុំតុលាការមេត្តាសម្រេចអនុញ្ញាត្តិឲ្យមន្ត្រីជំនាញសុរិយោដីចុះវាស់វែង និងចុះបញ្ជីធ្វើប័ណ្ណកម្មសិទ្ធិលើដីទំហំប្រហែល៨៧១៥៧ម$^2$ មានទីតាំងស្ថិតនៅភូមិ៣ សង្កាត់១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ឲ្យខ្ញុំបាទកាន់កាប់ជាកម្មសិទ្ធិចាប់ពីពេលនេះតទៅ ។

## II.អំពីភស្តុតាងដែលបញ្ជាក់ពីមូលហេតុនៃការទាមទារ

យោងតាមអង្គហេតុដែលខ្ញុំបាទបានជម្រាបជូន លោកប្រធាន ដូចខាងលើនេះ ខ្ញុំបាទមានភស្តុតាងជាឯកសារ និងសាក្សីមួយចំនួន ដែលបញ្ជាក់ពីភាពត្រឹមត្រូវនៃមូលហេតុនៃការទាមទាររបស់ខ្ញុំបាទ ដែលភស្តុតាងទាំងនោះរួមមាន:

១. ភស្តុតាងជាឯកសារ

- ពាក្យសុំចេញដីកាសម្រេចរក្សាការពារចុះថ្ងៃទី២៥ ខែ១២ ឆ្នាំ២០១៨ របស់ខ្ញុំបាទ ។
- កិច្ចសន្យាលក់ផ្តាច់ ចុះថ្ងៃទី១៥ ខែ០៦ ឆ្នាំ២០១៦ រវាងឈ្មោះ សុខ វន្នី ជាមួយឈ្មោះ សយ សុភាព និង សុខចន្ទី ។
- លិខិតលក់ដីចុះថ្ងៃទី០៧ ខែ០៥ ឆ្នាំ១៩៩៨ រវាងឈ្មោះ ហៃ ចាន់ថន ជាមួយឈ្មោះ សុខ វន្នី ។
- លិខិតលក់ដីចុះថ្ងៃទី០៥ ខែ០៧ ឆ្នាំ១៩៩៨ រវាងឈ្មោះ ទស់ វិច ជាមួយឈ្មោះ សុខ វន្នី ។
- លិខិតលក់ដីចុះថ្ងៃទី០៩ ខែ១០ ឆ្នាំ២០០៣ រវាងឈ្មោះ ចំរើន វន្នីកា ជាមួយឈ្មោះ សុខ វន្នី ។
- លិខិតលក់ផ្តាច់ចុះថ្ងៃទី០៩ ខែ០៦ ឆ្នាំ២០០៦ រវាងឈ្មោះ យក់ សុផល ជាមួយឈ្មោះ សុខ វន្នី ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តព្រះសីហនុ**
លេខ:..៧.៧.៧............ត.វ/២០

**ដីកាសម្រេច**
**ស្តីពីការអនុញ្ញាតឱ្យធ្វើការផ្សាយជាសាធារណៈ**

យើង [redacted] ជាចៅក្រមទទួលបន្ទុកនៃសាលាដំបូងខេត្តព្រះសីហនុ .

បានឃើញ: មាត្រា២៥៥-២៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

បានឃើញ: សំណុំរឿងរដ្ឋប្បវេណីលេខ: ១៩០ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០។

បានឃើញ: ចំណារ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២០ របស់លោក គង់ ប៊ុនធីម អនុប្រធានភូមិ០៤។

**ក្រោយពីបានពិនិត្យរួចរាល់ហើយ**
**យល់ឃើញថា**

ទោះបីបានខំប្រឹងប្រែងធ្វើការស្រាវជ្រាវរកលំនៅដ្ឋាន ឬទីសំណាក់របស់ភាគី ឬកន្លែងផ្សេងទៀត ដែលត្រូវធ្វើការបញ្ជូនក៏ដោយ ក៏នៅតែរកមិនឃើញ។

**ហេតុដូច្នេះសម្រេច**

ឱ្យមានការបញ្ជូនតាមការផ្សាយជាសាធារណៈ

ថ្ងៃចន្ទ ០៣រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ខេត្តព្រះសីហនុ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០
**ចៅក្រមទទួលបន្ទុក**

[redacted]

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តព្រះសីហនុ**

លេខ: 7455 របក/១៩

## លិខិតជូនដំណឹង

## អំពី ការបញ្ជូនតាមការផ្សាយជាសាធារណៈ

[redacted]

យើង រៃ វណ្ណៈ ជាក្រឡាបញ្ជី នៃសាលាដំបូងខេត្តព្រះសីហនុ

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១៧១ ចុះថ្ងៃទី ២៤ ខែ កក្កដាឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៩៦/១៨ (គ) ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រះសីមាន ។

សូមជូនដំណឹងមកឈ្មោះ **សុខ ឌុន្សី** ភេទប្រុស អាយុ៥៧ឆ្នាំជាតិខ្មែរមានទីលំនៅចុងក្រោយនៅក្រុមទី១៣ភូមិ០២សង្កាត់លេខ០៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ឱ្យបានជ្រាបថា សាលាដំបូងខេត្តព្រះសីហនុបានសម្រេចឱ្យធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ អំពីអនុសារៈសាលក្រមរដ្ឋប្បវេណីលេខៈ៩៦/១៨(គ) ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ ឱ្យឈ្មោះ**សុខ ឌុន្សី**ចូលមកយកអនុសារៈសាលក្រមរដ្ឋប្បវេណីលេខៈ៩៦/១៨(គ) ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

ក្នុងការបញ្ជូនតាមការផ្សាយជាសាធារណៈនេះ តុលាការៈ

បានបិទផ្សាយលិខិតជូនដំណឹងនេះនៅកន្លែងបិតប្រកាសរបស់សាលាដំបូងខេត្តព្រះសីហនុចាប់ពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅសាលាដំបូងខេត្តព្រះសីហនុ និងសាលាសង្កាត់លេខ១ -សាលាសង្កាត់លេខ០៤ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

សេចក្តីនេះសូមលោកឈ្មោះ **សុខ ឌុន្សី** មកយកអនុសារៈសាលក្រមរដ្ឋប្បវេណីលេខៈ៩៦/១៨-គៈចុះថ្ងៃទី១៥ខែវិច្ឆិកាឆ្នាំ ២០១៩ នៅបន្ទប់ស៊ីបសួរលេខ១០នៃសាលាដំបូងខេត្តព្រះសីហនុ រៀងរាល់ម៉ោងធ្វើការនិងថ្ងៃធ្វើការ។

ធ្វើនៅថ្ងៃអង្គារ៨រោចខែកត្តិកឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ខេត្តព្រះសីហនុ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៩

ក្រឡាបញ្ជី

[redacted]

ខ្ញុំបាទតាងមកការយក
លិខិតជូនដំណឹងអំពីការ
បញ្ជូនតាមការផ្សាយជា
សាធារណៈទៅប្រពន្ធ [illegible]
[illegible]
[illegible]
ឈ្មោះ សុខ [illegible]
[illegible] ថ្ងៃទី27 ខែ11 ឆ្នាំ2019

[illegible] របស់សាលាដំបូង [illegible]

1

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តព្រះសីហនុ**

លេខ: 7455 បប/១៩

# លិខិតជូនដំណឹង

## អំពី ការបញ្ជូនតាមការផ្សព្វផ្សាយជាសាធារណៈ

យើង [redacted] ជាក្រឡាបញ្ជី នៃសាលាដំបូងខេត្តព្រះសីហនុ

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១៧១ ចុះថ្ងៃទី ២៤ ខែ កក្កដាឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៩៦/១៨ (ក) ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ ។

សូមជូនដំណឹងមកឈ្មោះ **សុខ ចុន្នី** ភេទប្រុស អាយុ៥៧ឆ្នាំជាតិខ្មែរមានទីលំនៅចុងក្រោយនៅក្រុមទី១ភូមិ០២សង្កាត់លេខ០៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ឱ្យបានជ្រាបថា សាលាដំបូងខេត្តព្រះសីហនុបានសម្រេចឱ្យធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ អំពីអនុសារៈសាលក្រមរដ្ឋប្បវេណីលេខៈ៩៦/១៨(ក) ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ ឱ្យឈ្មោះ**សុខ ចុន្នី**ចូលមកយកអនុសារៈសាលក្រមរដ្ឋប្បវេណីលេខៈ៩៦/១៨(ក) ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

ក្នុងការបញ្ជូនតាមការផ្សាយជាសាធារណៈនេះ តុលាការៈ

បានបិទផ្សាយលិខិតជូនដំណឹងនេះនៅកន្លែងបិទប្រកាសរបស់សាលាដំបូងខេត្តព្រះសីហនុចាប់ពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅសាលាដំបូងខេត្តព្រះសីហនុ និងសាលាសង្កាត់លេខ១ -សាលាសង្កាត់លេខ០៤ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

សេចក្តីនេះសូមលោកឈ្មោះ **សុខ ចុន្នី** មកយកអនុសារៈសាលក្រមរដ្ឋប្បវេណីលេខៈ ៩៦/១៨-ក-ចុះថ្ងៃទី១៥ខែវិច្ឆិកាឆ្នាំ ២០១៩ នៅបន្ទប់ស៊ើបសួរលេខ១០នៃសាលាដំបូងខេត្តព្រះសីហនុ រៀងរាល់ម៉ោងធ្វើការនិងថ្ងៃធ្វើការ។

**ធ្វើនៅថ្ងៃអង្គារ៨រោចខែកត្តិកឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣**

**ខេត្តព្រះសីហនុ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៩**

**ក្រឡាបញ្ជី**

[redacted]

សាលាដំបូងខេត្តព្រះសីហនុ

# របាយការណ៍អំពីការបញ្ជូន

*ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី*

កាលបរិច្ឆេទផ្ញើចេញ : ថ្ងៃទី 27 ខែ 11 ឆ្នាំ ២០២០

លេខសំណុំរឿង : លេខ.................ចុះថ្ងៃទី..............ខែ................. ឆ្នាំ ២០២០

ឈ្មោះឯកសារដែលត្រូវបានបញ្ជូន : [illegible] 728

ឈ្មោះអ្នកទទួលបន្ទុកកិច្ចការបញ្ជូន ...

អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន : សាលាដំបូងខេត្តព្រះសីហនុ

ឈ្មោះជនដែលត្រូវទទួលការបញ្ជូន : [illegible]

*ហត្ថលេខា ឬស្នាមម្រាមដៃអ្នកទទួលឯកសារជាក់ស្តែង :* 27/11/2020 [illegible]

*ប្រអប់ខាងក្រោមត្រូវបំពេញដោយអ្នកប្រតិបត្តិការបញ្ជូន ( កញ្ញាប៉ៃ្របសណីយ៍ អាជ្ញាសាលា ឬក្រឡាបញ្ជី )*

| | |
|---|---|
| ទីកន្លែងដែលធ្វើការបញ្ជូន :........................................ | |
| កាលបរិច្ឆេទនៃការបញ្ជូន : ថ្ងៃទី..................ខែ..................ឆ្នាំ..................ម៉ោង..................ព្រឹក/រសៀល | |
| **វិធីជាក់ស្តែងក្នុងការបញ្ជូន** | |
| ☐ ១ | បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ |
| | ☐ ខ្ញុំបានពន្យល់ដល់ជនដែលត្រូវទទួលការបញ្ជូន នូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូន ពីព្រោះជននោះមិនចេះអានអក្សរ |
| ☐ ២ | បានប្រគល់ឯកសារទៅអ្នកដែលមានការយល់ដឹងសមរម្យចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់នៅកន្លែងដែលត្រូវបញ្ជូននោះទេ |
| | ☐ អ្នកបម្រើ ☐ អ្នកជិតខាងដែលធ្វើការនៅទីនោះ ☐ អ្នកនៅជាមួយ |
| | ឈ្មោះ :........................................ |
| ☐ ៣ | ឯកសារត្រូវបានទុកនៅឯទីកន្លែងដែលត្រូវធ្វើការបញ្ជូន ដោយហេតុថាបុគ្គលខាងក្រោមនេះមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល |
| | ☐ ជនដែលត្រូវទទួលការបញ្ជូន ☐ អ្នកបម្រើ<br>☐ អ្នកនៅជាមួយ ☐ អ្នកជិតខាងដែលធ្វើការនៅទីនោះ |
| | ឈ្មោះ :........................................ |
| ☐ *ខ្ញុំបានបញ្ជូនឯកសារដូចនីតិវិធីខាងលើ* | |
| ☐ *ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូន ខ្ញុំមិនបានជួបជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនេះ ។* | |
| កាលបរិច្ឆេទធ្វើរបាយការណ៍ : ថ្ងៃទី 27 ខែ 11 ឆ្នាំ 2020 | |
| ឈ្មោះ និងហត្ថលេខាអ្នកធ្វើរបាយការណ៍ :........................................ | |

[redacted]